# បណ្ឌិតសភានៃចំណេះដឹង ICT សំខាន់ៗសំរាប់ថ្នាក់ដឹកនាំរដ្ឋាភិបាល

( Academy of ICT Essentials for Government Leaders )

# មេរៀនទី ៥

## ការអភិបាលអ៊ីនធឺណែត

Ang Peng Hwa

APCICT មជ្ឈមណ្ឌលអាស៊ីនិងប៉ាស៊ីហ្វិចសំរាប់បណ្តុះបណ្តាលបច្ចេកវិទ្យាព័ត៌មាន
និងគមនាគមន៍សំរាប់ការអភិវឌ្ឍន៍

កំរងមេរៀន Academy of ICT Essentials for Government Leaders

## មេរៀនទី៥៖ ការអភិបាលអ៊ីនធឺណែត

ស្នាដៃនេះបានចេញផ្សាយនៅក្រោមអាជ្ញាប័ណ្ណ Creative Commons Attribution 3.0។ ដើម្បីមើលពីឯកសារថតចំលងនៃអាជ្ញាប័ណ្ណនេះ សូមចូលទៅកាន់ http://creativecommons.org/licenses/by/3.0/ ។

ទស្សនៈ រូបភាព និងការប៉ាន់ប្រម៉ានដែលមាននៅក្នុងការបោះពុម្ពផ្សាយនេះគឺជាការទទួលខុសត្រូវរបស់អ្នកនិពន្ធ ដែលមិនគួរត្រូវបានចាត់ទុកថាជាការឆ្លុះបញ្ចាំងពីទស្សនៈឬការព្រមព្រៀងណាមួយរបស់អង្គការសហប្រជាជាតិឡើយ។

ការចាត់ចំណាត់ថ្នាក់ផ្សេងៗដែលបានប្រើប្រាស់ និងការបង្ហាញអំពីខ្លឹមសារនៅក្នុងការបោះពុម្ពផ្សាយនេះមិនមែនជាទស្សនៈណាមួយរបស់លេខាធិការអង្គការសហប្រជាជាតិ ដែលទាក់ទងទៅនឹងឋានានុក្រមផ្នែកច្បាប់របស់ប្រទេស ដែនដី ទីក្រុង ឬតំបន់ ឬអាជ្ញាធររបស់វា ឬទាក់ទងទៅនឹង ការកំណត់ព្រំដែន ឬព្រំប្រទល់របស់វា (ប្រទេស ដែនដី□) ឡើយ។

ការនិយាយអំពីឈ្មោះក្រុមហ៊ុន និងផលិតផលពាណិជ្ជកម្មផ្សេងៗមិនមែនជាការព្រមព្រៀងណាមួយរបស់អង្គការសហប្រជាជាតិឡើយ។

មជ្ឈមណ្ឌលអាស៊ីនិងប៉ាស៊ីហ្វិចសំរាប់បណ្តុះបណ្តាលបច្ចេកវិទ្យាព័ត៌មាន
និងគមនាគមន៍អភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ (UN-APCICT)
អាស័យដ្ឋាន៖ Bonbudong, ជាន់ទី៣ នៃអាគារ Songdo Techno Park
7-50 Songdo-dong, Yeonsu-gu, ទីក្រុង Incheon សាធារណៈរដ្ឋកូរ៉េ
ទូរស័ព្ទ៖ +82 32 245 1700-02
ទូរសារ៖ +82 32 245 7712
អ៊ីម៉េល៖ info@unapcict.org
http://www.unapcict.org

រក្សាសិទ្ធិ © UN-APCICT 2009 ISBN: 978-89-955886-4-2 [94560]
រចនារូបរាងឯកសារដោយ៖ ក្រុមហ៊ុនបោះពុម្ព Scandinavian Publishing Co., Ltd និ studio triangle

បោះពុម្ពក្នុង៖ សាធារណរដ្ឋកូរ៉េ

# បុព្វកថា

សតវត្សទី២១ ត្រូវបានកត់ចំណាំដោយការពឹងពាក់គ្នាទៅវិញទៅមកកាន់តែខ្លាំងក្លារបស់មនុស្សនៅក្នុងពិភពលោកនាដំណាក់កាលសកលភាវូនីយកម្ម ។ វាជាពិភពលោកដែលឱកាសជាច្រើនត្រូវបានបើកចំហរឡើងសំរាប់មនុស្សជាច្រើនលាននាក់ តាមរយៈបច្ចេកវិទ្យាថ្មីៗ ការទទួលបានព័ត៌មាន និងចំណេះដឹងសំខាន់ៗកាន់តែទូលំទូលាយ ដែលអាចធ្វើឲ្យជីវិតមនុស្សនិងការកាត់បន្ថយភាពក្រីក្រកាន់តែប្រសើរឡើងគួរឲ្យកត់សំគាល់។ ប៉ុន្តែលទ្ធផលទាំងនេះសំរេចបានតែក្នុងករណីដែលការពឹងផ្អែកគ្នានេះធ្វើឡើងដោយសារការមានគុណធម៌ ការតាំងចិត្ត និងសាមគ្គីភាពរួមគ្នា ដើម្បីការអភិវឌ្ឍន៍មួយប្រកបដោយនិរន្តភាពសំរាប់មនុស្សទាំងអស់គ្នា។

ក្នុងប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ អាស៊ីនិងតំបន់ប៉ាស៊ីហ្វិចគឺជា □តំបន់ដែលមានឧត្តមភាព□ បើនិយាយអំពីបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ (ICT)។ បើយោងទៅតាមសហគមន៍ទូរគមនាគន៍អន្តរជាតិ (ITU) តំបន់នេះជាជំរកនៃអ្នកប្រើប្រាស់ទូរស័ព្ទលើតុចំនួន ២កោដិ និងទូរស័ព្ទចល័តចំនួន ១.៤កោដិ។ ប្រទេសចិននិងប្រទេសឥណ្ឌាតែពីរប្រទេសប៉ុណ្ណោះ កាន់កាប់តួលេខ ១ ភាគ ៤នៃអ្នកប្រើប្រាស់ទូរស័ព្ទចល័តទាំងអស់ក្នុងពិភពលោកមុនពាក់កណ្តាលឆ្នាំ ២០០៨ ។ តំបន់អាស៊ីប៉ាស៊ីហ្វិចតំណាងឲ្យអ្នកប្រើប្រាស់អ៊ីនធឺណែតចំនួន ៤០ភាគរយ នៃអ្នកប្រើប្រាស់ទាំងអស់របស់ពិភពលោក និងក៏ជាទីផ្សារ broadband ដែលធំជាងគេបំផុតក្នុងពិភពលោកផងដែរ ដោយសារមានមានចំណែក ៣៩ភាគរយក្នុងពិភពលោក។

ដោយសំអាងលើការរីកចំរើនផ្នែកបច្ចេកវិទ្យាដ៏លឿនបែបនេះ មនុស្សជាច្រើនមានចម្ងល់ថាតើគំលាតឌីជីថលត្រូវលុបបំបាត់ដែរឬទេ។ ជាអកុសល ចម្លើយទៅនឹងសំនួរនេះគឺ □មិនទាន់ទេ□។ សូម្បីតែរយៈពេល៥ឆ្នាំក្រោយកិច្ចប្រជុំកំពូលស្តីពីសង្គមព័ត៌មាន (WSIS) នៅទីក្រុង Geneva ក្នុងឆ្នាំ ២០០៣ និងសូម្បីតែមានរបកគំហើញបច្ចេកវិទ្យា និងការតាំងចិត្តរបស់អ្នកពាក់ព័ន្ធគន្លឹះៗនៅក្នុងតំបន់ក៏ដោយ ក៏ការទទួលបានសេវាគមនាគមន៍ជាមូលដ្ឋាន នៅតែហួសពីសមត្ថភាពរបស់មនុស្សភាគច្រើន ជាពិសេសជនក្រីក្រ។

មានប្រទេសច្រើនជាង ២៥ នៅក្នុងតំបន់ ដែលភាគច្រើនជាប្រទេសដែនដីកោះ និងប្រទេសគ្មានសមុទ្រ មានអ្នកប្រើប្រាស់អ៊ីនធឺណែតតិចជាង ១០នាក់ ក្នុងចំណោម ១០០នាក់ ម្យ៉ាងវិញទៀតអ្នកប្រើប្រាស់ទាំងនោះភាគច្រើនរស់នៅទីក្រុងធំៗ ក្នុងខណៈដែលប្រទេសអភិវឌ្ឍន៍មានដង់ស៊ីតេអ្នកប្រើប្រាស់រហូតដល់ ៨០នាក់ក្នុងចំណោម ១០០នាក់។ ភាពខុសគ្នារវាងការប្រើប្រាស់ broadband ក្នុងប្រទេសអភិវឌ្ឍន៍និងប្រទេសកំពុងអភិវឌ្ឍន៍កាន់តែមានកំរិតខ្ពស់ទៅទៀត។

ដើម្បីតភ្ជាប់គំលាតឌីជីថល និងសំរេចបាននូវសក្តានុពល ICT សំរាប់ការអភិវឌ្ឍន៍ក្នុងតំបន់ អ្នកធ្វើគោលនយោបាយក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ចាំបាច់ត្រូវកំនត់បណ្តាអាទិភាព អនុម័តគោល នយោបាយបង្កើតវិធានការដាក់បទបញ្ជានិងច្បាប់ ផ្តល់ការគាំទ្រថវិកា ព្រមទាំងសំរបសំរួលភាពជាដៃគូក្នុងការលើកតំកើងឧស្សាហកម្ម ICT ក៏ដូចជាជំនាញ ICT ក្នុងចំណោមប្រជាពលរដ្ឋ។

ដូចដែលផែនការសកម្មភាពរបស់ WSIS បានបញ្ជាក់ □បុគ្គលម្នាក់ៗគួរមានឱកាសទទួលបាននូវជំនាញនិងចំណេះដឹងចាំបាច់ដើម្បីស្វែងយល់ ចូលរួមនិងទទួលបានផលប្រយោជន៍ពីសង្គមព័ត៌មាននិងសេដ្ឋកិច្ចដែលពឹងផ្អែកលើចំណេះដឹង□។ ដើម្បីសំរេចលទ្ធផលនេះ ផែនការសកម្មភាពនេះបានអំពាវនាវរកកិច្ចសហការទាំងក្នុងតំបន់និងឆាកអន្តរជាតិលើវិស័យកសាងសមត្ថភាព ដែលផ្តោតសំខាន់លើការផលិតអ្នកប្រកបវិជ្ជាជីវៈ និងអ្នកជំនាញការផ្នែក ICT ក្នុងកំរិតមូលដ្ឋាន។

ដើម្បីជាការឆ្លើយតបនឹងការអំពាវនាវនេះ APCICT បានរៀបចំកំរងមេរៀនគ្រប់ជ្រុងជ្រោយមួយសំរាប់បណ្តុះបណ្តាលចំណេះដឹងអំពី ICTD ហៅថា *Academy of ICT Essentials for Government Leaders* ដែលបច្ចុប្បន្នមាន ៨មេរៀនដាច់ៗពីគ្នា ប៉ុន្តែមានទំនាក់ទំនងនឹងគ្នាដែលមេរៀនទាំងនោះ មានគោលបំណងផ្តល់ចំណេះដឹង និងជំនាញសំខាន់ៗសំរាប់ជួយអ្នកធ្វើគោលនយោបាយក្នុងការធ្វើផែនការ និងអនុវត្តជាក់ស្តែងនូវគំនិតផ្តួចផ្តើមផ្សេងៗ ឲ្យកាន់តែមានប្រសិទ្ធភាព។

APCICT ជាវិទ្យាស្ថានមួយក្នុងចំណោមវិទ្យាស្ថានប្រចាំតំបន់ទាំង ៥ ដែលចំណុះឲ្យគណកម្មការសេដ្ឋកិច្ចនិងសង្គមកិច្ចប្រចាំអាស៊ីនិងតំបន់ប៉ាស៊ីហ្វិចរបស់អង្គការសហប្រជាជាតិ (ESCAP)។ ESCAP មានតួនាទីជំរុញការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចប្រកបដោនិរន្តភាពនៅអាស៊ីនិងតំបន់ប៉ាស៊ីហ្វិច តាមរយៈការវិភាគការធ្វើបទដ្ឋានការងារ ការកសាងសមត្ថភាព កិច្ចសហប្រតិបត្តិការក្នុងតំបន់ និងការចែករំលែកចំណេះដឹង។

ក្នុងនាមជាដៃគូជាមួយនឹងទីភ្នាក់ងារ UN និងអង្គការអន្តរជាតិដទៃទៀត ក៏ដូចជាសហការជាមួយដៃគូ និងអ្នកពាក់ព័ន្ធថ្នាក់ជាតិ ESCAP មានការតាំងចិត្តខ្ពស់ក្នុងការគាំទ្រការប្រើប្រាស់ការរៀបចំសំរួលនិងបកប្រែមេរៀន *Academy* ទាំងនេះនៅតាមប្រទេសផ្សេងៗ។ មេរៀនទាំងនេះត្រូវបានចែកចាយជាប្រចាំនៅសិក្ខាសាលាថ្នាក់ជាតិនិងថ្នាក់តំបន់ សំរាប់មន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់និងមធ្យម ហើយអ្វីដែលយើងចង់បាននោះគឺ សមត្ថភាពក៏ដូចជាចំណេះដឹងដែលទទួលបាននឹងធ្វើឲ្យមានការកើនឡើង នៃការយល់ដឹងអំពីផលប្រយោជន៍របស់ ICT និងរៀបចំសកម្មភាពជាក់លាក់ដើម្បីសំរេចគោលដៅអភិវឌ្ឍន៍។

Noeleen Heyzer

អគ្គលេខាធិការរងនៃអង្គការសហប្រជាជាតិ និង

លេខាធិការប្រតិបត្តិនៃ ESCAP

# អារម្ភកថា

ដំណើរការបង្កើតកំរងមេរៀន *Academy of ICT Essentials for Government Leaders* គឺពិតជាបទពិសោធន៍ជាក់ស្តែងនិងជាកក្តាជំរុញមួយផងដែរ ។ *Academy* មិនត្រឹមតែជួយបំពេញចន្លោះក្នុងការសាងសមត្ថភាពប៉ុណ្ណោះទេ ថែមទាំងជាអ្នកត្រួសត្រាយផ្លូវថ្មីមួយសំរាប់ការបង្កើតជាកំរងមេរៀនសិក្សាផងដែរ តាមរយៈការអោយមនុស្សមានការចូលរួម និងមានកម្មសិទ្ធនៃខ្លឹមសារដែលបានតាក់តែងឡើង។

*Academy* គឺជាគំរោងដ៏សំខាន់ជាងគេរបស់ APCICT ដែលត្រូវបានចងក្រងឡើងដោយផ្អែកទៅលើ (១) លទ្ធផលនៃការស្ទាបស្ទង់វាយតំលៃលើតំរូវការសំខាន់ៗរបស់ប្រទេសចំនួនជាង ២០ នៅក្នុងតំបន់ ដោយរួមទាំងការប្រឹក្សាជាមួយមន្ត្រីរដ្ឋាភិបាល សមាជិកនៃសហគមន៍អភិវឌ្ឍន៍អន្តរជាតិ អ្នកស្រាវ ជ្រាវទ្រឹស្តី និងអ្នកអប់រំ (២) ការសិក្សាស្រាវជ្រាវស៊ីជម្រៅ និងការវិភាគលើចំនុចខ្លាំងនិងចំនុចខ្សោយនៃឯកសារបណ្តុះបណ្តាលដែលមានពីមុនមក (៣) យោបល់ត្រលប់ពីអ្នកចូលរួមបណ្តាសិក្ខាសាលាដែលរៀបចំឡើងនៅក្នុងតំបន់ ដោយ APCICT ស្តីពីសារៈសំខាន់ និងភាពពាក់ព័ន្ធនៃខ្លឹមមេរៀន និងវិធីសាស្រ្តក្នុងការបណ្តុះបណ្តាលដែលសមរម្យ (៤) ព្រមទាំងដំណើរការត្រួតពិនិត្យឡើងវិញយ៉ាងមុតមាំរវាងគ្នានឹងគ្នាដែលធ្វើឡើងដោយអ្នកជំនាញការកំពូលៗក្នុងផ្នែក ICTD។ សិក្ខាសាលាស្តីពី *Academy* ដែលបានធ្វើឡើងនៅទូទាំងតំបន់ បានផ្តល់ឱកាសដ៏មានតំលៃសំរាប់ផ្លាស់ប្តូរបទពិសោធន៍ និងចំណេះដឹងក្នុងចំណោមសិក្ខាកាមមកពីប្រទេសផ្សេងៗ ដែលដំណើរការនេះធ្វើឲ្យអ្នកដែលមានបទពិសោធន៍ និងទ្រឹស្តីរបស់ *Academy* ក្លាយជាអ្នកដើរតួដ៏សំខាន់ក្នុងការរចនារូបរាងនៃមេរៀនទាំងនេះឡើង។

ការដាក់ឲ្យប្រើប្រាស់មេរៀន *Academy* ចំនួន ៨ ដំបូងក្នុងកំរិតជាតិ គឺជាការសំគាល់នៃការចាប់ផ្តើមរបស់ដំណើរដ៏មានសារៈសំខាន់សំរាប់ពង្រឹងភាពជាដៃគូរដែលមានកន្លងមក ក៏ដូចជាបង្កើតភាពជាដៃគូថ្មីៗបន្ថែម ដើម្បីអភិវឌ្ឍសមត្ថភាពក្នុងការធ្វើគោលនយោបាយ ICTD នៅទូទាំងតំបន់។ APCICT បានតាំងចិត្តក្នុងការផ្តល់ជំនួយបច្ចេកទេសដើម្បីបង្កើតឲ្យមាន *Academy ថ្នាក់ជាតិ* ដែលជាគន្លឹះ សំរាប់ធានាឲ្យមេរៀន *Academy* បានទៅដល់អ្នកធ្វើគោលនយោបាយទាំងអស់។ APCICT ក៏បាននឹងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងវិទ្យាស្ថានបណ្តុះបណ្តាលថ្នាក់ជាតិនិងថ្នាក់តំបន់ជា ច្រើនដែលបានបង្កើតខ្សែបណ្តាញជាមួយរដ្ឋាភិបាលថ្នាក់មូលដ្ឋាន ថ្នាក់រដ្ឋ និងថ្នាក់កណ្តាលរួចរាល់ហើយនោះ ដើម្បីធ្វើឲ្យប្រសើរឡើងនូវសមត្ថភាពរបស់ពួកគេក្នុងការរៀបចំសំរួល បកប្រែ និងចែក ចាយកំរងមេរៀន *Academy*

ដោយគិតគូដល់បណ្ដាគំរូការនិងអាទិភាពរបស់ជាតិ។ ផែនការជាច្រើនត្រូវបានបង្កើតឡើងដើម្បីពង្រីកបន្ថែមភាពស៊ីជម្រៅនិងការគ្របដណ្ដប់របស់បណ្ដាមេរៀនដែលមានកន្លងមក និងការបង្កើតមេរៀនថ្មីៗបន្ថែម។

លើសពីនេះទៅទៀត APCICT បាននឹងកំពុងប្រើវិធានបែបច្រើនច្រក ដើម្បីធានាថាខ្លឹមសាររបស់ *Academy* អាចទទួលយកបានដោយអ្នកអាននៅក្នុងតំបន់។ ក្រៅពីមធ្យោបាយជួបមុខគ្នាដោយផ្ទាល់ ដើម្បីចែកចាយកំរងមេរៀន *Academy* តាមរយៈ *Academy* ថ្នាក់ជាតិ និងថ្នាក់តំបន់ ក៏មាន *Academy* របស់ APCICT នៅលើបណ្ដាញ (AVA) សំរាប់ឲ្យសិក្ខាកាមសិក្សាពីចម្ងាយនៅនឹងកន្លែងរបស់ពួកគេ។ AVA នឹងធានាថាកំរងមេរៀន *Academy* ទាំងអស់ ព្រមទាំងឯកសារដែលភ្ជាប់មកជាមួយដូចជា slide បង្ហាញមេរៀន និងការសិក្សាករណីជាក់ស្ដែងផ្សេងៗ និងងាយចូលទៅរកលើបណ្ដាញសំរាប់ទាញយក ប្រើប្រាស់ឡើងវិញ រៀបចំកែសំរួល និងបកប្រែ ម្យ៉ាងវិញទៀត AVA មានមុខងារជាច្រើនដូចជា ការបង្រៀនលើបណ្ដាញ ឧបករណ៍គ្រប់គ្រងការរៀន ឧបករណ៍ចងក្រងខ្លឹមសារ និងវិញ្ញាបនប័ត្រ។

ការបង្កើតឈុតដំបូងដែលមាន ៨មេរៀន និងការចែកចាយតាមរយៈសិក្ខាសាលា *Academy* ថ្នាក់ជាតិ ថ្នាក់អនុតំបន់ និងតំបន់ មិនអាចប្រព្រឹត្តិទៅបានឡើយ បើសិនជាគ្មានការតាំងចិត្ត ការលះបង់ និងការចូលរួមសំរបសំរួលពីសំណាក់បុគ្គលនិងអង្គភាពជាច្រើន។ ខ្ញុំសូមឆ្លៀតឱកាសនេះ ទទួលស្គាល់នូវកិច្ចប្រឹងប្រែង និងសមិទ្ធិផលដែលកើតឡើងដោយអ្នកដែលមានបទពិសោធន៍និងទ្រឹស្ដីរបស់ *Academy* ក៏ដូចជាបណ្ដាដៃគូរបស់យើងដែលមកពីក្រសួងរដ្ឋាភិបាល វិទ្យាស្ថានបណ្ដុះបណ្ដាល និង អង្គការថ្នាក់ជាតិ និងតំបន់ ដែលពួកគេបានចូលរួមក្នុងបណ្ដាសិក្ខាសាលា *Academy*។ ពួកគេមិនត្រឹមតែផ្ដល់យោបល់ចូលរួមមានតំលៃសំរាប់បង្កើតខ្លឹមសារប៉ុណ្ណោះទេ ថែមទាំងសំខាន់ជាងនេះទៅទៀត បានក្លាយជាអ្នកគាំទ្រ *Academy* នៅក្នុងប្រទេសរបស់គេ ដែលទាំងនេះធ្វើឲ្យមានកិច្ចព្រមព្រៀងជាផ្លូវការរវាង APCICT និងវិទ្យាស្ថានដៃគូថ្នាក់ជាតិនិងតំបន់ជាច្រើន ស្ដីពីការរៀបចំសំរួល និងផ្ដល់ជាវគ្គសិក្សា *Academy* នៅក្នុងប្រទេស។

ខ្ញុំក៏សូមទទួលស្គាល់ជាពិសេសចំពោះកិច្ចប្រឹងប្រែងយ៉ាងពេញទំហឹងរបស់បុគ្គលដ៏គួឲ្យស្ញើចសរសើរជាច្រើន ដែលបានធ្វើឲ្យសមទ្ធិផលនេះចេញជារូបរាងឡើង។ ពួកគេទាំងនោះរួមមាន លោក Shahid Akhtar

ដែលជាអ្នកប្រឹក្សាគំរោង *Academy*, លោក Patricia Arinto ដែលជាអ្នកកែតម្រូវ, លោក Christine Apikul នាយកបោះពុម្ព, អ្នកនិពន្ធ *Academy* ទាំងអស់ ព្រមទាំងក្រុមការងារ APCICT។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាកំរងមេរៀន *Academy* នឹងជួយបណ្តាប្រជាជាតិទាំងអស់កាត់បន្ថយគំលាតធនធានមនុស្ស ដកចេញនូវឧបសគ្គនៃទទួលយក ICT និងជំរុញការប្រើប្រាស់ ICT ក្នុងការ បង្កើនល្បឿនការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ច ដើម្បីសំរេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្ស។

Hyeun-Suk Rhee

ប្រធាន

UN-APCICT

# អំពីកំរងមេរៀន

នៅយុគសម័យព័ត៌មានវិទ្យាបច្ចុប្បន្ន ការងាយទទួលបានព័ត៌មានបានផ្លាស់ប្តូររបៀបដែលយើងរស់ នៅ ធ្វើការនិងលេងកំសាន្ត។ □សេដ្ឋកិច្ចឌីជីថល□ (digital economy) ដែលអាចហៅបានថា □សេដ្ឋកិច្ចចំណេះដឹង□ (knowledge economy) □សេដ្ឋកិច្ចបណ្តាញទំនាក់ទំនង□ (networked economy) ឬ □សេដ្ឋកិច្ចថ្មី□ (new economy) ត្រូវបានកត់សំគាល់ដោយការផ្លាស់ប្តូរពីការផលិតទំនិញទៅជាការផលិតគំនិត។ ស្ថានភាពនេះផ្តល់សារៈសំខាន់កាន់តែខ្លាំងទៅលើការដើរតួរបស់បច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ (ICT) នៅក្នុងវិស័យសេដ្ឋកិច្ច និងក្នុងសង្គមទាំងមូល។

ដោយសារមូលហេតុនេះ ទើបរដ្ឋាភិបាលទាំងអស់នៅទូទាំងពិភពលោកបានផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងទៅលើបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍សំរាប់អភិវឌ្ឍន៍ (ICTD)។ សំរាប់រដ្ឋាភិបាលទាំង នេះ ICTD មិនត្រឹមតែជាសកម្មភាពអភិវឌ្ឍន៍វិស័យ ICT ឬវិស័យសេដ្ឋកិច្ចប៉ុណ្ណោះទេ ថែមទាំងជាចលករជំរុញការលូតលាស់សេដ្ឋកិច្ច ក៏ដូចជាសង្គមនិងនយោបាយ។

ទោះជាយ៉ាងណាក៏ដោយ ក្នុងចំណោមការលំបាកទាំងឡាយដែលរដ្ឋាភិបាលទាំងនោះជួបប្រទះក្នុងដំណើរការបង្កើតគោលនយោបាល ICT នោះគឺអ្នកធ្វើគោលនយោបាយជាញឹកញាប់មិនមានភាពស្និទ្ធស្នាលជាមួយនឹងបច្ចេកវិទ្យាដែលពួកគេកំពុងប្រើដើម្បីអភិវឌ្ឍជាតិ។ ដោយសារតែគ្មាននរណាម្នាក់អាចដាក់បទបញ្ជាលើអ្វីដែលខ្លួនមិនយល់បាននោះ អ្នកធ្វើគោលនយោបាយជាច្រើនមានការអល់អែកក្នុងការធ្វើគោលនយោបាយ ICT។ ប៉ុន្តែ បើទុកការងារធ្វើគោលនយោបាយនេះឲ្យអ្នកបច្ចេក ទេសជាអ្នកធ្វើក៏មិនត្រឹមត្រូវផងដែរ ពីព្រោះជាញឹកញាប់អ្នកបច្ចេកទេសមិនបានដឹងពីការជះ ឥទ្ធិពលនយោបាយរបស់បច្ចេកវិទ្យាដែលគេកំពុងបង្កើតនិងប្រើប្រាស់ឡើយ។

កំរងមេរៀន *Academy of ICT Essentials for Government Leaders* ត្រូវបានអភិវឌ្ឍឡើងដោយមជ្ឈមណ្ឌលអាស៊ីនិងប៉ាស៊ីហ្វិចសំរាប់បណ្តុះបណ្តាលបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍អភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ (UN-APCICT) សំរាប់៖

១. អ្នកធ្វើគោលនយោបាយនៅរដ្ឋាភិបាលថ្នាក់មូលដ្ឋាននិងថ្នាក់ជាតិ ដែលទទួលខុសត្រូវការធ្វើគោលនយោបាយ ICT

២. មន្ត្រីរដ្ឋាភិបាលដែលទទួលខុសត្រូវការងារបង្កើតនិងអនុវត្តកម្មវិធីប្រើប្រាស់ ICT និង

៣. អ្នកគ្រប់គ្រងក្នុងផ្នែកសារធារណៈ ដែលកំពុងស្វែងរកឧបករណ៍ ICT យកមកប្រើប្រាស់សំរាប់គ្រប់គ្រងគំរោង។

កំរងមេរៀននេះមានគោលបំណងបង្កើនភាពស្និទ្ធស្នាលជាមួយនឹងបញ្ហាសំខាន់ៗទាក់ទងនឹង ICTD ទាំងក្នុងទស្សនៈវិស័យនយោបាយនិងបច្ចេកវិទ្យា។ វាមិនមានចេតនាសំរាប់ប្រើធ្វើជាសៀវភៅក្បួន ICT ឡើយ ប៉ុន្តែសំរាប់ជាការផ្តល់ការយល់ដឹងដ៏ល្អអំពីអ្វីដែលបច្ចេកវិទ្យាបច្ចុប្បន្នអាចធ្វើបាន តើបច្ចេកវិទ្យាកំពុងអភិវឌ្ឍន៍ឆ្ពោះទៅរកទិសដៅណា និងអ្វីដែលជាអត្ថន័យសំរាប់ការធ្វើគោលនយោបាយ។ ប្រធានបទដែលបានគ្របដណ្តប់នៅក្នុងមេរៀនទាំងនោះ ត្រូវបានរកឃើញតាមរយៈការវិភាគទៅលើគំរូការឱ្យមានការបណ្តុះបណ្តាល និងការសិក្សាទៅលើឯកសារបណ្តុះបណ្តាលនៅទូទាំងពិភពលោក។

មេរៀនទាំងនោះត្រូវបានតាក់តែងឡើងសំរាប់អាចយកទៅសិក្សាដោយអ្នកអានខ្លួនឯង ក៏ដូចជាប្រើជាធនធានក្នុងវគ្គឬកម្មវិធីបណ្តុះបណ្តាលណាមួយ។ មេរៀននីមួយៗមានលក្ខណៈដោយឡែកៗពីគ្នា តែមានទំនាក់ទំនងនឹងគ្នា ដោយមានការប្រឹងប្រែងផ្សាភ្ជាប់ខ្លឹមសាររបស់មេរៀនមួយជាមួយនឹងមេរៀនបន្ទាប់ក្នុងកំរងមេរៀនទាំងមូល។ គោលបំណងយូរអង្វែងគឺធ្វើយ៉ាងណាឱ្យមេរៀនទាំងនោះក្លាយជាវគ្គសិក្សាមានការស៊ីសង្វាក់គ្នាដែលមានការទទួលស្គាល់និងបញ្ជាក់ត្រឹមត្រូវ។

## មេរៀនទី ៥

អ៊ីនធឺណែតបានបង្កឲ្យមានការអភិវឌ្ឍន៍មនុស្សជាតិប្រកបដោយចីរភាព ក៏ដូចជាបញ្ហាប្រឈមសំខាន់ៗចំពោះនយោបាយសាធារណៈ។ ដូច្នេះចាំបាច់ត្រូវមានការបង្កើតជាប្រចាំនូវគោលនយោបាយនិងនីតិវិធីអន្តរជាតិទាក់ទងនឹងការប្រើប្រាស់ និងប្រតិបត្តិការនៃប្រព័ន្ធអ៊ីនធឺណែត។ ទោះជាតំបន់អាស៊ីប៉ាស៊ីហ្វិកគ្របដណ្តប់លើចំនួនអ្នកប្រើប្រាស់អន្តរជាតិច្រើនជាងគេក៏ដោយការលាតត្រដាង នៃវេទិកាដែលបង្កើតគោលនយោបាយទាំងឡាយទាក់ទងនឹងអ៊ីនធឺណែត នៅមិនទាន់បានគ្រប់គ្រាន់នៅឡើយ។ នៅមានបញ្ហាប្រឈមប្រចាំតំបន់ជាច្រើនដែលទាក់ទងទៅនឹងការអភិបាលប្រព័ន្ធអ៊ីនធឺណែត។ រដ្ឋាភិបាលទាំងឡាយនៃប្រទេសកំពុងអភិវឌ្ឍន៍ត្រូវយល់ពីបញ្ហាទាំងនេះ ដើម្បីអាចមានសំឡេងក្នុងបណ្តាញព័ត៌មានពិភពលោក។

### គោលបំណង

មេរៀននេះមានគោលបំណងដើម្បី៖

១. រៀបរាប់ពីដំណើរការបង្កើតគោលនយោបាយ និងនីតិវិធីអន្តរជាតិដែលគ្រប់គ្រងការប្រើប្រាស់ និងប្រតិបត្តិការប្រព័ន្ធអ៊ីនធឺណែត និង

២. ផ្តល់ជូនការសង្ខេបគ្រួសៗនូវបញ្ហាប្រឈមទាក់ទងនឹងការអភិបាលប្រព័ន្ធអ៊ីនធឺណែត ក្នុងបរិបទតំបន់។

### លទ្ធផលរំពឹងទុក

បន្ទាប់ពីសិក្សាមេរៀននេះ អ្នកអានអាចនឹងមានសមត្ថភាពដើម្បី៖

១. រៀបរាប់ពីការអភិវឌ្ឍន៍នៃគោលនយោបាយ និងនីតិវិធីអន្តរជាតិគ្រប់គ្រងការប្រើប្រាស់និងប្រតិបត្តិការរបស់ប្រព័ន្ធអ៊ីនធឺណែត

២. ពិភាក្សាបញ្ហាគន្លឹះៗក្នុងការអភិបាលប្រព័ន្ធអ៊ីនធឺណែតក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និង

៣. គូសបញ្ជាក់ពីបណ្តាជំហ៊ានដំបូងឆ្ពោះទៅរកការអភិបាលប្រព័ន្ធ ដែលប្រសើរជាងមុនក្នុងប្រទេសរបស់ពួកគេ។

# មាតិកា


បុព្វកថា ..... 3

អារម្ភកថា ..... 6

អំពីកំរងមេរៀន ..... 9

មេរៀនទី ៥ ..... 11

គោលបំណង ..... 11

លទ្ធផលរំពឹងទុក ..... 11

បញ្ជីករណីជាក់ស្តែង ..... 14

បញ្ជីរូបភាព ..... 14

ពាក្យកាត់ ..... 15

បញ្ជីនិមិត្តសញ្ញា ..... 16

១បញ្ហា . និងវិសាលភាពនៃការអភិបាលប្រព័ន្ធអ៊ីនធឺណែត ..... 17

១សេចក្តីផ្តើម ១. ..... 17

១.២ ប្រវត្តិ និងការផ្តួចផ្តើមបច្ចេកទេសអ៊ីនធឺណែត ..... 18

២.ពហុភាគី និង ពហុវិស័យនៃការអភិបាលប្រព័ន្ធអ៊ីនធឺណែត ..... 25

២១. និយមន័យ ..... 25

២២. អនុសាសន៍ ..... 27

៣ទំហំនៃការអភិបាលប្ .រព័ន្ធអ៊ីនធឺណែត១៖ ការប្រើប្រាស់អ៊ីនធឺណែត ..... 33

៣.១ វិធីសាស្រ្តក្នុងការដាក់បទបញ្ញា ..... 33

៣ទិសដៅណែនាំ ២. ..... 36

៤៖២ទំហំនៃការអភិបាលប្រព័ន្ធអ៊ីនធឺណែត. ការប្រើប្រាស់អ៊ីនធឺណែតមិនត្រឹមត្រូវ ................................ 48
៤.១ តើមានអ្វីពិសេសជាមួយប្រព័ន្ធអ៊ីនធឺណែត ........................................................................ 48
៤.២ ការប្រើប្រាស់អ៊ីនធឺណែតមិនត្រឹមត្រូវ ............................................................................ 49
៤៣. ការដាក់ទណ្ឌកម្ម ......................................................................................................... 57
៥បញ្ហាដូចគ្នាទៅនឹងសង្គមខាងក្រៅ............................................................................................. 64
៥១. នយោបាយប្រកួតប្រជែង ................................................................................................ 64
៥២. ការត្រួតពិនិត្យ និងសិទ្ធិក្នុងការបញ្ចេញមតិ ........................................................................ 66
៥៣. ការបង្ខូចកេរ្តិ៍ឈ្មោះ ........................................................................................................ 69
៥.៤ សិទ្ធិអ្នកនិពន្ធ និងកម្មសិទ្ធិបញ្ញាដទៃៗទៀត ..........................................................................71
៥.៥ ភាពជាឯកជន.................................................................................................................. 72
៦. ទំហំនៃការអភិវឌ្ឍន៍៖ ភាពខុសគ្នានៃកំរិតឌីជីថល ........................................................................ 74
៦.១ ICT សំរាប់ការអភិវឌ្ឍន៍.................................................................................................... 74
៦.២ ដែនកំណត់ និងឧបសគ្គ ................................................................................................... 76
៦.៣ ការប្រើប្រាស់ ICTD........................................................................................................ 76
៧. ការអភិបាលប្រព័ន្ធអ៊ីនធឺណែត៖ ការប្រមើលមើលទៅមុខ ............................................................. 79
កថាបន្ថែម ............................................................................................................................. 84
សំរាប់ការអានបន្ថែម ................................................................................................................ 84
សន្ទានុក្រម .............................................................................................................................. 85
កំណត់សំគាល់សំរាប់អ្នកបណ្តុះបណ្តាល ......................................................................................... 87
អំពីអ្នកនិពន្ធ............................................................................................................................ 90

## បញ្ជីករណីជាក់ស្តែង


១. ការទទួលស្គាល់ស្លាកស្នាមអេឡិចត្រូនិច

២. ខ្លឹមសារខុសច្បាប់៖ ការសំរបសំរួលជាអន្តរជាតិ

៣. វីរុស I Love You

៤. ចំរៀងខុសច្បាប់

៥. ការបំពេញលក្ខខណ្ឌស្តង់ដាអ៊ឺរុប

៦. ការលុបបំបាត់គេហទំព័រខុសច្បាប់ប្រចាំឆ្នាំ

៧. Spam Spam តើវាបញ្ចប់នៅពេលណា

៨. ដំណោះស្រាយការឈ្លក់វង្វេងនឹងអ៊ីនធឺណែត

៩. អ៊ីម៉េលបញ្ឆោតឲ្យបង់ប្រាក់ ឬការឆបោកនីហ្សេរីយ៉ា ៤១៩

១០. ការរំលោភបំពានក្នុងបណ្តាញអ៊ីនធឺណែត

១១. ក្រុមប្រឹក្សានៃសន្និសញ្ញាអ៊ឺរុបលើបទឧក្រិដ្ឋក្នុងបណ្តាញអ៊ីនធឺណែត

១២. សម្ព័ន្ធបញ្ឈប់ Spam

១៣. របបទីផ្សាសេរីក្នុងវិស័យទូរគមនាគមន៍ និងតំលៃនៃការប្រើប្រាស់អ៊ីនធឺណែត

១៤. ការច្រោះយកគេហទំព័រតាមប្រភេទ

១៥. អ៊ីនធឺណែតតាមភូមិ


## បញ្ជីរូបភាព


រូបភាពទី១៖ ការស្វែងរកគេហទំព័រណាមួយក្នុងប្រព័ន្ធអ៊ីនធឺណែត

រូបភាពទី២៖ ការចូលរួមជាពហុភាគី និងពហុវិស័យដើម្បីអភិបាលប្រព័ន្ធអ៊ីនធឺណែត

រូបភាពទី៣៖ ការថ្លឹងថ្លែងនៃកម្មសិទ្ធិបញ្ញា

## ពាក្យកាត់

| | |
|---|---|
| APCICT | មជ្ឈមណ្ឌលអាស៊ីប៉ាស៊ីហ្វិចសំរាប់ការហ្វឹកហ្វឺន បច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ដើម្បីការអភិវឌ្ឍន៍ |
| ccTLD | លេខកូដដូម៉េនបង្គោលរបស់ប្រទេស |
| CoE | ក្រុមប្រឹក្សាអ៊ឺរុប |
| CSC | មជ្ឈមណ្ឌលផ្តល់សេវាកម្មទូទៅ ឥណ្ឌា |
| DEC | សាជីវកម្មបរិក្ខារឌីជីថល |
| DNS | ប្រព័ន្ធផ្តល់ឈ្មោះដូម៉េន |
| ESCAP | គណកម្មការសេដ្ឋកិច្ច និងសង្គមកិច្ចប្រចាំអាស៊ីនិងតំបន់ប៉ាស៊ីហ្វិច |
| EU | សហគមន៍អ៊ឺរុប |
| FOSS | Software ដែលមានកូដបើកចំហរ និងឥតគិតថ្លៃ |
| GPS | ប្រព័ន្ធប្រាប់ទីតាំងសកល |
| gTLD | ដូម៉េនបង្គោលបញ្ជាក់ប្រភេទ |
| ICANN | សាជីវកម្មអ៊ីនធឺណែតសំរាប់ផ្តល់ឈ្មោះដូម៉េននិងលេខ |
| ICPEN | បណ្តាញពង្រឹងនិងការពារអ្នកប្រើប្រាស់អន្តរជាតិ |
| ICRA | សមាគមន៍កំណត់ប្រភេទខ្លឹមសារអ៊ីនធឺណែត |
| ICT | បច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ |
| ICTD | បច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ដើម្បីការអភិវឌ្ឍន៍ |
| IP | ប្រូតូកូលអ៊ីនធឺណែត |
| IPv4 | ប្រូតូកូលអ៊ីនធឺណែតវគ្គទី៤ |
| IPv6 | ប្រូតូកូលអ៊ីនធឺណែតវគ្គទី៦ |
| ITU | សហគមន៍ទូរគមនាគមន៍អន្តរជាតិ |
| MDG | គោលដៅអភិវឌ្ឍន៍សហសវត្ស |
| OECD | អង្គការសំរាប់ការសំរបសំរួលសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ |
| PPP | ភាពជាដៃគូឯកជននិងសាធារណៈ |
| RIAA | សមាគមន៍ឧស្សាហកម្មថតសំឡេងអាមេរិច |
| RIR | ការចុះបញ្ជីអ៊ីនធឺណែតប្រចាំតំបន់ |

| | |
|---|---|
| TCP/IP | ប្រូតូកូលគ្រប់គ្រងការបញ្ជូន/ប្រូតូកូលអ៊ីនធឺណែត |
| TLD | ដូម៉េនបង្គោល |
| UN | អង្គការសហប្រជាជាតិ |
| USA | សហរដ្ឋអាមេរិច |
| WGIG | ក្រុមការងារអភិបាលអ៊ីនធឺណែត |
| WSIS | ប្រជុំពេញអង្គពិភពលោកស្តីពីសង្គមព័ត៌មានវិទ្យា |

## បញ្ជីនិមិត្តសញ្ញា



ករណីជាក់ស្តែង



សំនួរពិចារណា


ការងារត្រូវធ្វើ



សាកល្បងខ្លួនឯង

# ១. បញ្ហា និងខសាលភាពនៃការអភិបាល ប្រព័ន្ធអ៊ីនធឺណែត

ផ្នែកនេះមានគោលបំណងរៀបរាប់អំពីប្រវត្តិអ៊ីនធឺណែតខ្លីៗ និង បរិបទដើម្បីអភិបាលប្រព័ន្ធអ៊ីនធឺណែត ព្រមទាំងគូសបញ្ជាក់គ្រួសៗនូវដែនគ្របដណ្តប់នៃការអភិបាលប្រព័ន្ធអ៊ីនធឺណែត។

## ១.១ សេចក្តីផ្តើម

ជាញឹកញាប់គេសន្និដ្ឋានថាមធ្យោបាយទំនាក់ទំនងថ្មីហៅថាអ៊ីនធឺណែតនេះមិនអាចធ្វើការអភិបាលបានទេ។ ប្រការនេះគេអាចយល់បានដោយសារ អ្នកប្រើប្រាស់អ៊ីនធឺណែតជំនាន់មុនជាទូទៅពោលថា អ៊ីនធឺណែតបង្កើតដើម្បីជៀសផុតពីការវាយប្រហារនុយក្លេអ៊ែរ និងការរាំងខ្ទប់ផ្សេងៗ ដែលប្រើសំរាប់ឆ្លងកាត់ព្រំប្រទល់អន្តរជាតិជាច្រើន ជាហេតុធ្វើឲ្យអ៊ីនធឺណែតមិនអាចត្រួតពិនិត្យបាន។ ពាក្យថាមិនអាចត្រួតពិនិត្យបានមានន័យថា ខ្លឹមសាររបស់វាពិបាកស្ទើរតែមិនអាចប្រើច្បាប់ទំលាប់គ្រប់គ្រងបាន និងពិបាកក្នុងការត្រួតពិនិត្យអ្នកប្រើប្រាស់[1]។

នាពេលបច្ចុប្បន្ន រយៈពេលជាង១០ឆ្នាំបន្ទាប់ពីអ៊ីនធឺណែតត្រូវបានប្រើជាសាធារណៈ យើងបានដឹងច្បាស់ថានេះជាទស្សនៈមិនត្រឹមត្រូវឡើយ តាមពិតអ៊ីនធឺណែតអាចធ្វើឲ្យមានរបៀបរាបរយបាន។ ជាក់ស្តែងកាលណាប្រទេសកាន់តែអភិវឌ្ឍន៍ ការដាក់ច្បាប់ត្រួតពិនិត្យលើអ៊ីនធឺណែតកាន់តែមាន។ ការខ្វះវិធានការគ្រប់គ្រងធ្វើឲ្យក្រុមប្រទេសកំពុងអភិវឌ្ឍន៍ក្លាយជាឋានសួគ៌សំរាប់ជនទុច្ចរិតប្រើអ៊ីនធឺណែត ដើម្បីពង្រាយ Spam និង ល្បិចបោកប្រាស់ផ្សេងៗ។

បរិមាណនៃច្បាប់ទំលាប់មិនធ្វើឲ្យរាំងស្ទះដល់ការប្រើប្រាស់អ៊ីនធឺណែតទេ។ បើដូច្នោះមែន សហរដ្ឋអាមេរិចប្រហែលជាប្រទេសដែលបង្កឧបសគ្គក្នុងការប្រើ ចំណែកប្រទេសឡាវដែលកំពុងតែមានភាពលំបាកក្នុងការបង្កើតហេដ្ឋារចនាសម្ព័ន្ធអ៊ីនធឺណែត ប្រហែលក្លាយជាប្រទេសដែលរីកលូតលាស់ខ្លាំងក្នុងវិស័យនេះ។ អ្វីដែលសំខាន់គឺច្បាប់ទំលាប់ទាំងនោះត្រូវធ្វើឡើងដោយផ្អែកលើការយល់ដឹង ផ្អែកច្បាប់

[1] Peng Hwa. 2005. *ការរៀបចំភាពច្របូកច្របល់ Ordering Chaos: ការដាក់បទបញ្ញាលើអ៊ីនធឺណែត Regulating the Internet*. Singapore: Thomson.

និងបច្ចេកទេស ព្រមទាំងសហប្រតិបត្តិការអន្តរជាតិ។ មេរៀននេះមានគោលបំនងធ្វើឲ្យយល់ច្បាស់ពីបញ្ហាទាំងនេះ និងដើម្បីបង្ហាញថាតើសហប្រតិបត្តិការអន្តរជាតិអាចធ្វើបានតាមរបៀប ណា។

## ១.២ ប្រវត្តិ និងការផ្តួចផ្តើមបច្ចេកទេសអ៊ីនធឺណែត

### ប្រវត្តិ និង ការអភិវឌ្ឍន៍បច្ចេកទេស

អ៊ីនធឺណែតមិនមែនបង្កើតឡើងដើម្បីបញ្ចៀសការវាយប្រហារនុយក្លេអ៊ែរណាមួយនោះទេ ប៉ុន្តែគឺសំរាប់រូបវិទូប្រើប្រាស់កុំព្យូទ័ររួមគ្នា ដើម្បីដោះស្រាយការគណនាស្មុគ្រស្មាញ។ កុំព្យូទ័រនាសម័យនោះជាឧបករណ៍ដែលមានទំហំធំ តំលៃថ្លៃ ដាក់នៅទីតាំងឆ្ងាយដាច់ស្រយ៉ាល។[2] មធ្យោបាយតភ្ជាប់បណ្តាញគឺតាមរយៈការប្រើប្រូតូកូលដែលគេបង្កើតឡើងក្នុងទស្សវត្ស ៦០ ហើយវាមានភាពឯករាជ្យពីបច្ចេកវិទ្យារបស់បណ្តាញ។ បែបនេះវាផ្ទុយទៅនឹងទស្សនៈទូទៅ ដែលគិតថា ដើម្បីបញ្ជូនសារ ពីកន្លែងមួយទៅកន្លែងមួយទៀត គេត្រូវប្រើបរិក្ខានិងបច្ចេកវិទ្យាល្អ។ ផ្ទុយទៅវិញ ប្រូតូកូលនេះអាចបំបែកសារ និងប្រតិបត្តិការកុំព្យូទ័រឲ្យទៅជាកញ្ចប់ជាច្រើន រួចផ្គុំឡើងវិញនៅកន្លែងទទួល។ បើសិនជាសារមិនបានទទួលត្រឹមត្រូវទេនោះ នឹងមានការបញ្ជូនឡើងវិញ។ មធ្យោបាយបែបនេះមានន័យថា បណ្តាញឬខ្សែទំនាក់ទំនងមិនចាំបាច់មាន "ភាពឆ្លាតវៃ" ឡើយ។ អ្វីដែលត្រូវការនោះគ្រាន់តែមាន Router សំរាប់ចង្អុលបង្ហាញទីកន្លែងដែលសារត្រូវបញ្ជូនប៉ុណ្ណោះ បន្ទាប់មកសារនោះនឹងរកផ្លូវដោយខ្លួនឯងឆ្លងកាត់ "បណ្តាញល្ងង់" ។ "ប្រូតូកូលតភ្ជាប់បណ្តាញ" នេះជួយបញ្ជូនសារឆ្លងកាត់បណ្តាញ ផ្សេងៗជាច្រើនមានភាពប្រសើរជាងប្រូតូកូលទូរស័ព្ទ។

ភាពប្រសើរនេះត្រូវបានលើកតំកើនចាប់តាំងពីទស្សវត្សទី ៧០ ដែលពេលនោះក្រុមហ៊ុនទូរស័ព្ទទាំងអស់បានបន្ថែមភាពវៃឆ្លាតទៅក្នុងបណ្តាញពួកគេ។[3] ទោះបី ITU ដែលជាភ្នាក់ងារមួយរបស់ UN បង្កើតឡើងដើម្បីសំរបសំរួលទូរគមនាគមន៍ពិភពលោក បានអភិវឌ្ឍប្រូតូកូល និងស្តង់ដារមួយចំនួន ទស្សនៈខុសគ្នាទាំងអស់នេះបង្កឲ្យមានការប៉ះទង្គិចដែលទីបំផុត ប្រូតូកូលតភ្ជាប់បណ្តាញទទួលបានការគាំទ្រច្រើនជាងប្រូតូកូលរបស់ក្រុមហ៊ុនទូរស័ព្ទ។

---

[2] Katie Hafner and Mathew Lyon, *ទីដែលភាពអស្ចារ្យមានការឃើតយ៉ាវ Where Wizards Stay Up Late: ដើមកំណើតនៃអ៊ីនធឺណែត The Origins of the Internet* (New York: Simon and Schuster, 1998).

[3] David S. Isenberg, "ឱនភាពនៃបណ្តាញល្ងង់" "The Dawn of the Stupid Network," *ACM Networker* 2.1 February/March (1998): 24-31, http://www.isen.com/papers/Dawnstupid.html.

## ប្រវត្តិនៃការអភិបាលប្រព័ន្ធអ៊ីនធឺណែត[4]

គេគួរចងចាំថាប្រូតូកូលនិងស្តង់ដាមានសារៈសំខាន់ណាស់ក្នុងពិភពបច្ចេកវិទ្យា ព្រោះអ្នកណាដែលគ្រប់គ្រងវាទោះជាមិនអាចចាត់ចែង ក៏អាចបញ្ជាទិសនៃការអភិវឌ្ឍន៍បច្ចេកវិទ្យាទាំងមូលបានដែរ។ ចំពោះករណីអ៊ីនធឺណែត ប្រូតូកូលដែលគេបានប្រើដើម្បីតភ្ជាប់បណ្តាញ នាពេលបច្ចុប្បន្ននេះត្រូវបានគេហៅថា ប្រូតូកូលគ្រប់គ្រងការបញ្ជូន/ប្រូតូកូលអ៊ីនធឺណែត (TCP/IP)។ វាត្រូវបានបង្កើតដោយ លោក Vinton G. Cerf និង លោក Bob Kahn ក្នុងឆ្នាំ ១៩៧៤ ព្រមទាំងមានសារៈសំខាន់ជាខ្លាំងចំពោះការប្រតិបត្តិការរបស់បណ្តាញ រហូតដល់ធ្វើឲ្យបណ្តាញទាំងឡាយណាដែលប្រើ TCP/IP ត្រូវបានគេស្គាល់ថាជាប្រព័ន្ធអ៊ីនធឺណែត។

សំរាប់គោលបំណងនៃមេរៀននេះ គោលការណ៍នៃប្រូតូកូលដែលគួរឲ្យចាប់អារម្មណ៍នោះគឺថាគ្មានការគ្រប់គ្រងដោយផ្ទាល់ទៅលើលំហូរនៃព័ត៌មានលើបណ្តាញឡើយ គឺមានតែការគ្រប់គ្រងទៅលើអាស័យដ្ឋានដែលព័ត៌មានត្រូវចែចាយប៉ុណ្ណោះ។ អ្វីដែលសំខាន់នោះគឺត្រូវមាននរណាម្នាក់ រៀបចំធានាមិនឲ្យមានកំហុសក្នុងការកំណត់អាស័យដ្ឋាន។ ប្រព័ន្ធបែងចែកអាស័យដ្ឋានសកលបានប្រើលេខដើម្បីសំគាល់បណ្តាញទាំងអស់។ បុគ្គលឬភ្នាក់ងារណាមួយ ត្រូវមើលការខុសត្រូវមិនឲ្យមាន អាស័យដ្ឋានស្ទួនគ្នា ដែលនេះតំរូវឲ្យមានក្បាលម៉ាស៊ីនសំរាប់លុបបំបាត់ស្ថានភាពនេះ។ ដូច្នេះហើយ បានជាលោក Jon Postel ដែលបានទទួលសញ្ញាប័ត្រទាំងអស់របស់គាត់នៅសកលវិទ្យាល័យ California ក្នុងរដ្ឋ Los Angeles ប៉ុន្តែក្រោយមកទៅធ្វើជានាយកនៃវិទ្យាស្ថានវិទ្យាសាស្ត្រព័ត៌មានរបស់សកលវិទ្យាល័យ Southern California បានក្លាយជា "ព្រះជាម្ចាស់នៃអ៊ីនធឺណែត" ដែលត្រូវបានដាក់ឈ្មោះដោយអ្នកសេដ្ឋកិច្ច។ គាត់ជាអ្នកដោះស្រាយបញ្ហាទាំងនេះទើបធ្វើឲ្យបណ្តាញអាចលូតលាស់បាន។

ពេលចំនួនបណ្តាញកាន់តែកើនឡើង នោះតួលេខទាំងអស់កាន់តែពិបាកចងចាំ។ ដូច្នេះក្នុងឆ្នាំ ១៩៨៣ លោក Postel និងលោក Paul Mockapetris បានស្នើឲ្យមានការប្រើឈ្មោះភ្ជាប់ជាមួយនឹងលេខទាំងនោះ។ ឧទាហរណ៍ ការប្រើ google.com ជំនួស ៦៤.២៣៣.១៦១.១៨ ដើម្បីទៅរកក្បាលម៉ាស៊ីនស្វែងរក

[4] សៀវភៅណាមួយដែលនិយាយពីប្រវត្តិអ៊ីនធឺណែតគឺជាប្រភពដ៏ល្អ ដូចជាសៀវភៅរបស់ Hafner and Lyon "*ទីដែលភាពអស្ចារ្យមានការយឺតយ៉ាវ*" និងសៀវភៅ "*អ្នកណានឹងគ្រប់គ្រងអ៊ីនធឺណែត៖ ការមានអារម្មណ៍ដឹងពីពិភពលោកគ្មានព្រំដែន*" ម្យ៉ាងទៀតសូមអានឯកសារប្រវត្តិអ៊ីនធឺណែតនៅលើបណ្តាញរបស់សង្គមអ៊ីនធឺណែត *Where Wizards Stay Up Late*, and Jack Goldsmith and Tim Wu's *Who Controls the Internet: Illusions of a Borderless World*. The Internet Society's *Histories of the Internet* at http://www.isoc.org/internet/history.

ដែលដូចគ្នាទៅនឹងការដាក់ឈ្មោះនៅក្នុងប្រព័ន្ធកត់ត្រាលេខទំនាក់ទំនងរបស់ទូរស័ព្ទ។ នេះ ជាកំណើតរបស់ប្រព័ន្ធផ្តល់ឈ្មោះដូម៉េន (DNS)។

ការប្រើ DNS បង្កឲ្យមានបញ្ហាផ្លូវច្បាប់មួយចំនួន ដែលយើងនឹងលើកយកមកបង្ហាញក្នុងផ្នែកក្រោយ។ សំរាប់ពេលនេះយើងត្រូវយល់អំពី DNS ដើម្បីយល់ពីបញ្ហារបស់វា។[5]

DNS គឺជាប្រព័ន្ធដែលមានឋានានុក្រមដូចទំរង់ទ្រី (tree) ដើម្បីរៀបចំព័ត៌មានអំពីរាល់បណ្តាបណ្តាញ និងកុំព្យូទ័រ។ វាដូចគ្នាទៅនឹងអាស័យដ្ឋានប្រៃសនីយ៍ដែរ៖ ដោយគ្រាន់តែដាក់អាស័យដ្ឋានផ្លូវនៅខាងដើមនិងឈ្មោះប្រទេសនៅខាងចុង។ បើដូច្នេះដូម៉េនមេ (TDL) គឺនៅខាងចុងបំផុត រីឯអាស័យដ្ឋានច្បាស់លាស់ជាងនៅខាងដើម។ អញ្ចឹងហើយបានជាពេលកុំព្យូទ័រស្វែងរកអាស័យដ្ឋានណាមួយក្នុងប្រព័ន្ធអ៊ីនធឺណែត វាត្រូវអានពីស្តាំទៅឆ្វេង ដោយសួរ Server និមួយៗរហូតឃើញទីតាំងពិតប្រាកដ។

មាន TDL ចំនួន ៦ ដែលត្រូវបានគេប្រើដំបូងបំផុតក្នុងឆ្នាំ ១៩៨៤ មាន៖

- COM សំរាប់ក្រុមហ៊ុនពាណិជ្ជកម្ម
- EDU សំរាប់ស្ថាប័នអប់រំ
- NET សំរាប់អ្នកផ្គត់ផ្គង់បណ្តាញ
- ORG សំរាប់អង្គការមិនគិតប្រាក់ចំណេញ
- MIL សំរាប់កងទ័ពអាមេរិច
- GOV សំរាប់រដ្ឋាភិបាលអាមេរិច[6]

ចាប់តាំងពីពេលនោះមក ដូម៉េនបង្គោលបញ្ជាក់ប្រភពកាន់តែច្បាស់ (gTLDs) ក៏ត្រូវបានគេបន្ថែមជាច្រើនទៀត។[7] លេខកូដ TDL ទាំងនេះមានលក្ខណៈប្រហាក់ប្រហែលនឹង អក្សរ ២តួនៃ ISO 3166-1

[5] សូមមើល http://en.wikipedia.org/wiki/Domain_name_system សំរាប់ព័ត៌មានបន្ថែមអំពី DNS.

[6] សូមមើល http://en.wikipedia.org/wiki/Generic_top-level_domain សំរាប់ព័ត៌មានបន្ថែមអំពីប្រព័ន្ធ TLD.

[7] សំរាប់បញ្ជីច្បាស់លាស់ សូមមើល http://data.iana.org/TLD/tlds-alpha-by-domain.txt. បញ្ជីដែលកាន់តែងាយយល់មាននៅ http://en.wikipedia.org/wiki/List_of_Internet_top-level_domains.

សំរាប់សំគាល់ប្រទេសនិងដែនដី ដែលគេប្រើក្នុងពាណិជ្ជកម្មអន្តរជាតិ។[8] សហរដ្ឋអាមេរិចមាន ccTLD ដែលមានអក្សរពីរតួ (US)។ តែដោយសារតែខ្លួនជានាំមុខ និងចាប់ផ្តើមមុនគេ អាមេរិចមិនចាំបាច់ប្រើលេខកូដសំគាល់ ដូចប្រទេសដទៃទេឡើយ ដូចនេះ COM ត្រូវបានប្រើសំគាល់ប្រភពចេញពីអាមេរិច ដើម្បីបង្ហាញភាពអស្ចារ្យរបស់ខ្លួន។

វត្តមាន ccTLD មានន័យថារដ្ឋាភិបាលទាំងអស់មានសំឡេង ដូចដែលការផ្តល់ឲ្យនូវ ccTLD រៀងៗ ខ្លួន។ ជាឧទាហរណ៍ yahoo.fr ទទួលច្បាប់ និងគោលនយោបាយផ្សេងៗដែលបានកំណត់ដោយ ប្រទេសបារាំង ដូចជាករណីដែលតុលាការប្រទេសបារាំងបានចេញសាលក្រមមិនឲ្យ Yahoo បង្ហាញពីគេហទំព័រ និយាយពីកេរ្តិ៍ដំណែលរបស់របបណាស៊ី ទៅដល់ទស្សនិកជនបារាំងឡើយ។ តុលាការបារាំងអាចធ្វើដូច្នេះដោយសារដូម៉ែនឈ្មោះ yahoo.fr បានចុះបញ្ជីក្នុងប្រទេសបារាំង។ នាពេលក្រោយមក Yahoo បានប្តូរដូម៉ែនជាភាសាបារាំងនេះទៅជា fr.yahoo.com ដែលមានកន្ទុយជា com នៅលើ Server ឈ្មោះ FR។ ការធ្វើដូចនេះអាចឲ្យ Yahoo មានសិទ្ធតទល់ជាមួយតុលាការបារាំង បើទោះជាទង្វើនេះមិនមានប្រយោជន៍ពាណិជ្ជកម្មក៏ដោយ។ Yahoo បានប្តូរាល់អាស័យដ្ឋានគេហទំព័រជាភាសាផ្សេងៗរបស់ខ្លួន មកបញ្ចប់ដោយ com វិញ។
មានបញ្ហាបច្ចេកទេសមួយដែលនឹងលើកមកពិភាក្សា ដែលទាក់ទងនឹង Server មេ។ នៅពេលកុំព្យូទ័រស្វែងរកអាស័យដ្ឋាន វាអានពីស្តាំទៅឆ្វេង។ ដោយសារតែ gTLD ស្ថិតនៅខាងស្តាំ កុំព្យូទ័រត្រូវដំណើរការពីខាងស្តាំបំផុត ដូច្នេះសំរាប់ www.google.com កុំព្យូទ័រនឹងស្វែងរក .com។ រាល់ឈ្មោះដូម៉ែនអ៊ីនធឺណែតទាំងអស់ត្រូវបញ្ចប់ដោយ dot "." សំរាប់សំគាល់ server មេ។ មានស្ថាប័នទាំងអស់ចំនួន ១២ ដែលមានឈ្មោះថា អ្នកប្រត្តិការ server មេទាំងអស់។ Server ទាំងនោះមានអក្សរសំគាល់ពី A ដល់ M។ Server A គឺជាអ្នកនាំមុខគេ ហើយធ្វើការទាក់ទងជាមួយ server មេដទៃទៀត ម្តងម្កាលក្នុង មួយថ្ងៃៗ។ ព័ត៌មានទាំងអស់លើប្រព័ន្ធអ៊ីនធឺណែតត្រូវផ្ទុកលើ server ជាច្រើនពាសពេញពិភពលោក ដើម្បីបង្កើនល្បឿនរបស់អ៊ីនធឺណែត។ ដែននៃ server ទាំងនេះមានឈ្មោះថា Root Zone។[9] ដោយសារ Root Zone ជាគ្រោងឆ្អឹងសំខាន់បំផុតក្នុងប្រព័ន្ធអ៊ីនធឺណែត គេបានបន្ថែម server បង្កប់មួយទៀតបិទបាំងមិនឲ្យ hacker ដឹងឡើយ។

[8] សូមមើល http://en.wikipedia.org/wiki/ISO_3166-1_alpha-2 for more details about ISO 3166-1 alpha-2.

[9] Wolfgang Kleinwächter, "ការទំលាយអាថ៌កំបាំងនៃឫសគល់របស់អ៊ីនធឺណែត៖ តើយើងត្រូវការការត្រួតពិនិត្យដោយរដ្ឋាភិបាលឬទេ?" នៅក្នុងសៀវភៅកំណែទំរង់ការអភិបាលអ៊ីនធឺណែត" De-Mystification of The Internet Root: Do We Need Governmental Oversight?" in *Reforming Internet Governance*, ed. William J. Drake (New York: UN ICT Task Force, 2005), 209-225, http://www.wgig.org/docs/book/WGIG_book.pdf.




Server បង្កប់ និង server A មានទីតាំងនៅអាមេរិច ដែលចោទជាសំនួរមួយថា តើនឹងមានអ្វីកើតឡើងចំពោះអ៊ីនធឺណែតក្នុងប្រទេសមួយ បើប្រទេសនោះ មានសង្គ្រាមជាមួយអាមេរិច។ ជាឧទាហរណ៍ តើរដ្ឋាភិបាលអាមេរិចអាចលុបប្រទេសនោះចេញពី ទិន្នន័យក្នុង Root Zone ឬយ៉ាងណា ?

មុនសង្គ្រាមជាមួយប្រទេសអ៊ីរ៉ាក់ ដូម៉េន IQ បានរលាយបាត់ចេញពីប្រព័ន្ធអ៊ីនធឺណែត។ ដូម៉េន IQ មិនត្រូវបានដំណើរការដោយអង្គភាពណាមួយរបស់ Saddam Hussein ឡើយ តែដូម៉េននេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ជនជាតិអារ៉ាប់ប៉ាលេស្ទីន រស់នៅក្នុងរដ្ឋតិចសាស់។ អ្នកដំណើរការដូម៉េននេះគឺជាបងប្អូនត្រកូល Elashi និងដៃគូរជំនួញរបស់ខ្លួន ដែលពួកគេត្រូវបានចាប់ខ្លួនពីបទនាំចេញសំភារៈកុំព្យូទ័រខុសច្បាប់ទៅកាន់ប្រទេស Libya និង Syria ក្នុងឆ្នាំ ២០០២។ មិនដឹងជាការចៃដន្យឬយ៉ាងណា ឡើយ ដែលដូម៉េន IQ ត្រូវបានបិទចំពេលមុនសង្គ្រាមតែម្តង។ នៅថ្ងៃ ២៨ កក្កដា ២០០៥ ចន្លោះពេលដែលរបាយការណ៍របស់ក្រុមគ្រប់គ្រងប្រព័ន្ធអ៊ីនធឺណែតតែងតាំងដោយ UN បានបញ្ចប់ និងមុនពេល

ដែលរបាយការណ៍នេះបោះពុម្ពជាភាសាផ្លូវការផ្សេងៗរបស់ UN ដូម៉េន IQ ត្រូវបានប្រគល់ទៅឲ្យរដ្ឋាភិបាលអ៊ីរ៉ាក់ ដោយមូលហេតុពេលនោះ ប្រទេសអ៊ីរ៉ាក់មានរដ្ឋាភិបាលមានដំណើរការនិងស្ថិរភាពហើយនោះ។

ការគ្រប់គ្រងលើ Root Zone ត្រូវបានគេចាត់ទុកជាចំនុចគន្លឹះក្នុងការគ្រប់គ្រងប្រព័ន្ធអ៊ីនធឺណែត ក្រៅពីនេះក៏មានកង្វល់ដទៃទៀតផងដែរ។ ប្រទេសមួយចំនួនមានការបារម្ភអំពីការបែងចែក IP address។ ដោយសារតែការអភិវឌ្ឍន៍អ៊ីនធឺណែតតាមវិធីដែលគ្មានសណ្តាប់ធ្នាប់ និង មិនបានគ្រោងទុក ធ្វើឲ្យសកលវិទ្យាល័យសហរដ្ឋអាមេរិចខ្លះមាន IP address ច្រើនជាងបណ្តាប្រទេសមួយចំនួនទៅទៀត។ បញ្ហាមិនត្រឹមតែពាក់ព័ន្ធនឹងការបែងចែកនេះទេ គឺថែមទាំងទៅលើកង្វល់ដោយសារចំនួនសរុបនៃ IP address ទាំងនោះមានកំណត់។ តាមរយៈការប្រើប្រព័ន្ធប្រូតូកូលអ៊ីនធឺណែតវគ្គ៤ (IPv4) ដែលកំពុងប្រើសព្វថ្ងៃ មាន IP address ចំនួន ៤,២៩៤,៩៦៧,២៩៦ ខុសៗគ្នា។ ដោយសារតែប្រជាជនពិភពលោកមានចំនួនច្រើនជាងធំជាងនេះឆ្ងាយ IP address នឹងត្រូវប្រើអស់។ បញ្ហានេះអាចលុបបំបាត់បានដោយការប្រើដែលមានការសន្សំសំចៃ និងការដាក់ឲ្យប្រើប្រាស់ ប្រូតូកូលវគ្គទី៦ (IPv6) ដែលមាន IP address រហូតដល់ ៣៤០,២៨២,៣៦៦,៩២០,៩៣៨,៤៦៣,៣៧៤,៦០៧,៤៣២,៧៦៨,២១១,៤៥៦។[10]

ចំណោទនៃការអភិបាលអ៊ីនធឺណែតបានត្រូវគេលើកឡើងក្នុងឆ្នាំ ២០០៣ នៅប្រជុំពេញអង្គពិភពលោកស្តីពីសង្គមព័ត៌មានវិទ្យា (WSIS)។ ខណៈពេលនោះប្រទេសជាច្រើនចង់ដោះស្រាយបញ្ហាគ្រប់គ្រងនេះ ចំណែកសហរដ្ឋអាមេរិចមានទស្សនៈថាប្រទេសកំពុងអភិវឌ្ឍន៍មិនមានសមត្ថភាពគ្រប់គ្រាន់ឡើយ។ ដូចនេះហើយបានជាគេសំរេចចិត្តឲ្យមានក្រុមការងារមួយតែងតាំងដោយអគ្គរដ្ឋលេខាធិការ UN ដើម្បីរាយការណ៍លើបញ្ហានោះ។ ការប្រកាសពីគោលនយោបាយរបស់ WSIS មាន៖

> ៥០. បញ្ហាអភិបាលអ៊ីនធឺណែតអន្តរជាតិ គួរដោះស្រាយដោយមានការសំរបសំរួល ។ យើងស្នើសុំអគ្គលេខាធិការអង្គការសហប្រជាជាតិ រៀបចំបង្កើតក្រុមការងារគ្រប់គ្រងអ៊ីនធឺណែតក្នុងបរិយាកាសបើកចំហរ និងរួមគ្នាដើម្បីឲ្យមានការចូលរួមពេញលេញយ៉ាង

[10] OECD, "រដ្ឋាភិបាលនិងក្រុមហ៊ុនជំនួញត្រូវដោះស្រាយការខ្វះខាតអាស័យដ្ឋានក្នុងប្រព័ន្ធអ៊ីនធឺណែតជាមួយគ្នា ថ្លែងដោយ OECD" "Governments and business must tackle Internet address shortage together, says OECD," 15 May 2008, http://www.oecd.org/document/29/0,3343,en_2649_34223_40542045_1_1_1_1,00.html.

សកម្មពីបណ្ដារដ្ឋាភិបាល ផ្នែកឯកជននិងសង្គមស៊ីវិល មកពីប្រទេសអភិវឌ្ឍន៍និងកំពុងអភិវឌ្ឍន៍ ដោយរួមទាំងអង្គការចំរុះរដ្ឋាភិបាល និងអន្តរជាតិ ព្រមទាំងវេទិការផ្សេងៗ។ ក្រុមការងារនេះត្រូវស៊ើបអង្កេត និងលើកសំណើធ្វើសកម្មភាពតាមការគួរលើការអភិបាលអ៊ីនធឺណែតឲ្យបានមុនឆ្នាំ ២០០៥។[11]

គណកម្មាធិការនេះត្រូវបានគេឲ្យឈ្មោះថា WGIG រួមមានសមាជិកចំនួន ៤០នាក់ មានតួនាទីស្វែងរកព័ត៌មានដូចជា៖ កំណត់ថាការងារគ្រប់គ្រងនេះយ៉ាងដូចម្ដេចខ្លះ មានបញ្ហាអ្វីខ្លះ និងនរណាត្រូវ ធ្វើអ្វីខ្លះ។ យើង នឹងសិក្សារបាយការណ៍របស់ WGIG នៅផ្នែកបន្ទាប់។

### សំនួរពិចារណា

តើការអភិបាលប្រព័ន្ធអ៊ីនធឺណែត មានសារៈសំខាន់យ៉ាងណា ចំពោះប្រទេសអ្នក?

### សាកល្បងខ្លួនឯង

១.ហេតុអ្វីអ៊ីនធឺណែតត្រូវបានបង្កើតឡើង?

២.គេនិយាយជាញឹកញាប់ថាអ៊ីនធឺណែតគ្មាន □ចំនុចកណ្ដាល□ ទេ។ តើពិតឬទេ?

៣.តើ DNS រៀបចំអ៊ីនធឺណែតយ៉ាងដូម្ដេច?

៤.តើ IP address និង ឈ្មោះដូម៉េន (domain name) ខុសគ្នាត្រង់ណា?

៥.តើអ្វីជាភាពខុសគ្នាជាក់ស្ដែងរវាង IPv4 និង IPv6?

[11] កិច្ចប្រជុំកំពូលពិភពលោកស្ដីពីសង្គមព័ត៌មានវិទ្យា *សេចក្ដីប្រកាសអំពីគោលនយោបាយក្នុងការកសាងសង្គមព័ត៌មានវិទ្យា៖ កិច្ចប្រឹងប្រែងជាសកលក្នុងសហស្សវត្សថ្មី* World Summit on the Information Society, *Declaration of Principles – Building the Information Society: A global challenge in the new Millennium* (12 December 2003), http://www.itu.int/wsis/docs/geneva/official/dop.html.

# ២.ពហុភាគី និង ពហុទស្សនៃ ការអភិបាលប្រព័ន្ធអ៊ីនធឺណែត

ផ្នែកនេះមានគោលបំណងបង្ហាញត្រួសៗអំពីរបាយការណ៍របស់ WGIG ដែលមានចំណាងជើងថា ភាពតានតឹងនយោបាយជុំវិញភាពចំរូងចំរាស់បំផុតនៃការអភិបាលប្រព័ន្ធអ៊ីនធឺណែត ព្រមទាំងការកកើតឡើងនៃវេទិកាអភិបាលអ៊ីនធឺណែត។

កង្វល់ដ៏សមស្របមួយក្នុងការងារអភិបាលអ៊ីនធឺណែតនោះ គឺថាការផ្តល់អនុសាសន៍ទាំងឡាយមិនត្រូវបង្អាក់ដំណើរការប្រព្រឹត្តទៅរបស់ប្រព័ន្ធអ៊ីនធឺណែតឡើយ។ ដូច្នេះ WGIG បានប្រកាន់យកគោលការណ៍ណែនាំមួយចំនួនសំរាប់បំពេញការងាររបស់ខ្លួន ដូចជាអ៊ីនធឺណែតគួរតែបន្តឲ្យមាន ស្ថេរភាព និងសន្តិសុខ ម៉្យាងទៀតស្ថាបត្យកម្មនិងការអភិវឌ្ឍន៍ស្តង់ដាផ្សេងៗនៅតែបន្តបើកចំហរតាមបែបពហុបក្ស ព្រមទាំងការងារគ្រប់គ្រងឈ្មោះដូម៉ែន និងលេខត្រូវបន្តប្រកបដោយប្រសិទ្ធភាពខ្ពស់។

## ២.១ និយមន័យ

និយមន័យនៃការអភិបាលអ៊ីនធឺណែតបានចាប់ផ្តើមជាមួយនឹងភាពមិនចុះសម្រុងគ្នាមួយចំនួន។ ក្នុងសេចក្តីថ្លែងការណ៍របស់ខ្លួនទៅកាន់ WGIG លោក Yoshio Utsumi ដែលជាអគ្គលេខាធិការ ITU និងកាន់តួនាទីជាអគ្គលេខាធិការនៃ WSIS ចង់បាននូវនិយមន័យជាក់លាក់នៃការអភិបាលអ៊ីនធឺណែត។ លោកបាននិយាយថា៖

> បញ្ហាជាច្រើនដែលស្ថិតក្នុងបរិបទនយោបាយនៃ "ការអភិបាលអ៊ីនធឺណែត" ត្រូវបានលើកយកមកពិភាក្សាយ៉ាងផុសផុលរួចមកហើយក្នុងដំណាក់កាលទី១ នៃ WSIS ព្រមទាំងបានកត់ត្រាទុកគោលការណ៍ និងផែនការសកម្មភាពដែលបានព្រមព្រៀងគ្នា ទៅក្នុងឯកសារចុងក្រោយនៃដំណាក់នេះ។ មានការឯកភាពគ្នាយ៉ាងទូលំទូលាយរវាងបណ្តារដ្ឋាភិបាល ដូចដែលមានក្នុងកំណត់ត្រាថានឹងមិនមានការលើកឡើងសារជាថ្មីពីបញ្ហាទាំងនេះទៀតឡើយ។ ដូចនេះមិនចាំបាច់ពិភាក្សាបញ្ហាមួយចំនួនដូចជា លំហូរព័ត៌មានដោយសេរី ការពើបប្រទះនឹង spam សន្តិសុខបណ្តាញ server មេប្រចាំតំបន់ ការការពារភាពជាឯកជនឬការប្រើ ICT ក្នុងផ្លូវមិនល្អឡើយ។

ជំនួសមកវិញ យើងគួរផ្តោតទៅលើសកម្មភាពស្នូលនៃការគ្រប់គ្រង ធនធានអ៊ីនធឺណែតរបស់ ICANN (សាជីវកម្មអ៊ីនធឺណែតសំរាប់ផ្តល់ឈ្មោះដូម៉េននិងលេខ) ដូចជា ដូម៉េនបង្គោល ដែលមានបញ្ហាមួយក្នុងចំណោមបញ្ហាសំខាន់ៗជាច្រើនមិនទាន់បាន ដោះស្រាយ។[12]

ក្រុមការងារមិនបានទទួលយកនូវនិយមន័យជាក់លាក់នោះទេ ប៉ុន្តែបែជាប្រកាន់យកនិយមន័យទូលំទូលាយនៃការអភិបាលអ៊ីនធឺណែត៖

ការងារអភិបាលអ៊ីនធឺណែតគឺជាការអភិវឌ្ឍន៍ និងការអនុវត្តធ្វើឡើងដោយបណ្តារដ្ឋាភិបាល ផ្នែកឯកជននិងសង្គមស៊ីវិល ទៅតាមតួនាទីរៀងៗខ្លួន ដោយមានភាពរួមគ្នាតែមួយ នៃ គោលការណ៍ ស្តង់ដា ច្បាប់ទំលាប់ នីតិវិធីសំរេចចិត្ត និងកម្មវិធីផ្សេងៗ ដែលរចនាការវិវត្តន៍ និងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណែត[13]។

និយមន័យនេះមានលក្ខណៈខ្លី និងចំៗ បើប្រៀបធៀបជាមួយនិយមន័យផ្សេងៗទៀត[14]។ វាមានសារៈសំខាន់ដោយសារមូលហេតុមួយចំនួន ។ ទី១ និយមន័យនេះ បានច្រានចោល នូវទស្សនៈតូចចង្អៀតអំពីការអភិបាលអ៊ីនធឺណែត ដែល ITU គិតថា ICANN មានមុខងារដូចអ្វីដែល ITU ខ្លួនឯងកំពុងធ្វើ។ ទី២ និយមន័យនេះរួមបញ្ចូលទាំងបញ្ហា spam ភាពជាឯកជន បទឧក្រិដ្ឋក្នុងបណ្តាញអ៊ីនធឺណែត សន្តិសុខ និងការអភិវឌ្ឍន៍វិស័យអ៊ីនធឺណែត ដែលបញ្ហាទាំងនេះមិនសូវលើកយកមកពិភាក្សាដោយ ITU។ ទី៣ វាគ្របដណ្តប់លើអ្នកពាក់ព័ន្ធជាច្រើនដូចជាផ្នែកឯកជន និងសង្គមស៊ីវិល ដែល ITU មិនអាចធ្វើបានក្នុងអង្គប្រជុំ ដោយសារសមាជិករបស់ ITU មានក្រុមហ៊ុនទូរស័ព្ទដែលក្នុងប្រទេសភាគច្រើន ក្រុមហ៊ុនទាំងនោះមានទំនាក់ទំនងពាណិជ្ជកម្មជាមួយរដ្ឋាភិបាល។ និយមន័យនេះក៏បានបង្កប់អត្ថន័យថា ការអភិបាលអ៊ីនធឺណែតមិនមែនគ្រាន់តែជាការអនុវត្តដែលច្បាប់អនុម័តដោយរដ្ឋាភិបាលឡើយ ប៉ុន្តែគឺវាទាក់ទងទៅនឹងក្រឹតក្រម និងច្បាប់ទំលាប់សង្គម ដែលបង្កើតដោយសហគមន៍អ៊ីនធឺណែតខ្លួនឯង ដែលនេះបានផ្តល់ភាពសំខាន់ដល់សង្គមស៊ីវិល ដែលដើរតួនាទីមួយក្នុងការអភិវឌ្ឍន៍វិស័យអ៊ីនធឺណែត។

និយមន័យនេះមានបញ្ចូលពាក្យពេជន៍មួយចំនួនដែលមានក្នុងសេចក្តីប្រកាសរបស់ WSIS ដោយបង្កប់ន័យថា ដំណើរការអភិបាលអ៊ីនធឺណែត គួរតែមានអ្នកចូលរួមពាក់ព័ន្ធច្រើន (រួមបញ្ចូលទាំង រដ្ឋាភិបាល ផ្នែកឯកជន និងផ្នែកសាធារណៈ) ពហុភាគី (រួមមាន ប្រទេសជាច្រើន) ព្រមទាំងមាន តម្លាភាពនិង

[12] លោក Yoshio, Utsumi, សុន្ទរកថាស្វាគមន៍ (កិច្ចប្រជុំលើកទី១ របស់ក្រុមការងារអភិបាលអ៊ីនធឺណែត នាទីក្រុង Switzerland, 23-25 November 2004), http://www.wgig.org/docs/Utsumi.pdf.

[13] WGIG, *របាយការណ៍របស់ក្រុមការងារអភិបាលអ៊ីនធឺណែតឆ្នាំ ២០០៥ Report of the Working Group on Internet Governance* (2005), 4, http://www.wgig.org.

[14] WGIG, *របាយការណ៍អំពីប្រវត្តិ Background Report* (2005), http://www.wgig.org.

ប្រជាធិបតេយ្យ (គោរពតាមទស្សនៈភាគច្រើន)។ វាសង្កត់ធ្ងន់ទៅលើដំណើរប្រព្រឹត្តទៅនៃការអភិបាលអ៊ីនធឺណែត។

**រូបភាពទី២ ពហុភាគី និង ពហុវិស័យនៃការអភិបាលប្រព័ន្ធអ៊ីនធឺណែត**



## ២.២ អនុសាសន៍

ក្រុមការងារក៏បានផ្តល់នូវអនុសាសន៍មួយចំនួន។ អនុសាសន៍ទី១ គឺឲ្យមានវេទិកាមួយសំរាប់អ្នកពាក់ព័ន្ធទាំងអស់ចូលរួមបង្ហាញពីបញ្ហាទាំងឡាយទាក់ទងនឹងអ៊ីនធឺណែត។ វេទិកានេះមិនចាំបាច់មានរចនាសម្ព័នសាំញ៉ាំទេ ហើយក៏គ្មានអំណាចក្នុងការសំរេចដែរ។ វាមានគោលបំណងគ្រាន់តែជាកន្លែងដែលអ្នកពាក់ព័ន្ធទាំងអស់ ពិភាក្សាបញ្ហា និងចែករំលែកមេរៀនល្អៗ។ វេទិកាគ្រប់គ្រងអ៊ីនធឺណែតទីមួយ បានជួបជុំគ្នានៅទីក្រុង Athens ក្នុងឆ្នាំ ២០០៦។ វេទិកាទី២នៅក្នុងទីក្រុង Rio de Janeiro នៃប្រទេស Brazil និងវេទិកាទី៣នឹងត្រូវធ្វើឡើងក្នុងឆ្នាំ ២០០៨ ក្នុងទីក្រុង Hyderabad នៃ ប្រទេសឥណ្ឌា។

អនុសាសន៍ទី២របស់ WGIG គឺទាក់ទងនឹងការត្រួតពិនិត្យប្រព័ន្ធអ៊ីនធឺណែត។ ក្រុមការងារនេះ ក៏ផ្តល់អនុសាសន៍ឲ្យមានការត្រួតពិនិត្យជាអន្តរជាតិ ដោយផ្អែកលើគោលការណ៍របស់ WSIS ដែលថាគួរមានការចូលរួមពីសំនាក់ អ្នកពាក់ព័ន្ធ ពហុភាគី តម្លាភាពនិងប្រជាធិបតេយ្យ។ ដោយសង្កេតឃើញថាការត្រួតពិនិត្យបែបនេះមិនត្រូវធ្វើឲ្យមានភាពរអាក់រអួលដល់ដំណើរការប្រចាំថ្ងៃរបស់អ៊ីនធឺណែតនោះ

ក្រុមការងារបានណែនាំដោយប្រយោលថា រដ្ឋាភិបាលអាមេរិចគួរលះបង់សមត្ថកិច្ចដែលខ្លួនមានតែម្នាក់ឯងក្នុង ICANN។

ទោះបីរបាយការណ៍របស់ WGIG រកឃើញថា ICANN ជាភ្នាក់ងារអន្តរជាតិមានតម្លាភាពជាងគេបំផុតទាក់ទងនឹងអ៊ីនធឺណែត បញ្ហាមួយចំនួនក៏ត្រូវបានឆ្លុះបញ្ចាំងផងដែរ។ បញ្ហាទី១ គឺថា ICANN មិនមានកាលវិភាគច្បាស់លាស់ថាតើពេលណាខ្លះ gTLD ត្រូវគេបង្កើត។ កាលវិភាគបែបនេះមានសារៈប្រយោជន៍សំរាប់អ្នកស្នើបង្កើត gTLD និងអ្នកដែលមានយោបល់លើ gTLD ដែលកំពុងត្រូវបានគេស្នើ។ បញ្ហាទី២ គេបានរកឃើញថា ផ្នែកដែលមិនសូវមានតម្លាភាពនោះគឺ គណកម្មាធិការប្រឹក្សារដ្ឋាភិបាល ដែលជាវេទិកាសំរាប់រដ្ឋាភិបាលទាំងអស់ផ្តល់មតិរបស់ខ្លួន។ បញ្ហាលើការគ្រប់គ្រងធំៗនោះគឺ៖ ទី១ ICANN គឺជាក្រុមហ៊ុនអាមេរិចដែលបង្កើតកុងត្រាដោយខ្លួនឯង មិនមែនដោយសារខ្លួនបានបង្កើតស្នាដៃល្អៗឡើយ។ ទី២ ICANN ស្ថិតនៅក្រោមក្រសួងពាណិជ្ជកម្មអាមេរិច ដោយមានការចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាពីភាគីទាំងពីរ។

រដ្ឋាភិបាលអាមេរិចបានផ្តល់មូលហេតុពីរយ៉ាង ដែលខ្លួនត្រូវបន្តការគ្រប់គ្រង ICANN៖ (១) ដើម្បីធានាស្ថេរភាព និងសន្តិសុខប្រព័ន្ធអ៊ីនធឺណែត និង (២) ដើម្បីជៀសវៀងការត្រួតពិនិត្យប្រព័ន្ធអ៊ីនធឺណែតដោយរដ្ឋាភិបាលដទៃទៀត[15]។ មូលហេតុទាំងពីរនេះធ្វើឲ្យមានទស្សនៈផ្សេងៗជាច្រើន។ មូលហេតុ ទី១ ចង់បង្ហាញថាជំនាញបច្ចេកទេស ដើម្បីដំណើរការប្រព័ន្ធអ៊ីនធឺណែតមិនអាចស្វែងរកបានក្រៅពីប្រទេសអាមេរិចឡើយ។ មូលហេតុទី២ គឺសំរាប់ប្រឆាំងនឹងការកកើតនៃដូម៉ែន XXX ដែលប្រើសំរាប់គេហទំព័រអាសអាភាសន៍។ ទោះបីនេះជាការសំរេចចិត្តរបស់ ICANN ដែលជាក្រុមហ៊ុនឯកជនក៏ដោយដំណើរការឡាំងឡាយត្រូវបានគេដឹងថាជាគំនិតផ្តួចផ្តើមរបស់ក្រុមចែចូវអាមេរិច និងគាំទ្រដោយរដ្ឋាភិបាលអាមេរិច[16]។

ប៉ុន្តែចុះបើសិនជាសហរដ្ឋអាមេរិចបង្ហាញឫកពារហាក់ដូចអ៊ីនធឺណែតជាកម្មសិទ្ធរបស់ខ្លួន? នោះគេប្រហែលជាបែរទៅពិចារណាលើបច្ចេកវិទ្យាពីរទៀតដែលមានលក្ខណៈស្រដៀងគ្នា។ ទី១ គឺជា GPS ដែលប្រើសំរាប់គ្រប់គ្រងកម្លាំងយោធានិងត្រូវបានប្រើតាមបែបស៊ីវិលផងដែរនោះ។ បណ្តាប្រទេសអ៊ឺរ៉ុប

---

15 ជាឧទាហរណ៍ សូមមើលលិខិតរបស់សមាជិកសភាលោក Edward Markey ដែលជាប្រធានអនុកម្មាធិការនៃទូរគមនាគមន៍និងអ៊ីនធឺណែត នៅក្នុងអត្ថបទ “Markey, យោបល់របស់សមាជិកសភាអំពីបំរែបំរួលដែលអាចមានទៅលើទីភ្នាក់ងារឃ្លាំមើលអ៊ីនធឺណែត “Markey, Committee Members Comment on Possible Changes to Internet Watchdog Agency,” ការិយាល័យសមាជិកសភារបស់លោក Markey (6 May 2008), http://markey.house.gov/index.php?option=content&task=view&id=3342&Itemid=125.

16 លោក Milton Mueller, “ជុំរូប xxx បានផ្គុំបញ្ចូលគ្នា៖ រូបភាពនោះអាក្រក់ណាស់” “XXX Puzzle Pieces Start to Come Together: And the Picture is Ugly,” *CircleID*, 17 August 2005, http://www.circleid.com/posts/xxx_puzzle_pieces_start_to_come_together_and_the_picture_is_ugly.

បានបង្កើតប្រព័ន្ធដូចគ្នានេះដែរឈ្មោះថា Galileo ដើម្បីធានាថាសេវាកម្មប្រាប់ទីតាំងនៅតែមាន បើទោះជាអាមេរិចកាត់ផ្តាច់ប្រព័ន្ធ GPS ក៏ដោយ[17]។ ទី២ គឺជាបច្ចេកវិទ្យាដែលអាមេរិចកាន់កាប់ភាគ ច្រើន ដែលមានឈ្មោះថាកម្មវិធីរួបរួមអ្នកប្រយុទ្ធជាមុខ (Joint Strike Fighter Program) ដែលមាន ១០ប្រទេសចូលរួម និងប្រើអស់ដើមទុនចំនួន ៤០ កោដិដុល្លារអាមេរិច ដែលក្នុងនោះប្រទេស ជាដៃគូចំណាយទុន ៤ កោដិដុល្លារ។ កូដសំរាប់បង្កើតកម្មវិធីកុំព្យូទ័រសំរាប់ឱ្យយន្តហោះដំណើរការ ក៏ស្ថិតនៅក្នុងដៃសហរដ្ឋអាមេរិច។ ពីដំបូងមានការប្រឆាំងជំទាស់មិនឲ្យបែងចែកកូដនេះ សូម្បីតែជាមួយ ចក្រភពអង់គ្លេស (UK) ដែលជាប្រទេសបានចូលហ៊ុនសំរាប់បង្កើតកម្មវិធីនេះចំនួន ២.៥ កោដិដុល្លារ ដែរនោះ ដែលជាចំនួនច្រើនជាងគេក្នុងចំណោមប្រទេសដៃគូទាំងអស់។ បន្ទាប់ពីអង់គ្លេសគំរាមដកខ្លួន ចេញពីគំរោងនេះ និងបោះបង់គំរោងទិញយន្តហោះចំនួន ១៥០ គ្រឿងនោះ រដ្ឋាភិបាលអាមេរិចបាន ចុះហត្ថលេខាលើកិច្ចព្រមព្រៀងអនុញ្ញាតិឲ្យអង់គ្លេសមាន "អធិបតេយ្យភាព លើដំណើរការ" របស់ យន្តហោះ។[18]

សរុបមក ការមានប្រព័ន្ធពីរដូចគ្នាធ្វើឲ្យមានការចំណាយកាន់តែច្រើនសំរាប់បង្កើតប្រព័ន្ធទាំងពីរនោះ។ គួយ៉ាងដូចជាករណី GPS ប្រព័ន្ធ Galileo សន្យាថាមានភាពសុក្រឹត្យជាងប្រព័ន្ធរបស់អាមេរិចមួយនេះ។ ក្នុងករណីរបស់ Joint Strike Fighter Program ប្រតិកម្មរបស់អាមេរិច នឹងធ្វើឲ្យមានការផ្អាកកិច្ច សហប្រតិបត្តិការក្នុងកម្មវិធីប្រហាក់ប្រហែលគ្នានេះ នៅថ្ងៃអនាគត។

អនុសាសន៍ទី៣ របស់ WGIG គឺថាគួរតែធ្វើឲ្យប្រសើរឡើងនូវសហប្រតិបត្តិការអន្តរជាតិរវាងអង្គការ និងភ្នាក់ងារទាំងឡាយដែលពាក់ព័ន្ធនឹងការអភិបាលអ៊ីនធឺណែត។ អង្គការចំរុះរដ្ឋាភិបាលមានដូចជា ITU អង្គការកម្មសិទ្ធបញ្ញាអន្តរជាតិ និងអង្គការ UNESCO។ ស្ថាប័នអ៊ីនធឺណែតមានដូចជា ICANN អង្គការសង្គមអ៊ីនធឺណែត ក្រុមការងារវិស្វកម្មអ៊ីនធឺណែត សហគមន៍បណ្តាញគេហទំព័រពិភពលោក និង ភ្នាក់ងារចុះបញ្ជីអ៊ីនធឺណែតប្រចាំតំបន់ (RIRs)។ អនុសាសន៍នេះបង្ហាញថាមានភ្នាក់ងារដទៃៗទៀត ជាច្រើនក្រៅពី ITU ដែលពាក់ព័ន្ធនឹងការអភិបាលអ៊ីនធឺណែត។ សរុបមក ITU មិនបានបង្ហាញ ពីសមត្ថភាពគ្រប់គ្រាន់ដើម្បីកាន់កាប់ការងារអភិបាលអ៊ីនធឺណែតនេះតែម្នាក់ឯងឡើយ។

---

17 អគ្គនាយកដ្ឋានថាមពលនិងដឹកជញ្ជូន "ព័ត៌មានអំពីសំខាន់ៗអំពី Galileo" Directorate-General Energy and Transportation, "Galileo FAQ," http://ec.europa.eu/dgs/energy_transport/galileo/faq/index_en.htm.

18 "កម្មវិធីរួបរួមអ្នកប្រយុទ្ធជាមុខ" "Joint Strike Fighter deal agreed," *BBC News*, 12 December 2006, http://news.bbc.co.uk/2/hi/uk_news/politics/6173143.stm.

អនុសាសន៍ទី៤ របស់ WGIG គឺសំដៅលើការសំរបសំរួលគោលនយោបាយថ្នាក់ជាតិ និងតំបន់។ អនុសាសន៍នេះទាមទារឲ្យមានទំនាក់ទំនងការងារយ៉ាងជិតស្និទ្ធរវាង ccTLD និងរដ្ឋាភិបាល និង គំរូឲ្យមានការបង្កើតគោលនយោបាយអំណោយផលដល់ប្រព័ន្ធអ៊ីនធឺណែត ព្រមទាំងបានណែនាំឲ្យរដ្ឋាភិបាលបង្កើត "គណកម្មាធិការមេ" មួយដើម្បីបង្ហាញផ្លូវការងារអភិបាលអ៊ីនធឺណែតថ្នាក់ជាតិ។ គណកម្មាធិការនេះមានតួនាទីពិនិត្យបញ្ហាដូចតទៅ៖

- គ្រប់គ្រង File ទាំងឡាយក្នុង root zone និង ប្រព័ន្ធ server មេ សំរាប់ DNS
- ចាត់ចែង IP address
- តំលៃតភ្ជាប់បណ្តាញ
- ស្ថេរភាពអ៊ីនធឺណែត សន្តិសុខ និងឧក្រិដ្ឋកម្មក្នុងប្រព័ន្ធអ៊ីនធឺណែត
- Spam
- សិទ្ធបញ្ចេញមតិ
- ការចូលរួមដ៏មានតំលៃ ក្នុងការអភិវឌ្ឍគោលនយោបាយអ៊ីនធឺណែតជាអន្តរជាតិ
- ការពារទិន្នន័យ និងសិទ្ធឯកជន
- សិទ្ធរបស់អ្នកប្រើប្រាស់
- អន្តរភាសា

បញ្ហាទាំងនេះត្រូវបានបែងចែកជា ៤ក្រុម មានដូចតទៅ៖

**ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត** - ក្រុមនេះមានទំនាក់ទំនងផ្នែកនយោបាយ ដូចជាបញ្ហារបស់ ICANN ទាក់ទងនឹង IP address ឈ្មោះដូម៉េន និង Server របស់ root zone។ បញ្ហាហិរញ្ញវត្ថុក៏បានបញ្ចូល ក្នុងក្រុមនេះផងដែរ។
**ការប្រើ និងការបំពានប្រព័ន្ធអ៊ីនធឺណែត**- ក្នុងក្រុមនេះមានដូចជាបញ្ហា spam សន្តិសុខ បណ្តាញ និងឧក្រិដ្ឋកម្មលើប្រព័ន្ធអ៊ីនធឺណែត ដោយមានគោលបំណងបង្កើនការប្រើប្រាស់ និងបន្ថយការប្រើមិនត្រឹមត្រូវ។
**បញ្ហាទាក់ទង នឹង អ៊ីនធឺណែត តែមានឥទ្ធិពលធំធេង** - គោលនយោបាយដែលប៉ះពាល់ដល់អ៊ីនធឺណែត ក៏អាច មានឥទ្ធិពលលើអ្វីៗផ្សេងទៀតជាច្រើន រួមមានផ្នែកគន្លឹះមួយចំនួនជានយោបាយប្រកួតប្រជែងពាណិជ្ជកម្មអេឡិចត្រូនិច និងសិទ្ធកម្មសិទ្ធបញ្ញា។

**ជ្រុងអភិវឌ្ឍន៍របស់អ៊ីនធឺណែត-** គួរចងចាំថាការអភិវឌ្ឍន៍ជាគោលបំណងសំខាន់ ឈរពីក្រោយ WSIS ដែលធ្វើឲ្យមានការពិភាក្សាយ៉ាងផុសផុលលើការងារអភិបាលអ៊ីនធឺណែតនេះ។ អង្គការថវិកាសាមគ្គីឌីជីថល (Digital Solidarity Fund) បាននឹងកំពុងសំរួលឲ្យមានការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ដើម្បីការអភិវឌ្ឍន៍ (ICTD)។ ការអភិវឌ្ឍន៍ក្នុងបរិបទនេះត្រូវធ្វើឡើងឲ្យស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍សហវត្ស (MDG)។

ក្រុមបញ្ហាទាំងបួននេះ នឹងត្រូវលើកយកមកពិភាក្សានៅក្នុងផ្នែកបន្ទាប់ៗនៃមេរៀន។



ការងារត្រូវធ្វើ

១.ចូររាយឈ្មោះគោលនយោបាយអ៊ីនធឺណែតដែលមានក្នុងប្រទេសរបស់អ្នក។

២.ចូរធ្វើការតាមដាន (ឬរៀបរាប់ដោយខ្លី) នយោយបាយទាំងនេះត្រូវបានបង្កើតឡើងយ៉ាងដូម្តេចខ្លះ។

ប្រទេសកំពុងអភិវឌ្ឍន៍ជួបនឹងបញ្ហាពីរទាក់ទងនឹងការអភិបាលអ៊ីនធឺណែត៖ (១) តើមានវិធីអ្វីខ្លះ ដើម្បីឲ្យមានការចូលរួមគ្រប់គ្រងប្រកបដោយអត្ថន័យនិងប្រសិទ្ធភាព និង (២) តើត្រូវមានការអភិវឌ្ឍន៍សមត្ថភាពបែបណាខ្លះ ដើម្បីដោះស្រាយបញ្ហាដែលជួបប្រទះ។

អង្គប្រជុំកំពូល WSIS ក្នុងទីក្រុង Tunis បានឆ្លើយតបទៅនឹងរបាយការណ៍របស់ WGIG ទាក់ទងនឹងការងារអភិបាលអ៊ីនធឺណែត ដោយទុកឲ្យរដ្ឋាភិបាលនៃប្រទេសនីមួយៗ មានសមត្ថកិច្ចចាត់ចែង ដាច់មុខលើ ccTLD របស់ពួកគេ។

## សរុបសេចក្តី

របាយកាណ៍ WGIG គឺជាការសង្ខេបដ៏ល្អ អំពីបញ្ហាគន្លឹះៗទាក់ទងនឹងអ៊ីនធឺណែត។ វាក៏បានផ្តល់ផង ដែរ នូវគំរូសំរាប់ដំណើរការអភិបាលអ៊ីនធឺណែត។ របាយការណ៍នេះក៏បានគាំទ្រយ៉ាងពេញទំហឹងចំពោះ រដ្ឋាភិបាល ផ្នែកឯកជននិងសង្គមស៊ីវិល ដែលជាអ្នកពាក់ព័ន្ធសំខាន់ៗ ក្នុងកាអភិបាលអ៊ីនធឺណែត។ ដំណើរការប្រព្រឹត្តទៅរបស់ WGIG ក៏ជាគំរូនៃភាពបើកទូលាយ និងតម្លាភាព។ ប៉ុន្តែ របាយការណ៍ WGIG មិនមែនជាផែនទីប្រាប់ផ្លូវ ឬជាផែនការសកម្មភាពនោះឡើយ។

### សាកល្បងខ្លួនឯង

១.តើ WGIG បានផ្តល់និយមន័យនៃការអភិបាលអ៊ីនធឺណែតយ៉ាងដូម្តេច? តើអ្វីជាចំនុច សំខាន់ក្នុងនិយមន័យនេះ?

២.តើអនុសាសន៍សំខាន់ៗរបស់ WGIG មានអ្វីខ្លះ?

៣. តើមានមេរៀនអ្វីខ្លះទាក់ទងនឹងការអភិបាលអ៊ីនធឺណែត ដែលអាចទាញយកបានពី របាយការណ៍របស់ WGIG?

# ៣. ទំហំនៃការអភិបាលប្រព័ន្ធអ៊ីនធឺណែត១៖ ការប្រើប្រាស់អ៊ីនធឺណែត

ផ្នែកនេះមានគោលបំណងរៀបរាប់អំពីវិធីសាស្ត្រផ្សេងៗដើម្បីដាក់ច្បាប់ទំលាប់លើប្រព័ន្ធអ៊ីនធឺណែត។

យើងគួរដឹងពីបញ្ហា ថាតើការដាក់ច្បាប់ទំលាប់និងគោលនយោបាយសំរាប់អ៊ីនធឺណែតធ្វើឡើងយ៉ាងដូចម្តេច? តើវាអាចធ្វើបានឬទេ សំរាប់ការដាក់ក្រឹត្យក្រមលើអ៊ីនធឺណែតនោះ?
តាមពិត ក្នុងព្រំដែនកំនត់មួយ គេអាចដាក់ចេញនូវបទបញ្ជាទៅលើអ៊ីនធឺណែត ក្នុងគោលបំណងលើកទឹកចិត្តអ្នកប្រើ ក៏ដូចជាធ្វើឲ្យការប្រើប្រាស់កាន់តែមានភាពប្រសើរឡើង។

## ៣.១ វិធីសាស្ត្រក្នុងការដាក់បទបញ្ជា

មានវិធីសាស្ត្រចំនួន ៤ ក្នុងការដាក់បទបញ្ជា៖

- ច្បាប់- ការប្រើប្រាស់កម្លាំងចាប់បង្ខំ តាមរយៈទណ្ឌកម្មរបស់រដ្ឋាភិបាល និងផ្នែកឯកជន ដោយរួមបញ្ចូលទាំងការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់ស្ថាប័នដែលទទួលសិទ្ធិពីរដ្ឋាភិបាល
- ក្រឹត្យក្រមសង្គម- តាមរយៈការរំពឹងទុកលទ្ធផលអ្វីមួយ ការលើកទឹកចិត្ត និង ភាពអាម៉ាស
- យន្តការទីផ្សារ- ជាធម្មតាទាក់ទងនឹងការកំណត់តំលៃ និងការគ្រប់ដណ្តប់នៃសេវា
- ស្ថាបត្យកម្ម- តើបច្ចេកវិទ្យាណាខ្លះត្រូវបានអនុញ្ញាតិឲ្យប្រើ ឬមិនលើកទឹកចិត្តឲ្យប្រើនិង ហាមឃាត់។[19]

### ស្ថាបត្យកម្ម

ពាក្យ "ស្ថាបត្យកម្ម" សំដៅលើការរចនាបច្ចេកវិទ្យាអ៊ីនធឺណែត ដែលអាចលើកទឹកចិត្តឬមិនគាំទ្រសកម្មភាពណាមួយលើប្រព័ន្ធអ៊ីនធឺណែត។ ជាឧទាហរណ៍ ដើម្បីកាត់បន្ថយការបើកបរដោយល្បឿន លឿន គេអាចបង្កើនចំនួនប៉ូលីសប្រចាំការ ឬចំនួនទីទួលបន្ថយល្បឿនកាត់ទទឹងផ្លូវ។ នៅប្រទេស សឹង្ហបូរី ផ្លូវនៅតាមភូមិករណ៍ប្រជាជនត្រូវបានគេធ្វើឲ្យមានរាងកោង ដែលអាចកាត់បន្ថយល្បឿន បើកបរ និងបង្កើនសោភ័ណភាព។ ដូចគ្នានេះដែរ ពួកផលិតករបានប្រើវិធីចាក់សោ និងរាំងខ្ទប់ ដើម្បីបង្កភាពលំបាកក្នុងការថតចំលងបទចំរៀងនិងវីដេអូដោយខុសច្បាប់។

---

19 លោក Lawrence Lessig, *Code 2.0* (New York: Basic Books, 2007).

ចំពោះអ៊ីនធឺណែតវិញ មនុស្សមួយចំនួនជឿថាការរចនារបស់អ៊ីធឺណែតអាចឲ្យសិទ្ធិក្នុងការបញ្ចេញមតិកាន់តែប្រសើរ ដែលមានន័យថានរណាម្នាក់ដែលចង់ដាក់បទបញ្ញាលើខ្លឹមសាររបស់អ៊ីនធឺណែតត្រូវប្រឹងប្រែងដោះស្រាយការលំបាកផ្សេងៗ។ នៅសាធារណៈរដ្ឋកូរ៉េជំនួសឱ្យការប្រឹងប្រែងស្វែងរកនិងចាប់ខ្លួនអ្នកលបលួចចូលប្រព័ន្ធកុំព្យូទ័រនិងអ្នកលួចបញ្ជាបណ្តាញកុំព្យូទ័រ "botnet" សំរាប់វាយប្រហារប្រព័ន្ធអ៊ីនធឺណែត ទីភ្នាក់ងារសន្តិសុខអ៊ីនធឺណែត បានបង្កើត "honeynet" មួយដែលបញ្ឆោតឱ្យ bootnet វាយប្រហារលើបណ្តាញក្លែងក្លាយ ក្នុងគោលបំណងសិក្សាពីវិធីសាស្ត្រទប់ទល់។

**យន្តការទីផ្សារ**

ជាធម្មតា វិធីសាស្ត្រនេះទាក់ទងទៅនឹងការកំណត់តំលៃ និងការគ្រប់ដណ្តប់នៃទំនិញនិងសេវាកម្ម។ ការដាក់បទបញ្ញាដោយប្រើយន្តការទីផ្សារ នឹងប្រើប្រាស់នូវយុទ្ធសាស្ត្រដូចជា ការប្រកួតប្រជែងដោយយុត្តិធម៌ ការដាក់កិច្ចសន្យាច្បាស់លាស់ ព្រមទាំងជំរុញឲ្យមានការប្រកួតប្រជែងក្នុងទីផ្សារ ដោយប្រើគោលគំនិតពាណិជ្ជកម្ម (ការទិញនិងលក់)។

ការទិញដូរភាពឯកជននៅលើប្រព័ន្ធអ៊ីនធឺណែត ដូចជាការផ្តល់ជូនអាស័យដ្ឋាន e-mail របស់ខ្លួនដើម្បីទទួលបានសិទ្ធិអានឬទទួលឯកសារ គឺជាឧទាហរណ៍នៃការប្រើវិធីសាស្ត្រនេះ។ ទស្សនៈនេះគឺថាបើសិននរណាម្នាក់ឲ្យតំលៃភាពឯកជនរបស់គេច្រើនជាងការអានឬទទួលឯកសារនោះ គេនឹងមិនព្រមផ្តល់អាស័យដ្ឋាន e-mail របស់គេឡើយ។ នៅប្រទេសអាមេរិច ក្រុមហ៊ុនឯកជនឈ្មោះ Trust-e ត្រូវបង្កើតឡើងដើម្បីផ្តល់សេវាកម្មការពារភាពឯកជនរបស់អ្នកប្រើប្រាស់។ ផ្ទុយទៅវិញ សហគមអ៊ឺរុប (EU) មានជំនឿថាភាពឯកជននេះ គួរតែគ្រប់គ្រងដោយច្បាប់ ជាជាងដោយកិច្ចព្រមព្រៀងរវាងបុគ្គលនិងក្រុមហ៊ុនឯកជន។

**ក្រឹត្យក្រមសង្គម**

ការប្រើប្រាស់វិធីសាស្ត្រនេះបានសន្មត់ថា សំពាធសង្គមអាចជំរុញឲ្យឥរិយបថបុគ្គលមានការផ្លាស់ប្តូរ។ ពិធីការលើប្រព័ន្ធអ៊ីនធឺណែតគឺជាឧទាហរណ៍នៃការប្រើក្រឹត្យក្រមសង្គមជាវិធីសាស្ត្រដាក់បទបញ្ញា។ ឧទាហរណ៍ ពិធីការបែបនេះតំរូវឲ្យការបញ្ចេញយោបល់ណាមួយនៅលើវេទិកា មិនត្រូវចាកប្រធានបទ ឡើយ ម៉្យាងទៀតបើសិនមាននរណាម្នាក់និយាយថា "welcome" ឆ្លើយតបនឹងពាក្យ "thank you" របស់អ្នក វាមិនចាំបាច់បន្តការឆ្លើយឆ្លងទៀតឡើយ។

ការប្រើប្រាស់ក្រឹត្យក្រមសង្គមមានលក្ខណៈងាយស្រួលជាង ដោយសារនៅពេលក្រុមណាមួយកើត ឡើង វានឹងដើរតួនាទីជាភ្នាក់ងារត្រួតពិនិត្យនិងពង្រឹង។ អ្នកទាំងឡាយណាដែលបំពាន លើក្រឹត្យក្រមអាចនឹង បណ្ដេញចេញពីក្រុម ដែលការធ្វើបែបនេះអាចមានឥទ្ធិពលនៅពេលប្រើជាមួយសមាជិកក្រុមសំខាន់ៗ។

**ច្បាប់ ដោយរួមទាំងបទបញ្ជាផ្ទៃក្នុង**

ឧស្សាហកម្មអ៊ីនធឺណែតមានទំនោរទៅរកការប្រើប្រាស់បទបញ្ជាផ្ទៃក្នុង ដែលមានលក្ខណៈងាយស្រួល បត់បែនក្នុងការអនុវត្តនិងពង្រឹងច្បាប់។ ដើមឡើយបទបញ្ជាផ្ទៃក្នុងមានន័យថា ឧស្សាហកម្មណាមួយ ដាក់បទបញ្ជាលើឧស្សាហកម្មមួយផ្សេងទៀត ដោយមិនសំដៅលើអត្ថន័យដែលថាបុគ្គលឬក្រុមហ៊ុន ដាក់បទបញ្ជាលើខ្លួនឯងនោះឡើយ។ ក្នុងការអនុវត្តជាក់ស្ដែង បទបញ្ជាផ្ទៃក្នុងគឺជាការផ្ទេរអំណាច ដែលទោះជាយ៉ាងណាក៏ដោយ អំណាចដាក់ទណ្ឌកម្មធំជាងគេ ស្ថិតក្នុងដៃរបស់រដ្ឋាភិបាលដដែល។ នេះមានន័យថា រដ្ឋាភិបាលបានប្រគល់សិទ្ធិនាំមុខទៅឲ្យឧស្សាហកម្ម ដើម្បីដាក់បទបញ្ជាលើវិស័យ ដែលព្រមព្រៀង។ ការផ្សាយពាណិជ្ជកម្ម ជាវិស័យដែលរដ្ឋាភិបាលជាពិសេសក្នុងប្រទេសអភិវឌ្ឍន៍ មាន ទំនោរទៅរកការប្រើបទបញ្ជាផ្ទៃក្នុងនេះ។ ជនល្មើសរឹងក្បាល ដែលមិនគោរពតាមគោលការណ៍ របស់វិស័យនេះ អាចនឹងត្រូវរដ្ឋាភិបាលប្ដឹងពីបទធ្វើឲ្យមានការយល់ច្រលំ ឬការផ្សាយពាណិជ្ជកម្ម រំលោភបំពាន។

ប៉ុន្ដែ វិធីសាស្ដ្រប្រើបទបញ្ជាផ្ទៃក្នុងនេះ តំរូវផ្នែកឯកជនមានមានការតាំងចិត្តខ្ពស់។ វិធីសាស្ដ្រនេះហាក់ ដូចជាមានប្រសិទ្ធភាពជាមួយនឹងវិស័យផ្សាយពាណិជ្ជកម្ម ដោយសារការប្រើសារចណ៍ជាផ្លូវការរបស់ រដ្ឋាភិបាល អាចនឹងបន្ថយល្បឿនរបស់វិស័យដែលមានសន្ទុះដ៏លឿនមួយនេះ ព្រមទាំងអាចនឹងបង្អាក់ គំនិតច្នៃប្រឌិតផ្សេងៗ។ ឧស្សាហកម្មអ៊ីនធឺណែតមានចំណូលចិត្តតិចជាងទៅលើការប្រើបទបញ្ជាផ្ទៃក្នុង នេះ។ មនុស្សមួយចំនួនក្នុងឧស្សាហកម្មនេះបានត្អូញត្អែរថា ការប្រើបទបញ្ជាផ្ទៃក្នុង មានន័យថា ឧស្សាហកម្មនេះកំពុងធ្វើការងាររបស់រដ្ឋាភិបាល។

### សំនួរពិចារណា

តើវិធីសាស្រ្តទាំង ៤ មានការប្រើប្រាស់កំរិតណាក្នុងប្រទេសរបស់អ្នក? តើវិធីសាស្រ្ត ណាមួយ ឬណាខ្លះដែលនឹងមិនមានប្រសិទ្ធភាពក្នុងប្រទេសរបស់អ្នក ព្រោះហេតុអ្វី? តើវិធីសាស្រ្ត ណាមួយ ឬណាខ្លះដែលនឹងមានប្រសិទ្ធភាពល្អជាងគេក្នុងប្រទេសរបស់អ្នក ព្រោះហេតុអ្វី?

## ៣.២ ទិសដៅណែនាំ

ដោយសារនិយមន័យនៃការអភិបាលអ៊ីនធឺណែតមានវិសាលភាពធំ ខាងក្រោមនេះគឺត្រូវបានណែនាំសំរាប់ជាក្បួនក្នុងការបង្កើតគ្រោងឆ្អឹងនៃគោលនយោបាយណាមួយ។ ក្បួននេះគ្របដណ្តប់លើបញ្ហា ជាច្រើន ក៏ដូចជាមានក្រឹតចំណាំដើម្បីកំនត់ពីគុណភាពរបស់ក្រឹត្យក្រម និងគោលនយោបាយដែលគេកំពុងបង្កើតនោះ។ ប្រសិទ្ធភាពរបស់ក្បួននេះត្រូវបានបញ្ជាក់តាមរយៈការសាកល្បងប្រើក្នុងស្ថានភាពជាក់ស្តែង។[20]

នៅពេលដែលក្បួននេះត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៦ ប្រទេសជាច្រើនមិនមានវិធានការគ្រឹះសំរាប់គ្រប់គ្រងការសំគាល់ស្លាកស្នាមអេឡិចត្រូនិចឡើយ។ សព្វថ្ងៃនេះមានប្រទេសមួយចំនួនតូច ដែលគ្មានវិធានការគ្រឹះនេះ។ មកដល់ពេលបច្ចុប្បន្ន គ្រោងឆ្អឹងនេះនៅតែត្រូវគេយកមកប្រើដើម្បីណែនាំដំណើរការចំរាញ់ក្រឹត្យក្រមនិងគោលនយោបាយជុំវិញអ៊ីនធឺណែត។

បើគិតត្រួសៗ តាមលំដាប់ចុះនៃភាពសំខាន់ មានប្រធានបទមួយចំនួន ដែលត្រូវដោះស្រាយ ដូចខាង ក្រោម៖

១ ការប្រើប្រាស់ និងការផ្តល់សេវាកម្ម

២ ពាណិជ្ជកម្មបែបអេឡិចត្រូនិច

៣ ការដាក់បទបញ្ជាលើខ្លឹមសារ

៤ សន្តិសុខ

៥ កម្មសិទ្ធិបញ្ញា

៦ ភាពឯកជន

[20] សូមមើល Ang (2005) សំរាប់ការពិភាក្សាពេញលេញជាងនេះ

យើងផ្តល់សារៈសំខាន់ខ្លាំងជាងគេ ដល់ប្រធានបទអំពីការប្រើប្រាស់និងតំលៃ ដោយសារវាពាក់ព័ន្ធនឹងលទ្ធភាពក្នុងការទទួលបានសេវាកម្មអ៊ីនធឺណែត ដែលវាបង្កឲ្យមានបញ្ហាយ៉ាងច្រើនទាក់ទងនឹងការទំនាក់ទំនងរវាងអ៊ីនធឺណែត និងសង្គម។ ជាឧទាហរណ៍ បើសិនជាមាននរណាម្នាក់បាន ប្រព្រឹត្តបទល្មើសកេងបន្លំធនាគារតាមប្រព័ន្ធអ៊ីនធឺណែត តើច្បាប់សង្គមត្រូវបានកែតម្រូវទាន់ពេល ដើម្បីដាក់ទោសបុគ្គលនោះដោយផ្អែកលើភស្តុតាងដែលប្រមូលបានពីប្រព័ន្ធដែរឬទេ? មានផលចំនេញពាណិជ្ជកម្មដើម្បីដោះស្រាយបញ្ហាគន្លឹះនេះ តាមរយៈការសំរបសំរួលរវាងច្បាប់សង្គម និងអ៊ីនធឺណែត ។ បញ្ហាទាក់ទងនឹងការដាក់បញ្ហាលើខ្លឹមសារ និងសន្តិសុខអ៊ីនធឺណែត នឹងលេច ឡើងដោយសារ ភាពតានតឹងប្រទាញប្រទង់គ្នារវាងអ្វីដែលមានក្នុងសង្គម ហើយអាច ធ្វើបានលើប្រព័ន្ធអ៊ីនធឺណែត និង អាចធ្វើបាននៅក្នុងស្ថានភាពខាងក្រៅ។ មានប្រទេសជាច្រើនបានបោះបង់ការព្យាយាមដាក់បទបញ្ជាលើខ្លឹមសារអ៊ីនធឺណែត លើកលែងតែក្នុងលក្ខខ័ណ្ឌការពារកុមារអាយុតិចជាង ១២ ឆ្នាំប៉ុណ្ណោះ។ មានលក្ខខ័ណ្ឌមួយចំនួនដែលបញ្ហាដាក់បទបញ្ជាលើខ្លឹមសារ និងសន្តិសុខអ៊ីនណែតចាំបាច់ ត្រូវតែដោះស្រាយដោយសារអ្នកប្រើប្រាស់មួយចំនួន ដែលមានភាពខ្មាស់អៀនមិនព្រមប្រើអ៊ីនធឺណែត ឧទាហរណ៍ព្រោះមិនចង់មានខ្លឹមសារអាសអាភាសនៅគេហដ្ឋាន ឬខ្វល់ខ្វាយការលបលួចចូលប្រព័ន្ធកុំព្យូទ័រខុសច្បាប់តាមរយៈអ៊ីនធឺណែត (hack)។ ការការពារកម្មសិទ្ធិបញ្ញា និងភាពឯកជនកាន់តែមានសារៈសំខាន់ដោយសារការប្រើប្រាស់អ៊ីនធឺណែត កាន់តែសុះសាយទៅៗ។

### ការប្រើប្រាស់ និងការផ្តល់សេវាកម្ម

បញ្ហាដែលត្រូវដោះស្រាយក្រោមប្រធានបទនេះ គឺផ្តោតទៅលើសេវាកម្មដែលមានតំលៃសមរម្យ។ បញ្ហាទាំងនេះមានដូចជា៖

- របៀបរៀបចំស្តង់ដាបច្ចេកទេសក្នុងបណ្តាញណាមួយ។
- របៀបធានាឲ្យមានការតភ្ជាប់គ្នា និងអាចដំណើរការជាមួយគ្នាបានរបស់ប្រព័ន្ធកុំព្យូទ័រ និង បណ្តាញ។
- របៀបដាក់បទបញ្ជាលើការកំណត់តំលៃ និងគុណភាពសេវាកម្មនៃសេវាកម្មព័ត៌មាន។
- ការបញ្ជាក់ច្បាស់លាស់អំពីការទទួលខុសត្រូវចំពោះមុខច្បាប់របស់អ្នកផ្តល់សេវាកម្ម ដូចជាការការពារពួកគេពីការទទួលខុសត្រូវមុខច្បាប់ទាក់ទងនឹងខ្លឹមសារនិងឯកសាររបស់ភាគីទី៣។

ការលើកលែងទោសដូចពោលខាងលើមានសារៈសំខាន់ ពីព្រោះបើសិនជាគ្មានវាទេ ពាណិជ្ជកម្មតាមបែបអេឡិចត្រូនិចអាចនឹងមិនលូតលាស់ទៅមុខ។

### សំនួរពិចារណា

ក្នុងប្រទេសជាច្រើន ច្បាប់បង្ខូចកេរ្តិ៍ឈ្មោះមានន័យថា បុគ្គលម្នាក់ដែលបានបំពានបុគ្គលម្នាក់ទៀត ដោយប្រើព័ត៌មានមិនពិត ត្រូវតែសងជំងឺចិត្តដល់បុគ្គលរងគ្រោះ។ នៅប្រទេសមួយចំនួន តំលៃនៃសំណងអាស្រ័យលើអំពើនោះធ្វើដោយចេតនាឬទេ។ នៅប្រទេសដទៃទៀត គេមិនគិតថាចេតនាឬអចេតនាឡើយ។ នៅប្រទេសរបស់អ្នក តើការអនុវត្តច្បាប់មានលក្ខណៈបែបណា ចំពោះព័ត៌មានមិនត្រឹមត្រូវ ដែលមាននៅលើគេហទំព័រដូចជា (ក) ការបញ្ចេញមតិលើសៀវភៅ (ខ)ការបញ្ចេញមតិលើ សណ្ឋាគារ (គ) ការដេញថ្លៃទំនិញ? តើអ្នកផ្តល់សេវាកម្មអ៊ីនធឺណែតត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ឬទេ បើសិនជាខ្លួនត្រូវបានរកឃើញថាបានបញ្ជូនព័ត៌មានមិនត្រូវ នោះ?

**ពាណិជ្ជកម្មតាមបែបអេឡិចត្រូនិច**

បើតាមទស្សនៈពាណិជ្ជកម្ម ពាណិជ្ជកម្មតាមបែបអេឡិចត្រូនិច (e-commerce) មានផលប្រយោជន៍ជាច្រើន។ ក្រុមហ៊ុនដែលមានជំនួញបែបនេះ អាចបើកហាងលើ ២៤ ម៉ោង ព្រមទាំងកាត់បន្ថយឈ្មួញកណ្តាល និងអាចបើកទីផ្សារថ្មីៗ។ ពាណិជ្ជកម្មបែបអេឡិចត្រូនិចនេះ ក៏អាចធ្វើឲ្យជំនួញកាន់តែមានប្រសិទ្ធភាព ដោយសារការងារផ្សេងៗត្រូវដើរដោយកុំព្យូទ័រ។

ប៉ុន្តែ e-commerce មិនអាចអនុវត្តបានគ្រប់ប្រភេទនៃជំនួញឡើយ។ e-commerce អាចនឹងមិនមានប្រសិទ្ធិភាពក្នុងជំនួញលក់គ្រឿងសង្ហារឹមថ្លៃៗ ដោយសារអតិថិជនត្រូវការឃើញ និងសាកល្បងសំភារៈទាំងនោះមុនសំរេចចិត្តទិញ។ ម៉្យាងវិញទៀត ក្នុងវប្បធម៌មួយចំនួន ការទិញទំនិញគឺជាសកម្មភាពលំហែរ ហើយ e-commerce បានបំបាត់ស្ថានភាពបែបនេះ។

វាមានប្រយោជន៍ក្នុងការប្រឈមមុខដោះស្រាយទាក់ទងនឹង e-commerce នេះ ព្រោះធ្វើដូចនេះអាចឲ្យយើងដោះស្រាយបញ្ហាជាច្រើនដែលជាឧបសគ្គចំពោះការប្រើប្រាស់អ៊ីនធឺណែតឲ្យកាន់តែទូលំទូលាយនោះ។ ខាងក្រោមគឺជាបញ្ហាដែលគួរដោះស្រាយ៖

- សំគាល់បរិយាកាសអេឡិចត្រូនិចទៅតាមផ្លូវច្បាប់
- ទទួលយកនូវស្លាកស្នាមអេឡិចត្រូនិច
- សំគាល់ប្រតិបត្តិការតាមបែបអេឡិចត្រូនិច
- សំគាល់ហត្ថលេខា និងលិខិតអះអាងអេឡិចត្រូនិច
- ធ្វើឲ្យជាក់ច្បាស់នូវ សិទ្ធិ ការទទួលខុសត្រូវចំពោះការងារ និងចំពោះមុខច្បាប់ របស់ភាគីផ្សេងៗ ព្រមទាំងមានយន្តការដោះស្រាយជំលោះ
- លើកទឹកចិត្តយន្តការបង់ប្រាក់អេឡិចត្រូនិច និងការប្រើប្រាស់របស់វា
- ផ្តល់សិទ្ធិដល់ប៉ូលីសក្នុងការពង្រឹងច្បាប់ e-commerce
- ធ្វើឲ្យជាក់ច្បាស់នូវការយកពន្ធក្នុង e-commerce

វាប្រហែលជាមានការចាំបាច់ ដើម្បីបង្កើតលក្ខន្តិកៈដែលគេហៅថាកំរងច្បាប់ e-commerce ឬច្បាប់ប្រតិបត្តិការតាមអេឡិចត្រូនិច។ ច្បាប់ប្រភេទនេះ នឹងរៀបចំបរិដ្ឋានសមស្របសំរាប់ e-commerce។

### ការទទួលស្គាល់ស្លាកស្នាមអេឡិចត្រូនិច

ទសជាច្រើន ការទទួលស្គាល់ទំរង់ផ្សេងៗនៃស្លាកស្នាមអេឡិចត្រូនិច ជាកត្តាសំខាន់ក្នុងការធានាឲ្យមានការគ្របដណ្តប់ទូលំទូលាយជាសាធារណៈនៃសេវាកម្ម អ៊ីនធឺណែតចាប់តាំងពីពាក់កណ្តាលទស្សវត្សឆ្នាំ ១៩៩០ មកម្ល៉េះ។ ឧទាហរណ៍ បែបបទនៃការទទួលស្គាល់នេះត្រូវបានកែប្រែ នៅពេលដែលហត្ថលេខាអេឡិចត្រូនិចត្រូវបានបង្កើតឡើង។ នៅក្នុងប្រទេសសឹង្ហបូរី បែបបទទាំងនេះត្រូវបានកែប្រែក្នុងលក្ខន្តិកៈប្រតិបត្តិការអេឡិចត្រូនិចក្នុងឆ្នាំ ១៩៩៦។ នៅឥណ្ឌា ពួកវាត្រូវបានកែប្រែក្នុង លក្ខន្តិកៈបច្ចេកវិទ្យាព័ត៌មានឆ្នាំ ២០០០។ សង្ខេបមក ច្បាប់ថ្មីដែលប្រើសំរាប់សំរបសំរួលសង្គមខាងក្រៅនិងពិភពអ៊ីនធឺណែតទើបតែចាប់កំណើតថ្មីៗនេះប៉ុណ្ណោះ។

### ការងារត្រូវធ្វើ

ចូររៀបរាប់ពីការដាក់បទបញ្ញាដើម្បីធ្វើឲ្យប្រសើរឡើង ឬគាំទ្រនូវ e-commerce ក្នុងប្រទេសរបស់អ្នក។ បើសិនជាគ្មានបទបញ្ញាបែបនេះទេ ចូររាយបញ្ជីនូវអ្វីដែលអ្នកគិតថាអាចជាបទបញ្ញាសមស្រប ដើម្បីធ្វើឲ្យប្រសើរឡើង ឬអាចគាំទ្រ e-commerce ក្នុងប្រទេសរបស់អ្នក។

**ការដាក់បទបញ្ញលើខ្លឹមសារ**

អ្នកប្រើប្រាស់មួយចំនួនមានមតិថាខ្លឹមសារអ៊ីនធឺណែតដែលមិនល្អគឺបណ្ដាលមកពីការមិនបានចុះកិច្ចព្រមព្រៀងទទួលយកខ្លឹមសារនោះជាមុន។ ប៉ុន្តែខ្លឹមសារដែលមិនល្អនេះមានកំរិតខុសគ្នាពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត។ ការដោះស្រាយបញ្ហានេះតំរូវឲ្យមានគុណ្យភាពនៃគោលការណ៍មួយចំនួនដែលប្រកួតប្រជែងគ្នា។ គុណប្រយោជន៍ចំបងនៃការដែលមិនមានការច្រោះនិងចំរាញ់ខ្លឹមសារ គឺយើងមានខ្លឹមសារដែលមិនមានចំនួនកំនត់។ ជួនកាលការប្រើវិធានការច្រោះនេះអាចរាំងខ្ទប់លើសលុបទៅលើខ្លឹមសារដែលមិនមានផលអាក្រក់ដល់អ្នកប្រើប្រាស់។

ខាងក្រោមនេះ គឺជាចំនុចទាក់ទងនឹងការដាក់វិធានការលើខ្លឹមសារ ដែលចាំបាច់ត្រូវដោះស្រាយ៖

- របៀបរាំងខ្ទប់ខ្លឹមសារមិនល្អលើប្រព័ន្ធអ៊ីនធឺណែត ជាពិសេសអ្វីដែលប៉ះពាល់កុមារ
- របៀបការពារមិនឲ្យខ្លឹមសារមិនល្អប៉ះពាល់ដល់ប្រយោជន៍ជាតិ
- របៀបសំរបសំរួលខ្លឹមសារឲ្យស៊ីសង្វាក់នឹងវប្បធម៌និងទំនៀមទំលាប់

### ខ្លឹមសារខុសច្បាប់៖ ការសំរបសំរួលជាអន្តរជាតិ

ដោយសារភាពខុសគ្នានៃវប្បធម៌ វាពិបាកក្នុងការកំណត់រួមគ្នាជាសកល ថាតើខ្លឹមសារណាដែលមិនល្អ។ ប៉ុន្តែកិច្ចព្រមព្រៀងអំពីអ្វីដែលខុសច្បាប់និងបង្កគ្រោះថ្នាក់ ទទួលបានលទ្ធផលប្រសើរជាង។ រូបអាសគ្រាមកុមារគឺជាអ្វីដែលយើងនឹកដល់។

ការសំរបសំរួលអន្តរជាតិតាមរយៈ ភ្នាក់ងារពង្រឹងច្បាប់ បានដើរតួជាអ្នកត្រួតពិនិត្យការរីករាលដាលនៃរូបអាសគ្រាមកុមារ។ ភ្នាក់ងារពង្រឹងច្បាប់បានធ្វើកិច្ចសហប្រតិបត្តិការបោសសំអាតខ្លឹមសារខុសច្បាប់ទាំងនេះ។ កាលពីចុងទស្សវត្សឆ្នាំ ១៩៩០ កន្លងទៅថ្មីៗនេះ រូបអាសគ្រាមកុមារភាគច្រើនបានថតចំលងចេញពីរូបថតខាងក្រៅ។ ប៉ុន្តែអ៊ីនធឺណែតអាចឲ្យរូបភាពត្រូវបានបញ្ជូនដោយផ្ទាល់ តាមរយៈ webcam។ ដើម្បីបញ្ឈប់ការរំលោភបំពានបែបនេះ ភ្នាក់ប៉ូលីសបានដាក់មុខសញ្ញាលើមនុស្សដែលយករូបភាពនោះចេញពីអ៊ីនធឺណែត។ មានយុទ្ធនាការសំរបសំរួលជាន់ខ្ពស់ជាច្រើនត្រូវបានធ្វើឡើងក្នុងឆ្នាំ ១៩៩៨ (ឈ្មោះ Operation Cathedral) និង ឆ្នាំ ១៩៩៩ (ឈ្មោះ Operation Ore) ដែលនាំទៅរកការចាប់ខ្លួនមនុស្សរាបសិបនាក់ ក្នុងប្រទេសជាច្រើន។

(សំរាប់ព័ត៌មានបន្ថែម សូមមើលរបាយការណ៍ WGIG (ឈ្មោះ Background Report ឆ្នាំ ២០០៥កថាខណ្ឌ ១៩១) http://www.wgig.org ។

## សន្តិសុខ

បញ្ហានេះទទួលបានការចាប់អារម្មណ៍កាន់តែខ្លាំង ដោយសារដង្កូវព្យាបាទ (worm) វីរុស (virus) និងកម្មវិធីព្យាបាទ (Trojan horse) ដែលមានលើអ៊ីនធឺណែតកាន់តែមានភាពសាំញ៉ាំ។

### វីរុស ILoveYou

នេះជាវីរុសដែលបំផ្លិចបំផ្លាញប្រព័ន្ធកុំព្យូទ័រខ្លាំងជាងគេ ដែលមិនធ្លាប់មាន ព្រមទាំងរីកសុះសាយយ៉ាងលឿន ដែលធ្វើឲ្យភ្នាក់ងារដូចជា វិមាន Pentagon អាមេរិច ភ្នាក់ងារស៊ើបអង្កេតកណ្តាល (CIA) និង សភាអង់គ្លេស ត្រូវតែបិទ server អ៊ីម៉ែលរបស់ខ្លួន ដើម្បីជៀសវាងមិនឲ្យឆ្លងវីរុសនេះ។ វីរុសនេះរាលដាលយ៉ាងលឿន ដោយសារវាបានបង្កើតខ្លួនឯង និងធ្វើដំណើរទៅរកអាស័យដ្ឋានអ៊ីម៉េល ដែលមាននៅក្នុងសៀវភៅអាស័យដ្ឋាននៃ Microsoft Outlook ក្នុងម៉ាស៊ីនកុំព្យូទ័ររបស់អ្នកប្រើប្រាស់។ ដោយសារតែទទួលបានអ៊ីម៉េលពីមិត្តភក្តិ អ្នកប្រើប្រាស់បានចុចបើកអ៊ីម៉េលទាំងនោះ ដែលនាំឲ្យឆ្លង និងចំលងវីរុសបន្តទៅម៉ាស៊ីនដទៃទៀត។

ទោះជាបានបង្កការខូចខាតមហិមា ទៅលើប្រព័ន្ធកុំព្យូទ័រទូទាំងពិភពលោក អ្នកបង្កើតវីរុសនេះបានរួចខ្លួនពីការដាក់ទណ្ឌកម្មផ្សេងៗ បើទោះជាគេបានដឹងអ្នកនោះជានរណាក៏ដោយ។ នៅពេលដែលវីរុសនោះផ្សព្វផ្សាយដំបូងក្នុងឆ្នាំ ២០០០ ពុំមានច្បាប់ក្នុងប្រទេសហ្វីលីពីន ដែលជាប្រទេសដែលគាត់រស់នៅនោះឡើយ ដើម្បីប្រឆាំងនឹងការផ្សព្វផ្សាយវីរុសកុំព្យូទ័រនេះ។ ក្នុងខែ មិថុនា ឆ្នាំ ២០០០ ច្បាប់ e-commerce ដែលគេបាននឹងកំពុងចងក្រង ត្រូវបានអនុម័ត។ វាមានលក្ខន្តិកៈដែលដាក់ការផ្សព្វផ្សាយវីរុសជាបទឧក្រិដ្ឋ។

ប្រភព៖ Peng Hwa Ang □ការត្រួតពិនិត្យអ៊ីនធឺណែតអាស៊ី□ Asian Wall Street Journal ថ្ងៃទី ៧ កញ្ញា ២០០០

អ្វីដែលសំខាន់នោះគឺថា បញ្ហាសន្តិសុខ គឺជា៖

- របៀបការពារប្រឆាំងនឹងការបំផ្លាញសន្តិសុខក្នុងប្រព័ន្ធកុំព្យូទ័រ និងបណ្តាញ
- របៀបរាំងបទឧក្រិដ្ឋក្នុងបរិស្ថានឌីជីថល

*មេរៀនទី៦ ក្នុងក្រុមមេរៀន Acedemy of ICT Essentials for Government Leaders គឺនិយាយអំពី សន្តិសុខ និងភាពឯកជននៃព័ត៌មាននិងបណ្តាញ។*

**កម្មសិទ្ធិបញ្ញា**

ពិភពឌីជីថលអាចឲ្យគេធ្វើរបស់ចំលងដូចគ្នាបេះបិទទៅនឹងរបស់ពិត ដោយមិនមានការថយចុះគុណភាពដូចនៅក្នុងពិភពអាណាឡូក (analog) ឡើយ។ ប៉ុន្តែភាពងាយស្រួលក្នុងការចំលងមានគុណភាពឥតខ្ចោះនេះហើយ ដែលធ្វើឲ្យវាមានភាពងាយស្រួលរំលោភលើកម្មសិទ្ធិបញ្ញា។

ដូចនេះរបបសម័យទំនើបនៃកម្មសិទ្ធិបញ្ញាត្រូវប្រឈមដោះស្រាយបញ្ហាដូចខាងក្រោម៖

- របៀបពន្លាតរបបកម្មសិទ្ធិបញ្ញាបច្ចុប្បន្នដើម្បីបញ្ចូលស្នាដៃឌីជីថល
- របៀបទទួលបាន ការការពារ និងគ្រប់គ្រងសិទ្ធិក្នុងមជ្ឍដ្ឋានឌីជីថល
- របៀបរាំងការលួចចំលងដោយខុសច្បាប់ នៃស្នាដៃដែលមានការរក្សាសិទ្ធិ

## ការលួចចំលងចំរៀងដោយខុសច្បាប់

ចំរៀងប្រហែលជាខ្លឹមសារដែលត្រូវបានលួចចំលងដោយខុសច្បាប់ខ្លាំងជាងគេក្នុងពិភពលោក។ ខណៈដែល ការលក់ iPod និងឧបករណ៍លេងតន្ត្រីដទៃទៀតមានចំនួនកាន់តែកើនឡើង ការលក់ cd ចំរៀងនៅតែបន្តធ្លាក់ចុះប៉ុន្មានឆ្នាំនេះ។ អ្វីដែលធ្វើឲ្យអំពើខុសច្បាប់នេះកាន់តែមានសន្ទុះគឺជាការចែកចាយយ៉ាងផុសផុលនៃចំរៀងដែលយកចេញពីអ៊ីនធឺណែតដោយប្រើកម្មវិធី peer-to-peer។

ផ្ទុយពីការយល់ច្រលំភាគច្រើន អ្នកដែលចែកចាយចំរៀងតាមប្រព័ន្ធអ៊ីនធឺណែត អាចត្រូវបានគេរកឃើញ និងដាក់ទោស។ ការយល់ច្រលំនេះប្រហែលបណ្តាលមកពីទស្សនៈដែលយល់ថាការប្រើប្រាស់កម្មវិធី peer-to-peer ដូចជា BitTorrent និង LimeWire អាចឲ្យអ្នកប្រើប្រាស់ទាញយកបទចំរៀងពីអ្នកប្រើប្រាស់ដទៃទៀត។ ដូច្នេះ បុគ្គលម្នាក់អាចបញ្ជូនបទចំរៀងមួយ ទៅឲ្យមនុស្សដទៃទៀតជាច្រើន ក្នុងលក្ខណៈជាការរកទីផ្សារផលិតផលតាមអ៊ីនធឺណែត។

ម្ចាស់បទចំរៀងបានធ្វើការប្រឆាំងតទល់ ហើយអ្វីដែលក្លាំងក្លានោះគឺជាការបង្កើតសមាគមន៍ឧស្សាហកម្មថតសំឡេងអាមេរិច (RIAA)។ RIAA បានដាក់ទោសនិស្សិតជាច្រើន ទោះជាដឹងថាពួកគេជាក្រុមដែលមិនសូវមានលុយកាក់ ដើម្បីទុកជាមេរៀនដល់អ្នកដទៃទៀត។ មានរបាយការណ៍ខ្លះបានបញ្ជាក់ថា RIAA ថែមទាំងបញ្ចុះបញ្ចូលនិស្សិតឲ្យឈប់រៀនដើម្បីធ្វើការរកលុយសងបំណុល។

## ការងារត្រូវធ្វើ

ចូររកច្បាប់ និងវិធានការដទៃទៀត ដែលការពារសិទ្ធិអ្នកនិពន្ធក្នុងប្រទេសរបស់អ្នក។ ចូរវាយតំលៃពីប្រសិទ្ធិភាពរបស់ពួកវានៅក្នុងមជ្ឈដ្ឋានឌីជីថល (មានន័យថា នៅពេលមានវត្តមាន នៃការអភិវឌ្ឍន៍បច្ចេកវិទ្យាឌីជីថល)។

**ភាពជាឯកជន**

វិធានការការពារភាពជាឯកជនក្លាំងក្លាជាងគេនោះ គឺជាបទបញ្ញាការពារទិន្នន័យរបស់សហគមន៍អ៊ឺរ៉ុប (EU) ដែលទាមទារឲ្យភាគីទី៣ ត្រូវមាន "កំរិតការពារទិន្នន័យស្មើគ្នា" នឹងខ្លួន ទើបអាចធ្វើប្រតិបត្តិការលើទិន្នន័យទាញចេញពី EU បាន។ ប៉ុន្តែ ការយកវិធានការនេះមកអនុវត្ត ត្រូវបានពន្យារដោយសារភាពស្ទាក់ស្ទើររបស់អាមេរិច ក្នុងការទទួលយកវិធានការស្រដៀងគ្នានឹងអ្វីដែលខ្លួនមាន។ អាមេរិចបានផ្តល់នូវវិធានការដែលមានលក្ខណៈថ្មៃប្រឌិត ដែលមានឈ្មោះថាលក្ខន្តិកៈ "កំពង់សុវត្ថិភាព" (safe habour) ដែលអនុញ្ញាតិឲ្យអ្នកណាដែលប្រកាន់យកវិធានការនេះ ត្រូវបានចាត់ទុកស្ថិតនៅក្នុង safe habour និង បានគោរពតាមវិធានការ។

អង្គការសំរាប់ការសំរបសំរួលសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ (OECD) ក៏បានអភិវឌ្ឍគោលការណ៍ណែនាំស្តីពីភាពឯកជននេះផងដែរ ដែលមានគោលបំនងបន្ធូរបន្ថយការទាមទារ បើប្រៀបធៀបទៅនឹងគោលជំហររបស់ EU[21] ។

ចំនុចសំខាន់នៃការដាក់បទបញ្ញាលើភាពជាឯកជន គឺរបៀបដាក់បទបញ្ញាលើការប្រើប្រាស់ព័ត៌មាន ឯកជនដោយស្ថាប័នឯកជននិងសាធារណៈ។

[21] OECD. "សេចក្តីណែនាំរបស់ OECD ស្តីពីការការពារភាពជាឯកជន និងលំហូរព័ត៌មានបុគ្គលឆ្លងកាត់ព្រំដែន" "OECD Guidelines on the Protection of Privacy and Transborder Flows of Personal Data," http://www.oecd.org/document/18/0,2340,es_2649_34255_1815186_1_1_1_1,00.html.

## ការបំពេញតាមស្តង់ដាអឺរ៉ុប

គោលជំហររបស់ EU ស្តីពីភាពជាឯកជន គឺមានការគិតគូរដិតដល់។ ផ្នែកមួយនៃគោលការណ៍នេះ គឺតំរូវឲ្យប្រទេសណាមួយដែលចង់បានទិន្នន័យពី EU ត្រូវតែមានកំរិតការពារទិន្នន័យដូចគ្នានឹង EU ដែរ។ ក្នុងស្ថានភាពជាក់ស្តែង ក៏មានការលើកលែងផងដែរ ដូចជាព័ត៌មានអាកាសចរណ៍។ ប៉ុន្តែ គោលនយោបាយរបស់ EU មានឥទ្ធិពលបង្ខំឲ្យប្រទេសជាច្រើនកែតំរូវច្បាប់ការពារទិន្នន័យរបស់គេដើម្បីបំពេញតាមស្តង់ដានេះ។

អ្វីដែលមិនចាំបាច់ចោទសួរនោះ គឺស្តង់ដា EU ធ្វើឲ្យមានការចំណាយមួយចំនួន ដែលធ្វើឲ្យគេអាចយល់បានថា សហគមន៍ជំនួញព្យាយាមបំពេញតាមស្តង់តានេះក្នុងកំរិតជាអប្បបរិមា តាមដែលអាចធ្វើទៅបាន។

សហរដ្ឋអាមេរិចបានដាក់ចេញនូចស្តង់ដា safe habour ដែលមួយផ្នែកត្រូវបានសំរបសំរួលដោយរដ្ឋាភិបាលអាមេរិច បើទោះជាស្តង់ដានេះទំនងជាផ្តួចផ្តើមឡើងដោយផ្នែកឯកជន។ វាបង្កលក្ខណៈឲ្យក្រុមហ៊ុនទាំងឡាយណាដែលគោរពតាម safe habour អាចមានសិទ្ធិទទួល និងប្រតិបត្តិការលើទិន្នន័យពី EU។

នៅប្រទេសអូស្ត្រាលី រដ្ឋាភិបាលបានព្យាយាមកែតំរូវច្បាប់ស្តីពីភាពឯកជនរបស់ខ្លួនដើម្បីអាចលក្ខណៈ □ស្មើគ្នា□ នឹង EU ប៉ុន្តែបំណងនេះត្រូវបង្អាក់ដោយការចៃចូររបស់ក្រុមហ៊ុនជំនួញ ដែលជាមូលហេតុធ្វើឲ្យការការពារមួយចំនួននៅខ្វះខាត។

ដូច្នេះ គួរមានការធ្វើឲ្យមានតុល្យភាពរវាងប្រយោជន៍ក្រុមហ៊ុនជំនួញ និងការគោរព ស្តង់ដា EU ស្តីពីការការពារភាពឯកជន។

គណកម្មាធិការអ៊ឺរ៉ុបមានគេហទំព័រស្តីពីការការពារទិន្នន័យនៅ http://ec.europa.eu/justice_home/fsj/privacy/index_en.htm ដែលឲ្យយើងរកបានព័ត៌មានបន្ថែមអំពីភាពឯកជន។

## សរុបសេចក្តី

បណ្តានីតិវិធីដោះស្រាយទាក់ទងនឹងបញ្ហាអ៊ីនធឺណែត ដែលបានបង្ហាញខាងលើ គឺផ្អែកទៅលើក្រឹត្យក្រមអន្តរជាតិ ព្រោះថាអ៊ីនធឺណែតមានវិសាលភាពជាអន្តរជាតិ ហើយគ្មានប្រទេសណាអាចផ្តាច់ខ្លួនពីសហគមន៍អន្តរជាតិឡើយ។ លើសពីនេះទៅទៀត វាសំខាន់ណាស់ក្នុងការពិភាក្សាជាមួយបណ្តាអ្នកពាក់ព័ន្ធដូចជា ឧស្សាហកម្ម និងសង្គមស៊ីវិលឲ្យបានទូលំទូលាយ ដើម្បីឲ្យពួកគេជ្រាប ជាព័ត៌មានក៏ដូចជាអាចអប់រំបន្តដល់សហគមន៍មូលដ្ឋាន។

### ការងារត្រូវធ្វើ

ចូរធ្វើការសំរេចចិត្ត ថាតើការដាក់ចំណាត់ថ្នាក់នៃក្រុមនៃបញ្ហាខាងលើមានភាពសមស្របក្នុងបរិបទប្រទេសរបស់អ្នកឬទេ? បើអ្នកមានអារម្មណ៍ថាមិនសមស្របទេនោះ ចូរស្នើរពីរបៀបសំរាប់រៀបចំណាត់ថ្នាក់នៃក្រុមបញ្ហាទាំងនោះ ដោយគិតពីកំរិតនៃភាពសំខាន់ ក្នុងប្រទេសរបស់អ្នក ព្រមទាំងលើកយោបល់ការពារការស្នើររបស់អ្នក។

### សាកល្បងខ្លួនឯង

១. តើវិធីសាស្ត្រទាំង ៤ ក្នុងការដាក់បទបញ្ហាលើអ៊ីនធឺណែតមានអ្វីខ្លះ? តើវិធីសាស្ត្រនិមួយៗមានចំនុចខ្វះខាតអ្វីខ្លះ ក្នុងការដាក់បទបញ្ហាលើអ៊ីនធឺណែត?

២. ក្បួនទាំងអស់ដែលមានក្នុងមេរៀន គ្រាន់តែជាការនាំផ្លូវដែលបានស្នើរឡើងប៉ុណ្ណោះ។ តើដំណាក់កាលដែលបានណែនាំ ក្នុងក្បួននេះមានអ្វីខ្លះ?

# ៤.ទំហំនៃការអភិបាលប្រព័ន្ធអ៊ីនធឺណែត២៖ ការប្រើប្រាស់អ៊ីនធឺណែតមិនត្រឹមត្រូវ

ផ្នែកនេះមានគោលបំណងបង្កើនការយល់ដឹងអំពីការប្រើប្រាស់អ៊ីនធឺណែតមិនត្រឹមត្រូវដែលយើងជួបប្រទះជារឿយៗ និងការចាត់វិធានការដើម្បីដោះស្រាយ។

## ៤.១ តើមានអ្វីពិសេសជាមួយប្រព័ន្ធអ៊ីនធឺណែត

មនុស្សមួយចំនួនគិតថាអ៊ីនធឺណែតគ្រាន់តែជាការឆ្លុះបញ្ចាំងសង្គមខាងក្រៅ ដូចនេះវាមិនចាំបាច់មានក្រឹត្យក្រមពិសេសណាមួយឡើយ។ ប៉ុន្តែទស្សនៈនេះមិនបានគិតដល់លក្ខណៈពិសេសមួយចំនួនរបស់អ៊ីនធឺណែត។

ទីមួយ, អ៊ីនធឺណែតបង្កភាពងាយស្រួលសំរាប់ភាពអានាមិក។ ប្រាកដណាស់ គេពិតជាអាចតាមដានរកអ្នកប្រើប្រាស់ល្មើសបាន ប៉ុន្តែគេត្រូវចំណាយយ៉ាងពិសេសទៅលើធនធាន និងការប្រឹងប្រែង។ ចំនុចខ្លាំងនៃភាពអានាមិក គឺជាការបើកចំហរ ដោយស្មោះត្រង់ នៅក្នុងទំនាក់ទំនងទាក់ទងនឹងបញ្ហាដូចជាស្ថានភាពសុខភាព។ ដោយឡែក ភាពអនាមិកក៏អាចជាទីសំអាងរបស់ឧក្រិដ្ឋជនផងដែរ។

ទី២, មានវប្បធម៌អានាធិបតេយ្យ គ្មានច្បាប់នៅលើអ៊ីនធឺណែត ដែលដូចទៅនឹងអ្វីដែលលោក John Perry Barlow បានធ្វើសេចក្តីប្រកាសមានចំណងជើងថា "ឯករាជ្យភាពនៃទំនាក់ទំនងលើ អ៊ីនធឺណែត" ៖

> បណ្តារដ្ឋាភិបាលនៃប្រទេសឧស្សាហកម្ម ដែលជាយក្សគ្មានកំលាំង ខ្ញុំមកពីពិភពអ៊ីនធឺណែតដែលជាកន្លែងបង្កើតទស្សនៈថ្មីៗ។ ក្នុងនាមជាអ្នកតំណាងអនាគតកាល ខ្ញុំសុំឲ្យពួកអ្នកដែលជាតំណាងអតីតកាល ទុកកន្លែងឲ្យខ្ញុំនៅតែម្នាក់ឯង។ យើងមិនស្វាគមន៍អ្នកឡើយ។ អ្នកគ្មានអធិបតេយ្យភាពនៅទីកន្លែងដែលពួកខ្ញុំជួបជុំគ្នាឡើយ។[22]

[22] លោក John Perry Barlow, សេចក្តីប្រកាសស្តីពីឯករាជ្យភាពនៃទំនាក់ទំនងលើអ៊ីនធឺណែត “A Declaration of the Independence of Cyberspace” (8 February 1996),http://homes.eff.org/~barlow/Declaration-Final.html.

ប្រាកដណាស់ដែលថាសេចក្តីប្រកាសនេះ គ្រាន់តែជាការស្រមើស្រម៉ៃមិនអាចក្លាយជាការពិត ដែលបានឆ្លុះបញ្ចាំងពីការយល់ច្រលំទៅលើអំណាចច្បាប់ ព្រោះថាច្បាប់មិនគ្រប់គ្រងទីកន្លែងណាមួយទេ គឺគ្រប់គ្រងមនុស្សទាំងអស់ដែលនៅក្នុងកន្លែងនោះ។ ដរាបណាមានវត្តមានមនុស្ស តំរូវការច្បាប់ ត្រូវតែមានដើម្បីដើរតួនាទីជាអ្នកមានឥទ្ធិពល និងកាតាលីករសង្គមជួយកាត់បន្ថយកំហុសឆ្គងមនុស្សជាអប្បបរិមា។

ទី៣, ដូចដែលយើងបាននឹងកំពុងចាប់ផ្តើមស្វែងយល់ អ៊ីនធឺណែតគឺជាឧបករណ៍ទំនាក់ទំនងដ៏មានឥទ្ធិពល។ សមត្ថភាពនេះ ដូចដែលបានបង្ហាញឲ្យឃើញតាមរយៈគេហទំព័រទំនាក់ទំនងសង្គមដូចជា MySpace និង FaceBook គឺត្រូវបានគេស្គាល់ជា Web 2.0។ មកទល់នឹងពេលនេះ Web 2.0 ធ្វើឲ្យក្រុមទំនាក់ទំនងតូចៗជាច្រើនរួបរួមគ្នា ក្លាយជាសហគមន៍នៅពាសពេញពិភពលោក។ barefoots.org គឺជាឧទាហរណ៍ ដែលសមាជិកក្រុមបានដើរដោយជើងទទេរ លើកលែងតែក្នុងឱកាសផ្លូវការប៉ុណ្ណោះ។ ក្នុងឆ្នាំ ១៩៩៩ មានសមាជិកក្រុមនេះចំនួនតែ ៤០០ នាក់ប៉ុណ្ណោះ ទូទាំងពិភពលោក។ ប្រហែលឆ្នាំ ២០០៧ ចំនួនសមាជិកក្រុមកើនឡើងដល់ ២០០០ នាក់ក្នុងបណ្តាប្រទេសមួយចំនួន។ ក្នុងខ្នាត ពិភពលោក ក្រុមនេះអាចទាក់ទាញមនុស្សឲ្យគាំទ្រ ច្រើនគ្រប់គ្រាន់ដើម្បីមានផ្លាកសំគាល់ផ្ទាល់ខ្លួន។

ក្នុងរបៀបដូចគ្នានេះដែរ អ៊ីនធឺណែតអាចធ្វើឲ្យមានការបង្កើតជាក្រុមមនុស្សប្រព្រឹត្តិមិនល្អ ដែលបង្កបញ្ហាដូចពិភាក្សាខាងក្រោម។

## ៤.២ ការប្រើប្រាស់អ៊ីនធឺណែតមិនត្រឹមត្រូវ

### រូបអាសគ្រាមកុមារ

មុនដំបូង រូបអាសគ្រាមកុមារគឺជាការចំលងពីរូបភាពលើក្រដាសឲ្យទៅជាឯកសារទន់។ ប៉ុន្តែនៅពេលបច្ចេកវិទ្យាកាន់តែរីកចំរើន គេអាចទទួលបានរូបភាពអាសគ្រាមទាំងនេះតាមតំរូវការ។ [23]

វាតំរូវឲ្យមានជាចាំបាច់នូវកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីប្រឆាំងក្រុមឧក្រិដ្ឋជនដែលជំរុញការបង្កើតរូបអាសគ្រាមកុមារ។ ការចុះឆ្មក់ និងចែកចាយព័ត៌មានឲ្យគ្នារវាងប្រទេសជាច្រើនក្នុងពេលដំណាលគ្នា ក្នុងយុទ្ធនាការ Catherdral ក្នុងឆ្នាំ ១៩៩៩ និងយុទ្ធនាការ Ore ក្នុងឆ្នាំ ២០០២ ត្រូវបានធ្វើឡើងដោយ

[23] លោក Ethel Quayle and Max Taylor, *រូបអាសគ្រាមកុមារ៖ បទឧក្រិដ្ឋលើអ៊ីនធឺណែត Child Pornography: An Internet Crime* (New York: Brunner-Routledge, 2003).

Interpol។[24] កិច្ចសហប្រតិបត្តិការអន្តរជាតិអាចនឹងធ្វើទៅបាន ដោយសារការផលិតនិងចែកចាយរូបអាសគ្រាមកុមារនេះ គឺជាប្រធានបទមួយក្នុងចំណោមប្រធានបទតិចតួចដែលត្រូវបានប្រទេសស្ទើរទាំងអស់ព្រមព្រៀងគ្នាថាជាអំពើខុសច្បាប់។

## ការឆបោកអ្នកប្រើប្រាស់

អ៊ីនធឺណែតបានបង្ហាញឲ្យឃើញថាច្បាប់សង្គមខាងក្រៅ ត្រូវមានការកែតំរូវដើម្បីឲ្យវិស័យនេះដំណើរការបាន។ ច្បាប់នៃការដេញថ្លៃគឺជាឧទាហរណ៍មួយ។ នៅប្រទេស Commonwealth ភាគច្រើន ការដេញថ្លៃអាចធ្វើទៅបាននៅពេលមានវត្តមានជារូបវន្តរបស់បុគ្គល ដែលមានអាជ្ញាបណ្ណដឹកនាំ ការដេញថ្លៃនោះ។ បើពិនិត្យមួយភ្លែត ច្បាប់នេះហាក់ដូចជាបុរាណណាស់។ ឧទាហរណ៍ វាមានន័យថាអ្នកដឹកនាំការដេញថ្លៃនៅលើគេហទំព័រ eBay ត្រូវតែមានការត្រួតពិនិត្យជាមុន ថាតើគេ មានអាជ្ញាបណ្ណឬទេ។ ក៏ប៉ុន្តែគោលគំនិតនៃច្បាប់នេះបានសបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ភ្លាមៗ នៅពេលមានវត្តមាននៃការដេញថ្លៃតាមអេឡិចត្រូនិច និងការកកើតឡើងនៃការដេញថ្លៃបោកប្រាស់ញឹកញាប់ជាងគេក្នុងចំណោមអំពើឆបោកទាំងអស់លើប្រព័ន្ធអ៊ីនធឺណែត[25]។

ការឆបោកអ្នកប្រើប្រាស់គឺជាចំនុចមួយទៀតដែលស្ទើរតែមានការព្រមព្រៀងជាសកល ថាអំពើនេះគួរតែត្រូវបញ្ឈប់។ ការបង្ក្រាបអំពើឆបោកទាំងនេះ គឺពិតជាអាចធ្វើឲ្យសេវាអ៊ីនធឺណែតកាន់តែ ប្រសើរ។ ចាប់ពីឆ្នាំ ១៩៩៦ មក មានយុទ្ធនាការបោសសំអាតអំពើទាំងនេះជារៀងរាល់ឆ្នាំ។ ចំនួនប្រទេសចូលរួមយុទ្ធនាការនេះកាន់តែកើនឡើងជាលំដាប់។

[24] សូមមើល Ang (2005)

[25] សូមមើល Ang (2005)

### ការលុបបំបាត់គេហទំព័រខុសច្បាប់ប្រចាំឆ្នាំ

មានប្រទេសចំនួនប្រហែល ៤០ បានរួបរួមគ្នាដើម្បីដោះស្រាយអំពើឆបោកលើប្រព័ន្ធអ៊ីនធឺណែត ដោយបង្កើតជាបណ្តាញពង្រឹងនិងការពារអ្នកប្រើប្រាស់អន្តរជាតិ (ICPEN)។ បណ្តាញនេះបានប្រារព្ធទិវាបោសសំអាតជារៀងរាល់ឆ្នាំ ដើម្បីស្វែងរកជាពិសេសនូវគេហទំព័រឆបោក។

គួរចងចាំថា ការបោសសំអាតនេះមានប្រសិទ្ធភាព លុះត្រាច្បាប់ផ្តល់ការគាំទ្រនិងការពារអ្នកប្រើប្រាស់។ ដូច្នេះ បើប្រទេសមួយកាន់តែអភិវឌ្ឍ ការបោសសំអាតនេះកាន់តែសកម្ម។

### សំនួរពិចារណា

តើច្បាប់ប្រឆាំងនឹងរូបអាសគ្រាមកុមារ
និងអំពើឆបោកអ្នកប្រើប្រាស់មានប្រសិទ្ធភាពកំរិតណា នៅក្នុងប្រទេសរបស់អ្នក?

## អ៊ីម៉េល spam គំរោងការណ៍ឆបោក កូដព្យាបាទ ការក្លែងបន្លំលួចព័ត៌មានផ្ទាល់ខ្លួន

បញ្ហាដែលធ្វើឲ្យមានការពង្រឹងជាបន្តបន្ទាប់តាមផ្លូវនយោបាយនិងពាណិជ្ជកម្មគឺ អ៊ីម៉េល spam ឬពំនូកអ៊ីម៉េលពាណិជ្ជកម្មសំរាម ក៏ព្រោះតែ spam ធ្វើឲ្យមានការខ្ជះខ្ជាយទំហំបញ្ជូនទិន្នន័យ។ សំខាន់ជាងនេះទៅទៀត spam អាចនាំមកជាមួយនូវកូដព្យាបាទ និងអនុញ្ញាតិឲ្យមានការក្លែងបន្លំលួចព័ត៌មាន

ផ្ទាល់ខ្លួនសំខាន់ដូចជា ឈ្មោះអ្នកប្រើប្រាស់ លេខសំងាត់ និងព័ត៌មានលំអិតអំពី កាដក្រេឌីត ដោយប្រើមធ្យោបាយធ្វើឲ្យអ្នកប្រើប្រាស់មានទំនុកចិត្តក្នុងការផ្តល់ព័ត៌មាន។[26]

ដោយសារមានប្រភពចេញពីសាកលវិទ្យាល័យ អ៊ីនធឺណែតបានកកើតឡើងជាមួយនឹងការបើក ទូលាយ និងវប្បធម៌ជឿទុកចិត្តគ្នា។ កាលពីដើមឡើយ នៅពេលដែលអ្នកប្រើប្រាស់ (ភាគច្រើនមានមូលដ្ឋាន នៅសាកលវិទ្យាល័យ) ផ្ញើសារទៅឲ្យអ្នកដទៃ ភាគច្រើននៃអ្នកទាំងនោះបានភ្ជាប់ជាមួយនូវលេខទូរស័ព្ទ នៅបន្ទាប់ពីហត្ថលេខា ដើម្បីបញ្ជាក់ពីការទទួលខុសត្រូវលើអ្វីដែលខ្លួនបានផ្ញើ។ សព្វថ្ងៃនេះ ក្នុងបរិបទ ដ៏ធំធេងនៃអ៊ីនធឺណែត ការផ្តល់លេខទូរស័ព្ទរបស់ខ្លួនបែបនេះនៅក្នុងអ៊ីម៉េល នឹងងាយទាក់ទាញការ វាយប្រហារគ្រប់ប្រភេទ។

Spam ដែលត្រូវបានផ្ញើដំបូងគេ គឺប្រហែលធ្វើឡើងដោយអ្នកតំណាងទីផ្សារនៃសាជីវកម្មបរិក្ខាឌីជីថល (DEC) ដែលផលិតកុំព្យូទ័រខ្នាតធំមធ្យម (mini-computer)។ កាលនោះ វាគឺជាអ៊ីម៉េលផ្សព្វផ្សាយ ព័ត៌មានផលិតផល ដែលធ្វើឲ្យអ្នកប្រើប្រាស់បានត្អូញត្អែ រហូតដល់មានការចាត់វិធានការចំពោះអ្នក ចរាចរណ៍អ៊ីម៉េលនេះ ខុសគ្នាទៅនឹងសម័យបច្ចុប្បន្នដែលអ្នកពង្រាយ spam មិនងាយនឹងត្រូវបានគេ រកឃើញឡើយ។[27]

បើទោះជាពាក្យ spam នេះត្រូវបានគេស្គាល់យ៉ាងទូលំទូលាយជាមួយនឹងអ៊ីម៉េល ពាក្យនេះក៏អាចប្រើ ជាមួយសេវាសារព័ត៌មាននៅលើអ៊ីនធឺណែតដទៃៗទៀតផងដែរដូចជា សេវាទទួលសារភ្លាមៗ, ក្រុម សារព័ត៌មាន Usenet, ក្បាលម៉ាស៊ីនស្វែងរកគេហទំព័រ, blog, wiki, ការផ្ញើសារតាមទូរស័ព្ទដៃ និង game។ តាមនិយមន័យអន្តរជាតិ អ៊ីម៉េល spam គឺជាអ៊ីម៉េលដ៏ច្រើនដែលទទួលបានដោយមិនបាន ស្នើសុំ ដែលអ៊ីម៉េលនិមួយៗគឺជាផ្នែកមួយនៃសំនុំអ៊ីម៉េលខ្លួនវា ដែលបញ្ជូនទៅអ្នកទទួលដែលមិនបានដឹងខ្លួន ជាមុន។ ដូច្នេះ spam គឺជាបញ្ហានៃការយល់ព្រមឬមិនយល់ព្រម មិនមែនទាក់ទងនឹងបញ្ហា ខ្លឹមសារឡើយ។[28] នេះមានន័យថា ការធ្វើបទបញ្ញត្តិដើម្បីដោះស្រាយបញ្ហា spam គួរគិតពី ការយល់ព្រមឬមិនយល់ព្រមទទួល មិនមែនខ្លឹមសារឡើយ។

---

26 គេហទំព័រ Wikipedia, “ការបោកបញ្ឆោតយកព័ត៌មានផ្ទាល់ខ្លួន” “Phishing,” Wikipedia Foundation, Inc., http://en.wikipedia.org/wiki/Phishing.

27 លោក Brad Templeton, “ការប្រតិកម្មទៅនឹង Spam របស់ក្រុមហ៊ុន DEC ក្នុងឆ្នាំ ១៩៧៨” “Reaction to the DEC Spam of 1978,” http://www.templetons.com/brad/spamreact.html.

28 លោក Spamhaus, “និយមន័យរបស់ Spam” “The Definition of Spam,” http://www.spamhaus.org/definition.html.

### Spam Spam តើវាបញ្ចប់នៅពេលណា

ច្បាប់ដំបូងគេដែលមានគោលបំណងដោះស្រាយបញ្ហា spam គឺជាលក្ខន្តិកៈ CAN-SPAM របស់អាមេរិច ដែលបង្កើតឡើងក្នុងឆ្នាំ ២០០៣។ វាមានឈ្មោះពេញថា៖ លក្ខន្តិកៈនៃការគ្រប់គ្រងការវាយប្រហាររបស់រូបអាសគ្រាមនិងការផ្សាយពាណិជ្ជកម្ម (Controlling the Assault of Non-Solicited Pornography and Marketing Act)។ លក្ខន្តិកៈនេះបានផ្តល់ អំណាចផ្លូវច្បាប់ដល់ប្រជាពលរដ្ឋ ព្រមទាំងត្រូវបានគេប្រើសំរាប់ដាក់ទោសអ្នកពង្រាយ spam ដែលគេបានស្គាល់ជាច្រើន ក្នុងសហរដ្ឋ អាមេរិច។ ការវាយតំលៃលើលក្ខន្តិកៈត្រូវបានធ្វើឡើងក្នុងឆ្នាំ ២០០៥ ដោយពុំមាន ការកែប្រែគួរឲ្យកត់សំគាល់ណាមួយទៅលើ ខ្លឹមសារលក្ខន្តិកៈនេះឡើយ។ ទោះជា យ៉ាងណាក៏ដោយ អាមេរិចនៅតែស្ថិតនៅជួរមុខគេ ឬលំដាប់ទី២ ក្នុងចំណោម ប្រទេសដែលមាន spam។ ប្រទេសចិន និងសាធារណរដ្ឋកូរ៉េ ក៏ស្ថិតក្នុងលំដាប់ ខ្ពស់ផងដែរ។

គេសង្កេតឃើញថា spam បានកកើតកាន់តែច្រើន នៅទីណាដែលភាពលូតលាស់នៃវិស័យអ៊ីនធឺណែតកាន់តែខ្លាំង ដូចករណីសាធារណរដ្ឋកូរ៉េ ម៉្យាងវិញទៀតកន្លែងណាដែលច្បាប់និងការពង្រឹងច្បាប់នៅមានភាពទន់ខ្សោយ ក៏បណ្តាលឲ្យមាន spam ច្រើនផងដែរ ដូចករណីប្រទេសចិន។

សម្ព័ន្ធផ្នែកជំនួញ និងផ្នែកច្បាប់ កំពុងធ្វើការដោះស្រាយបញ្ហា spam តាមរយៈគំរោងផែនការទីក្រុងឡុង (http://www.londonactionplan.org) និងការបង្កើតសម្ព័ន្ធបញ្ឈប់ spam (http://stopspamalliance.org)។ គេហទំព័ររបស់ពួកគេទាំងនេះមានព័ត៌មានលំអិតអំពី spam ព្រមទាំងព័ត៌មានថ្មីៗអំពីមេរៀនល្អៗ និងសកម្មភាពរបស់ពួកគេ។

## កាសម្លុត ការលួចតាមដាន ការលួចអត្តសញ្ញាណ និងការងប់ងល់ជាមួយនឹងអ៊ីនធឺណែត

មហន្តរាយទាំងនេះគឺជាលទ្ធផលនៃការប្រើប្រាស់អ៊ីនធឺណែត។ នេះមានន័យថា ការរងគ្រោះទាំងនេះគឺអាចនឹងកើតឡើងដោយសារការចំណាយពេលកាន់ច្រើនជាមួយអ៊ីនធឺណែត។ ការសម្លុតតាមអ៊ីនធឺណែតគឺជាការបន្លាចអនីតិជនម្នាក់ដោយអនីតិជនម្នាក់ទៀត ដោយប្រើអ៊ីនធឺណែត និង មធ្យោបាយទំនាក់ទំនង

ដទៃៗទៀត។ ជាញឹកញាប់វាពាក់ព័ន្ធទៅនឹងការផ្ញើសារប្រមាថនិងធ្វើឲ្យមានការផ្ទុះកំហឹង។ ប្រសិនបើអំពើបែបនេះត្រូវបានធ្វើឡើងដោយមនុស្សពេញវ័យ វាត្រូវបានចាត់ទុកថាការគំរាមកំហែងលើបណ្តាញអ៊ីនធឺណែត។

ការតាមដានតាមបច្ចេកវិទ្យាព័ត៌មានគឺជាប្រើប្រាស់អ៊ីនធឺណែត និងមធ្យោបាយទំនាក់ទំនងតាមអេឡិចត្រូនិចដទៃៗទៀតដើម្បីលួចសង្កេតជនរងគ្រោះ។ វាអាចកើតឡើងបន្ទាប់ពីមានការលួចតាមដានក្នុងសង្គមខាងក្រៅ ឬជាការគ្រួសត្រាយដើម្បីឲ្យមានការតាមដានក្នុងសង្គមខាងក្រៅ។

ការលួចអត្តសញ្ញាណគឺពាក់ព័ន្ធទៅនឹងការប្រើប្រាស់ព័ត៌មានបុគ្គលសំរាប់ទទួលផលប្រយោជន៍ ឬ ដើម្បីរួចផុតពីកាតព្វកិច្ចអ្វីមួយ។ ឧទាហរណ៍ងាយយល់នោះគឺជាការប្រើប្រាស់ព័ត៌មានបុគ្គលណាម្នាក់ដើម្បីទទួលបានក្រេឌីតកាត។

មហន្តរាយដែលកើតពីអំពើអាក្រក់ទាំងនេះអាចមានភាពធ្ងន់ធ្ងរ ដូចជាករណីពិរុទ្ធជនដែលលួចតាមដាននារីរងគ្រោះ ហើយបានសំលាប់នារីម្នាក់នោះ។ ដំណោះស្រាយគឺស្ថិតនៅលើការបង្កើតច្បាប់ដែលប្រឆាំងនឹងអំពើទាំងនេះ។

ចំណែកឯ ករណីងប់ងល់នឹងអ៊ីនធឺណែត គឺជាការសំដែងចេញនូវការប្រើប្រាស់អ៊ីនធឺណែតហួសកំនត់ជាហេតុធ្វើឲ្យមិនបានទៅសាលា ឬធ្វើការ។ សាធារណរដ្ឋកូរ៉េបានបង្កើតវិធីសាស្ត្រផ្ទាល់ខ្លួន ដើម្បីផ្តល់សេវាប្រឹក្សា និងដោះស្រាយបញ្ហានេះ។

## ដោះស្រាយការល្បក់វង្វេងនិងអ៊ីនធឺណែត

ភាពងប់ងល់នឹងអ៊ីនធឺណែតកាន់តែទទួលបានការកត់សំគាល់ ដោយសារវាជាចំណង់មិនអាចទប់បាន ដូចជាការញៀនល្បែងដែរ។ អ្នកប្រើអ៊ីនធឺណែតងប់ងល់អាចចំណាយពេល ពី ១៧ ទៅ ១៨ ម៉ោងលើប្រព័ន្ធអ៊ីនធឺណែត។ ប្រទេសដែលត្រូវបានគេរាយការណ៍ ថាមានអ្នកប្រើប្រាស់ងប់ងល់ច្រើនជាងគេ មានដូចជា ប្រទេសចិន ជប៉ុន សាធារណរដ្ឋកូរ៉េ និង តៃវ៉ាន់។ ដោយសារតែករណីងប់ងល់នេះភាគច្រើនកើតក្នុងប្រទេសអាស៊ី ធ្វើឲ្យមានសំនួរចោទឡើងថា តើកត្តាវប្បធម៌មានឥទ្ធិពលកំរិតណាទៅលើឥរិយាបថងប់ងល់នេះ។ មានការសិក្សាស្រាវជ្រាវជាច្រើនត្រូវបានធ្វើឡើងដើម្បីកំណត់ថាតើការងប់ងល់នេះជាសញ្ញាបញ្ជាក់ថាមានភាពមិនប្រក្រតីផ្សេងៗទៀតក្នុងខ្លួនបុគ្គលដែរឬទេ។

គេហទំព័រ Wikipedia បានឲ្យនិយមន័យ "ការល្បក់វង្វេងនឹងអ៊ីនធឺណែត" នៅ (http://en.wikipedia.org/wiki/Internet_addiction_disorder) ដែលផ្ដល់នូវអំណះអំណាងសមហេតុផល ទាក់ទងនឹងការគាំទ្រនិងប្រឆាំងនឹងការងប់ងល់អ៊ីនធឺណែតនេះ។

### ការងារត្រូវធ្វើ

ចូរធ្វើការវាយតំលៃក្រៅផ្លូវការភ្លាមៗ ទៅលើកំរិតយល់ដឹងអំពី spam, គំរោងការឆបោក (scam), ការបោកបញ្ឆោតឲ្យផ្ដល់ព័ត៌មានផ្ទាល់ខ្លួន (phising), ការគំរាមកំហែង (cyber bullying), ការលួចតាមដាន (cyberstalking), ការលួចអត្តសញ្ញាណ (identity theft) និងការងប់ងល់នឹងអ៊ីនធឺណែត នៅក្នុងអង្គភាពរបស់អ្នក នៅក្នុងរដ្ឋាភិបាលប្រទេសរបស់អ្នក និងនៅក្នុងសង្គមរបស់អ្នកទាំងមូល។ ចូរលើកអំណះអំណាង ឬផ្ដល់ការបកស្រាយចំពោះការវាយតំលៃរបស់អ្នក។

## ឆន្ទៈខាងផ្នែកនយោបាយ

ការប្រឆាំងនឹងភាពអវិជ្ជមាននៃការប្រើប្រាស់អ៊ីនធឺណែត តំរូវឲ្យមានឆន្ទៈខាងផ្នែកនយោបាយ។ ទី១ ត្រូវធ្វើយ៉ាងណាឲ្យអំពើអវិជ្ជមានទាំងនោះ ត្រូវបានគេចាត់ទុកជាអំពើខុសច្បាប់នៅក្នុងប្រទេសមួយ។

នៅប្រទេសមួយចំនួន ច្បាប់ការពារអ្នកប្រើប្រាស់មានភាពទន់ខ្សោយខ្លាំងពេក ដែលធ្វើឲ្យការពង្រឹងច្បាប់មិនអាចធ្វើទៅបាន ឬគ្មានប្រសិទ្ធភាព។ ទី២ វាតំរូវឲ្យមានឆន្ទៈនយោបាយដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាអន្តរជាតិ។ ឧទាហរណ៍ គំរោងការឆបោកនីហ្សេរីយ៉ា ៤១៩ នៅតែមានជាបន្តបន្ទាប់ ដោយសារតែគ្មានការចាត់វិធានការជាក់ស្តែងដោយរដ្ឋាភិបាលនីហ្សេរីយ៉ា។ ដោយសារតែមូលហេតុនេះ ហើយទើបពាណិជ្ជកម្មតាមបែបអេឡិចត្រូនិចនៅប្រទេសនីហ្សេរីយាបានទទួលទំនុកចិត្តក្នុងកំរិតទាប នៅឡើយ។

## អ៊ីម៉េលបញ្ឆោតឲ្យបង់ប្រាក់ ឬការឆបោកនីហ្សេរីយ៉ា ៤១៩

វាគួរឲ្យអាណោចអាធមដែលប្រទេសនីហ្សេរីយ៉ា ដែលស្ថិតក្នុងលំដាប់ខ្ពស់នៃអំពើពុករលួយក្នុងពិភពលោក គឺជាប្រទេសដែលសំបូរទៅដោយការឆបោកទ្រព្យសម្បត្តិតាមអ៊ីនធឺណែត ហើយអំពើនេះត្រូវបានគេហៅទៅតាមឈ្មោះរបស់លក្ខន្តិកៈប្រឆាំងនឹងអំពើពុតត្បុតដើម្បីយកទ្រព្យសម្បត្តិ។ គំរោងឆបោកនីហ្សេរីយ៉ា ៤១៩ គឺជាការបោកឲ្យបង់ប្រាក់ជាមុន ដែលតំរូវឲ្យជនរងគ្រោះផ្ញើលុយដើម្បីទទួលបានការតបស្នងនូវលុយច្រើនជាងនេះ។

ជាទូទៅ អ៊ីម៉េលប្រភេទនេះត្រូវបានបញ្ជូនទៅជនរងគ្រោះ ពីនរណាម្នាក់ដែលអះអាងថាខ្លួនគេមានលុយមួយចំនួនដែលមិនអាចយកបាន បើសិនជាគ្មានជំនួយ។ លុយទាំងនេះត្រូវបានគេសន្មតថាមានប្រភពចេញពីកេរ្តិ៍មរតក គណនីធនាគារអសកម្ម និងសូម្បីជាលុយពុករលួយ។ ជនណាដែលជាប់អន្ទាក់នឹងត្រូវបានគេស្នើសុំឲ្យផ្ញើប្រាក់កាន់តែច្រើនទៅៗ ដើម្បីយកទៅដោះស្រាយបញ្ហាដែលកើតឡើងដោយមិនបានរំពឹងទុក។

ដោយសារមានការពាក់ព័ន្ធនឹងរឿងលុយកាក់ ប្រតិបត្តិការទាំងនេះត្រូវបានគេរៀបចំឡើងដោយភាពស្ទាត់ជំនាញ ព្រមទាំងមានការឃុបឃិតជាមួយមន្ត្រីរដ្ឋាភិបាលផងដែរ។ មានមនុស្សមួយចំនួនដែលបានទៅប្រទេសនីហ្សេរីយ៉ាដើម្បីស៊ើបអង្កេតរឿងនេះត្រូវបានបាត់ខ្លួនឬត្រូវបានគេសំលាប់។

ការពន្យល់របស់គេហទំព័រ Wikipedia លើប្រធានបទ "ការបោកឲ្យបង់ប្រាក់ជាមុន" នៅ (http://en.wikipedia.org/wiki/Advance_fee_fraud) បានធ្វើការសង្ខេបអំពីប្រវត្តិនៃគំរោងឆបោក និងព័ត៌មានលំអិតអំពីរឿងរ៉ាវផ្សេងៗរបស់វា។ គេហទំព័ររបស់ក្រុមហ៊ុនគ្រឿងអេឡិចត្រូនិចអាមេរិច (http://home.rica.net/alphae/419coal/) បានផ្តល់ដំបូន្មានអំពីអ្វីដែលត្រូវធ្វើនៅពេលយើងទទួលបានអ៊ីម៉េលឆបោក។

## ៤.៣ ការដាក់ទណ្ឌកម្ម

រាល់ការពិភាក្សាអំពីការអភិបាលត្រូវតែនិយាយអំពីចំនុចទាក់ទងនឹងការពង្រឹងច្បាប់។ បើគ្មានការ ពង្រឹងទេ អ្វីដែលល្អបំផុតនោះគឺថាច្បាប់គេគ្រាន់តែជាអ្វីដែលគេចាត់ទុកថាល្អល្អះប៉ុណ្ណោះ ប៉ុន្តែអ្វីដែលអាក្រក់បំផុតនោះគឺថាច្បាប់ត្រូវបានគេចាត់ទុកថាជាមធ្យោបាយការពារប្រយោជន៍ផ្ទាល់ខ្លួន បុគ្គលគ្មានតំលៃក្នុងការគោរពឡើយ។ នៅក្នុងផ្នែកនេះនឹងមានការលើកបង្ហាញអំពីរបៀបដែលទណ្ឌកម្មអាចត្រូវបានគេប្រើប្រាស់ដើម្បីពង្រឹងច្បាប់ដែលបានគេបានព្រមព្រៀងទាក់ទងនឹងអ៊ីនធឺណែត។

### ក្រឹត្យក្រមរបស់សហគមន៍អ៊ីនធឺណែត៖ ពិធីការលើប្រព័ន្ធអ៊ីនធឺណែត និងទណ្ឌកម្មរបស់សហគមន៍

សហគមន៍អ៊ីនធឺណែតអាចនឹងមានពិធីការប្រចាំរបស់ខ្លួន ព្រមទាំងអាចមានក្រឹត្យក្រម និងការរៀបឥរិយាបថផ្សេងៗ។ ក្នុងករណីទាំងនេះ ប្រភេទទណ្ឌកម្មរបស់សហគមន៍ដែលដាក់ទៅលើសមាជិកអាចជាការមិនរវីរវល់ និងការបណ្តេញចេញពីក្រុម។ ទណ្ឌកម្មប្រភេទនេះត្រូវបានគេធ្វើឡើងចំពោះករណីរបស់លោក Bungle ដែលគេបានដឹងសុះសាយ ថាលោកបានរំលោភបំពានតាមប្រព័ន្ធអ៊ីនធឺណែតទៅលើអ្នកលេងហ្គេមពីរនាក់ទៀត។ គាត់ត្រូវបានគេទុកចោលមិនរវីរវល់ និងទីបំផុតត្រូវបានបណ្តេញចេញពីក្រុមលេងហ្គេម។[29]

[29] លោក Julian Dibbell, "ការរំលោភលើបណ្តាញអ៊ីនធឺណែត" *សំឡេងអ្នកភូមិ* "A Rape In Cyberspace," *The Village Voice*, 23 December 1993, http://www.juliandibbell.com/texts/bungle_vv.html.

### ការរំលោភបំពានតាមបណ្តាញអ៊ីនធឺណែត

សហគមន៍លើបណ្តាញបានកកើតឡើងមុនកំណើតរបស់អ៊ីនធឺណែតទៅទៀត។ សហគមន៍ទាំងនេះមានទំហំតូចៗនិងប្រើមធ្យោបាយទំនាក់ទំនងតាមរយៈការផ្ញើសារឆ្លងឆ្លើយហើយលក្ខណៈទាំងនេះក៏មាននៅក្នុងហ្គេមលើបណ្តាញសម័យនោះផងដែរដែលជា ដូនតារបស់ហ្គេមសម័យទំនើបដូចជា World of Warcraft ជាដើម។ នៅក្នុងហ្គេម LambdaMOO ដែលជាហ្គេមមួយនៅសម័យនោះ មានអ្នកលេងហ្គេមម្នាក់ឈ្មោះ Bungle បានប្រើកម្មវិធីមួយដែលគាត់អាចប្រើដើម្បីបំភ័ន់អ្នកលេងដទៃទៀតឲ្យគិតថា សារដែលគាត់ផ្ញើជាសាររបស់អ្នកលេងដទៃទៀត។ សកម្មភាពរបស់លោក Bungle ដែលគាត់បានរៀបរាប់មានដូចជាការប្រព្រឹត្តិផ្លូវភេទរបស់ avatar ដែលគាត់គ្រប់គ្រង ជាមួយនឹង avatar មួយផ្សេងទៀតដែលហាក់ដូចជាគាត់កំពុងគ្រប់គ្រងដែរនោះ។ សកម្មភាពទាំងនោះដែលមានរយៈពេល ៤ ម៉ោង បានរំលោភទៅលើក្រឹត្យក្រមរបស់សហគមន៍។

ប៉ុន្មានថ្ងៃក្រោយមក អ្នកលេងហ្គេម LambdaMOO បានជួបជុំគ្នានៅលើបណ្តាញដើម្បីចាត់វិធានការទៅលើលោក Bungle។ ក្រោយកិច្ចប្រជុំ អ្នកគ្រប់គ្រងផ្នែកសរសេរកម្មវិធីម្នាក់របស់សហគមន៍បានសំរេចបញ្ឈប់គណនីរបស់លោក Bungle ជាឯកតោ ភាគី។ តាំងពីពេលនោះមក អ្នកលេងហ្គេម LambdaMOO បានសំរេចជាផ្លូវការដើម្បីប្រើកម្មវិធីដកជាបណ្តោះអាសន្ននូវអ្នកលេងខូចខិល ឲ្យចេញពីសហគមន៍របស់ពួកគេ។

ទោះជាយ៉ាងណាក៏ដោយ សហគមន៍បែបនេះមិនសូវជាមានច្រើនឡើយ ដោយសារជាញឹកញាប់មានការលំបាកក្នុងការមូលមតិគ្នាថាតើសកម្មភាពណាដែលខុសឆ្គង និងការព្រងព្រៀងទៅលើកំរិតនៃ កំហុស និងទំហំនៃទណ្ឌកម្ម។ម្យ៉ាងវិញទៀត ការដាក់ទណ្ឌកម្មដោយមិនមានការរើរវល់ អាចមិនមានភាពធ្ងន់ធ្ងរគ្រប់គ្រាន់សំរាប់បុគ្គលមួយចំនួន។ សង្ខេបមក ទណ្ឌកម្មរបស់សហគមន៍មានប្រសិទ្ធភាពក្នុងដែនកំណត់មួយប៉ុណ្ណោះ។

## ការជួយសង្គ្រោះខ្លួនឯង

ក្នុងករណីមួយចំនួន ភាគីដែលត្រូវបានគេបំពានអាចប្រើសិទ្ធិការពារខ្លួនឯងផងដែរ។ ឧទាហរណ៍ ម្ចាស់កម្មសិទ្ធិ កន្លងមកបានប្ដឹងជនខិលខូចដែលលួចចំលងស្នាដៃដើមរបស់ខ្លួន ដែលនេះជាបញ្ហាធម្មតាកើតឡើងក្នុងសង្គមដែលមានការពង្រឹងផ្លូវច្បាប់។ នេះមានន័យថា ការងារភាគច្រើនក្នុងការស៊ើបអង្កេតនិងពង្រឹងច្បាប់ត្រូវបានធ្វើឡើងដោយម្ចាស់កម្មសិទ្ធិផ្ទាល់ មិនមែនដោយប៉ូលីសឡើយ ទោះជាការរំលោភលើច្បាប់កម្មសិទ្ធិស្ថិតក្នុងប្រភេទបទឧក្រិដ្ឋក៏ដោយ។

ក្នុងឆ្នាំ ២000 គណកម្មាធិការអូឡាំពិចទីក្រុងស៊ីដនី បានជួលក្រុមហ៊ុនឈ្មោះសេវាគ្រប់គ្រងកម្មសិទ្ធិ បញ្ញា ដើម្បីឃ្លាំមើលប្រព័ន្ធអ៊ីនធឺណែតមិនឲ្យមានគេហទំព័រដែលផ្សព្វផ្សាយព័ត៌មានអំពីអូឡាំពិច ដោយពុំមានការអនុញ្ញាត។ មូលហេតុនោះគឺថាសិទ្ធិក្នុងការផ្សព្វផ្សាយលទ្ធផលអូឡាំពិចត្រូវបានលក់ទៅឲ្យក្រុមហ៊ុនដែលបានដេញថ្លៃក្នុងតំលៃខ្ពស់បំផុតរហូតដល់ ២00 លានដុល្លារ ដូច្នេះការលួចផ្សព្វផ្សាយព័ត៌មានអំពីលទ្ធផលនេះអាចប៉ះពាល់ផលប្រយោជន៍របស់អ្នកទទួលសិទ្ធិត្រឹមត្រូវ។ សមាជិកក្រុមហ៊ុនមានគ្នាប្រហែល ៦0 នាក់ដែលមានតួនាទីឃ្លាំមើល បានទទួលជោគជ័យក្នុងការបញ្ឈប់ការផ្សព្វផ្សាយដែលមិនមានការអនុញ្ញាតបានជាច្រើនករណី។ ស្ថានីយ៍ទូរទស្សន៍របស់រុស្ស៊ី Moscow TV6 បានព្យាយាមត៉វ៉ាគាំទ្រសិទ្ធិក្នុងការបញ្ចេញមតិ នៅពេលដែលខ្លួនចាប់ផ្ដើមទទួលការផ្គត់ផ្គង់ខ្សែវីដេអូតាមអ៊ីនធឺណែតនោះ។ ប៉ុន្តែ Moscow TV6 ត្រូវតែបញ្ឈប់ការផ្សព្វផ្សាយអូឡាំពិចដែលគ្មានច្បាប់របស់ខ្លួនបើពុំនោះទេការផ្គត់ផ្គង់ខ្សែវីដេអូទៅឲ្យស្ថានីយ៍ក៏នឹងត្រូវបញ្ឈប់ដែរ។[30] ចាប់ពីពេលនោះមកមានការឃ្លាំមើលនៅពេលមានព្រឹត្តិការណ៍អូឡាំពិចទាំងរដូវក្ដៅ និងរដូវត្រជាក់។

[30] "ជនល្មើសត្រូវបានចាប់ខ្លួនខណៈដែលវីដេអូអូឡាំពិចត្រូវបានត្រួតពិនិត្យលើអ៊ីនធឺណែត" "Violators caught as Olympic video monitored on Internet," *CNN*, 22 September 2000, http://edition.cnn.com/2000/TECH/computing/09/22/olympics.netpolice.ap/index.html.

## ច្បាប់អន្តរជាតិ

កន្លងមកមានការពិភាក្សាអំពីការបង្កើតច្បាប់អន្តរជាតិ សំរាប់បង្កលក្ខណៈឲ្យមានការស៊ើបអង្កេត និងកាត់ទោសចំពោះឧក្រិដ្ឋកម្មលើអ៊ីនធឺណែត។ ច្បាប់បែបនេះមានអត្ថប្រយោជន៍ក្នុងការធ្វើឲ្យមានភាពជាឯកសណ្ឋាននៃការកំណត់និយមន័យ ការដាក់ទោស និងការពង្រឹងច្បាប់ទាំងនេះប្រឆាំងនឹងឧក្រិដ្ឋកម្មលើអ៊ីនធឺណែត។ ទោះជាមានកិច្ចសហប្រតិបត្តិការអន្តរជាតិបែបនេះក៏ដោយ មានប្រទេសចំនួនតិចតួចប៉ុណ្ណោះដែលបានចូលរួម។

ក្រុមប្រឹក្សានៃសន្ធិសញ្ញាអឺរ៉ុបលើបទឧក្រិដ្ឋក្នុងបណ្តាញអ៊ីនធឺណែត (Council of Europe Convention on Cybercrime) គឺជាកិច្ចប្រឹងប្រែងដើម្បីអនុវត្តនិងពង្រឹងច្បាប់នេះ។ ដោយសារប្រទេសនៅអឺរ៉ុបមានលក្ខណៈខុសៗគ្នា ទើបធ្វើឲ្យការអនុវត្តសន្ធិសញ្ញានេះមានអាចនឹងមានលក្ខណៈទូលំទូលាយ។ ម្យ៉ាងវិញទៀត សន្ធិសញ្ញានេះធ្វើឲ្យមានតុល្យភាពរវាងតំរូវការក្នុងការពង្រឹងសន្ធិសញ្ញាខ្លួនឯង និងសិទ្ធិក្នុងការបញ្ចេញមតិ។

## ក្រុមប្រឹក្សានៃសន្ធិសញ្ញាអ៊ឺរ៉ុបលើបទឧក្រិដ្ឋក្នុងបណ្ដាញអ៊ីនធឺណែត

ដើម្បីឲ្យមានប្រសិទ្ធភាព បណ្ដាភ្នាក់ងារពង្រឹងច្បាប់ត្រូវតែធ្វើការពិចារណាទៅលើភាពងាយស្រួល ដែលអ៊ីនធឺណែតអនុញ្ញាតឲ្យមានការឆ្លងព្រំប្រទល់ ក៏ដូចជាសមត្ថកិច្ចគ្រប់គ្រង។ នេះមានន័យថា លុះត្រាតែភ្នាក់ងារពង្រឹងច្បាប់ទាំងអស់មានការព្រមព្រៀង ទៅលើក្បួនខ្នាតនៃការអនុវត្តជាសកលមួយ ពុំនោះទេការកំណត់ប្រភេទនិងចំណាត់ការ លើបទឧក្រិដ្ឋនឹងជួបការលំបាក។

ទោះជាយ៉ាងណាក៏ដោយ សហគមន៍អ៊ីនធឺណែតមានការប្រុងប្រយ័ត្នក្នុងការពង្រឹងច្បាប់។ នៅលើប្រព័ន្ធអ៊ីនធឺណែតមានវប្បធម៌មួយដែលថា "អ្វីៗទាំងអស់អាចប្រព្រឹត្តិទៅបាន" ដែលជាកន្លែងផ្ដល់ការគាំទ្រទាំងស្រុងទៅលើសិទ្ធិក្នុងការបញ្ចេញមតិ។ ម៉្យាងទៀត ដោយសារអ៊ីនធឺណែតកំពុងស្ថិតក្នុងដំណាក់កាលលូតលាស់ គេមានកង្វល់ខ្លាចក្រែងការពង្រឹងច្បាប់អាចនឹងធ្វើឲ្យអ៊ីនធឺណែតឈប់លូតលាស់។

ក្រុមប្រឹក្សានៃសន្ធិសញ្ញាអ៊ឺរ៉ុបលើបទឧក្រិដ្ឋក្នុងបណ្ដាញអ៊ីនធឺណែត បានប្រឹងប្រែងដោះស្រាយកង្វល់ទាំងនេះ។ ស្ទើរតែគ្រប់ប្រទេសទាំងអស់នៅអ៊ឺរ៉ុបគឺជាសមាជិកនៃក្រុមប្រឹក្សាអ៊ឺរ៉ុប (CoE) ។ វាមានរដ្ឋដែលជាសមាជិកច្រើនជាង EU ដែលជាស្ថាប័នមួយផ្សេងទៀត។ CoE បង្កើតនូវសន្ធិសញ្ញាដែលរដ្ឋជាសមាជិកអាចនឹងផ្ដល់ឬមិនផ្ដល់សច្ចាប័ន ក្នុងខណៈដែលរាល់សន្ធិសញ្ញារបស់ EU ត្រូវតែគោរពដោយរដ្ឋជាសមាជិកដើម្បីធ្វើសមាហរណកម្មចូលច្បាប់របស់ប្រទេសសមាជិក។

ដោយសារតែមានសមាជិកច្រើនប្រទេស (ប្រហែលជិត ៥០) បានចូលរួម ជាហេតុធ្វើឲ្យមានបញ្ហាជាច្រើនក្នុងការបង្កើតសន្ធិសញ្ញាប្រឆាំងនឹងបទឧក្រិដ្ឋលើអ៊ីនធឺណែត។ ប៉ុន្តែដោយសារតែ CoE គឺជាស្ថាប័នក្នុង តំបន់ភាពជិតស្និទ្ធគ្នារវាងវប្បធម៌និងដែនដីនៃប្រទេសជាសមាជិក ធ្វើឲ្យភាពតានតឹងផ្នែកការទូតដែលមាននៅក្នុងកិច្ចពិភាក្សាត្រូវបានកាត់បន្ថយជាអប្បបរិមា។ ម៉្យាងវិញទៀត តាមលក្ខណៈធម្មជាតិនៃសន្ធិសញ្ញាប្រទេសទាំងអស់អាចព្រមព្រៀងគ្នាទៅលើតែអត្ថបទ ប៉ុណ្ណោះ ប៉ុន្តែមិនព្រមទទួលយកទៅអនុវត្ត ឬក៏អនុវត្តតែផ្នែកខ្លះនៃខ្លឹមសាររួមប៉ុណ្ណោះ។ លទ្ធភាពក្នុងការទទួលយកឬមិនទទួលយកនេះ ហើយដែលធ្វើឲ្យអំណាចនៃការសំរេចចិត្តស្ថិតនៅក្នុងកណ្ដាប់ដៃរបស់សភាជាតិនៃប្រទេសជាសមាជិក។ ផ្ទុយទៅវិញ ច្បាប់ដែលបានអនុម័តដោយសភាសហគមន៍អ៊ឺរ៉ុបត្រូវតែយកទៅអនុវត្តដោយប្រទេសសមាជិក។

ដូច្នេះហើយ CoE បានសង្កត់ធ្ងន់លើការថ្លឹងថ្លែងប្រកបដោយតុល្យភាពទៅលើកង្វល់ទាំងអស់។ សន្ធិសញ្ញាលើបទឧក្រិដ្ឋក្នុងប្រព័ន្ធអ៊ីនធឺណែតត្រូវឆ្លងកាត់ការត្រួតពិនិត្យជាច្រើនដំណាក់ ព្រមទាំងមានការចូលរួមយោបល់ពីស្ថាប័នដូចជាសហភាពសេរីភាពស៊ីវិលអាមេរិច (American Civil Liberties Union) អំពីភាពចំរូងចំរាស់ដែលអាចកើតមានទាក់ទងនឹងសិទ្ធិក្នុងការបញ្ចេញមតិ។ សន្ធិសញ្ញានេះបានដាក់ចេញនូវសេចក្ដីណែនាំសំរាប់ប្រទេសដែលមានបំណងអនុវត្តច្បាប់ឧក្រិដ្ឋកម្មលើអ៊ីនធឺណែត។ វាបានចូលជាធរមានក្នុងខែកក្កដាឆ្នាំ២០០៤ ដែលក្នុងនោះក៏មានលក្ខន្តិកៈសំរាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ ដែលមានន័យថាប្រទេសដែលមិនមែនជាសមាជិក CoE អាចនឹងចូលរួមសន្ធិសញ្ញានេះផងដែរ។ ជាការពិតណាស់ វាបានចូលជាធរមាននៅប្រទេសអាមេរិចផងដែរក្នុងឆ្នាំ ២០០៧។

សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងក្រុមប្រឹក្សាអ៊ឺរ៉ុបសំរាប់ប្រធានបទដូចជា "ឧក្រិដ្ឋកម្មលើអ៊ីនធឺណែត៖ ការគំរាមកំហែងទៅលើ លទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងនីតិរដ្ឋ" http://www.coe.int/t/dc/files/themes/cybercrime/default_en.asp.

យន្តការមួយទៀតដែលគេអាចធ្វើទៅបានដើម្បីទទួលបានកិច្ចព្រមព្រៀងអន្តរជាតិ គឺស្ថិតនៅលើសហប្រតិការសកម្មនៃវេទិកាអភិបាលអ៊ីនធឺណែត។ ការចូលរួមសកម្មគឺជាការចូលរួមជាក្រុមពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់ដែលមានចំណាប់អារម្មណ៍លើការពិភាក្សាលើបញ្ហាសំខាន់ណាមួយ។ វេទិកាអំពី spam ជាវេទិកាដ៏សកម្មមួយ។

### សម្ព័ន្ធបញ្ឈប់ spam

អ្វីដែលជាបញ្ហាជាមួយ spam នោះគឺថាការរ៉ាប់រងលើតំលៃផ្សេងៗគឺជាបន្ទុករបស់អ្នកទទួល មិនមែនអ្នកផ្ញើឡើយ ដែលខុសពីការផ្សាយពាណិជ្ជកម្មធម្មតា។ លទ្ធផលនៃតាមការសិក្សាបានបញ្ជាក់ថាចរាចរណ៍ភាគច្រើននៃអ៊ីម៉េលមានបញ្ចូល spam នៅក្នុងនោះផងដែរ។

"ជំនាន់ដំបូង" នៃ spam គឺគ្រាន់តែជាការរំខានដ៏គួរឲ្យខឹង ដែលអ្នកប្រើប្រាស់ក៏ដូចជាអ្នកគ្រប់គ្រងប្រព័ន្ធអាចធ្វើការច្រោះសំអាតបានស្ទើរតែគ្រប់ពេល។ ដោយឡែក spam ជំនាន់ក្រោយ បង្កឲ្យមានការប្រកាសអាសន្ន។ នាពេលបច្ចុប្បន្ន មាន spam កាន់តែច្រើនទៅៗផ្ទុកកម្មវិធីព្យាបាទ
ដែលអាចដំណើរការដោយខ្លួនឯងនិងមិនឲ្យអ្នកប្រើប្រាស់បានដឹងឡើយ។
កម្មវិធីទាំងនេះធ្វើឲ្យម៉ាស៊ីនកុំព្យូទ័រក្លាយជា "bot" ដែលគ្រប់គ្រងដោយ អ្នកពង្រាយ spam ដើម្បីផ្ញើ spam ចេញ។ ក្នុងករណីមួយចំនួន spam អាចភ្ជាប់មកជាមួយនូវកូដសំរាប់ទាញយកលេខសំងាត់ និងព័ត៌មានសំខាន់ៗដទៃទៀត។ ភាពសាំញ៉ាំ និងវិសាលភាពនៃប្រតិបត្តិការរបស់ spam បែបនេះ អាចបញ្ជាក់ថាមានអង្គភាពមួយចំនួនដែលមានទំនាក់ទំនងជាមួយនឹងក្រុមឧក្រិដ្ឋជនជាញឹកញាប់។

វាដូចជាហ្គេមឆ្មានិងកណ្តុរអញ្ចឹង ដែលអ្នកពង្រាយ spam កាន់តែព្យាយាមបង្កើត spam ឲ្យកាន់តែស្មុគស្មាញដោយសារតែ spam មុនៗរបស់ពួកគេត្រូវទទួលបរាជ័យ។ ដើម្បីផ្តល់ជាមេរៀនល្អៗ ក៏ដូចជាទស្សនៈផ្នែកជំនួញ សម្ព័ន្ធសកម្មលើបញ្ហា spam (Dynamic Coalition on Spam) ត្រូវបានបង្កើតឡើងនៅក្នុងវេទិកាអភិបាលអ៊ីនធឺណែត។ សម្ព័ន្ធនេះបានរួបរួមក្រុមតូចៗដែលកំពុងធ្វើការលើប្រធានបទនេះ ឲ្យទៅជាធ្លុងមួយ។ ការងារនេះកំពុងនឹងបន្តទៅមុខ ហើយក្រុមរួបរួមនេះបានហៅខ្លួនឯងថា សម្ព័ន្ធបញ្ឈប់ spam (http://stopspamalliance.org)។

### សំនួរពិចារណា

តើប្រទេសរបស់អ្នកបានចូលរួមកិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីដោះស្រាយការរំលោភបំពានលើអ៊ីនធឺណែត ដល់កំរិតណា?

## សរុបសេចក្តី

ដូចដែលយើងបានដឹងហើយថា អ៊ីនធឺណែតជាឧបករណ៍ដ៏អស្ចារ្យសំរាប់ជាមធ្យោបាយទំនាក់ទំនង ដែលនេះក៏ជាមូលហេតុដែលគេអាចប្រើប្រាស់វាក្នុងគោលបំណងមិនល្អផងដែរ។ វាតំរូវឲ្យមានការដាក់បទបញ្ជាទៅការប្រើបាស់អ៊ីនធឺណែតក្នុងផ្លូវអវិជ្ជមានទាំងនេះ ដោយមិនមានការសង្ស័យឡើយ។

ដោយសារតែមានការលំបាកក្នុងការកំណត់និយមន័យរួមនៃអ្វីដែលយើងទាំងអស់គ្នាព្រមព្រៀងថា ជាបទល្មើសសកលនោះ ភាពជោគជ័យក្នុងការដោះស្រាយមហន្តរាយ និងការបង្កបញ្ហាលើប្រព័ន្ធនៅមានកំណត់នៅឡើយ។ ភាពជោគជ័យដ៏គួរឲ្យកត់សំគាល់ជាងគេគឺជាការប្រឆាំងទៅនឹងការឆបោកអ្នកប្រើប្រាស់ និងរូបអាសគ្រាមកុមារ។

កិច្ចព្រមព្រៀងអន្តរជាតិមានភាពចាំបាច់ ដោយសារ ទី១ សំរាប់បង្កើតច្បាប់ និងទី២ សំរាប់ការពង្រឹងច្បាប់ទាំងនោះ។ ក្រុមប្រឹក្សានៃសន្និសញ្ញាអឺរ៉ុបលើបទឧក្រិដ្ឋក្នុងបណ្តាញអ៊ីនធឺណែត អាចនឹងក្លាយជាគ្រឹះស្ថាន សំរាប់កិច្ចព្រមព្រៀង និងសហប្រតិបត្តិការ នៅក្នុងថ្ងៃអនាគត។

### សាកល្បងខ្លួនឯង

១.តើភ្នាក់ងារពង្រឹងច្បាប់បានប្រឈមនឹងការលំបាក់អ្វីខ្លះ ក្នុងការត្រួតពិនិត្យការរំលោភបំពានលើប្រព័ន្ធអ៊ីនធឺណែត?

២.តើសហគមន៍អន្តរជាតិបានចាត់ទុកសកម្មភាពអ្វីខ្លះជាឧក្រិដ្ឋកម្មលើអ៊ីនធឺណែត និងគួរតែឲ្យមានការត្រួតពិនិត្យ?

៣.តើមានបទឧក្រិដ្ឋថ្មីអ្វីខ្លះ ដែលបានកកើតឡើងដោយសារអ៊ីនធឺណែត?

៤.តើមានទណ្ឌកម្មអ្វីខ្លះដើម្បីប្រឆាំងនឹងអំពើឧក្រិដ្ឋទាំងនេះ ដែលអាចនឹងធ្វើឡើងតាមរយៈអ៊ីនធឺណែត?

# ៥.បញ្ហាដូចគ្នានៅនឹងសង្គមខាងក្រៅ

ផ្នែកនេះមានគោលបំណងបង្កើនការយល់ដឹងអំពីភាពដូចគ្នារវាងពិភពអ៊ីនធឺណែតនិងសង្គមខាងក្រៅ នៅក្នុងផ្នែកគន្លឹះៗដូចជា រដ្ឋាភិបាល និងវិស័យសេដ្ឋកិច្ច ដែលទាក់ទងនឹងខ្លឹមសារ។ ម៉្យាងទៀត វាក៏មានគោលបំណងបង្កើនការយល់ដឹងអំពីតំរូវការឲ្យមានការឆ្លើយតបដោយមានដាក់បទបញ្ជា។

អ៊ីនធឺណែតបានជះឥទ្ធិពលដល់សង្គមខាងក្រៅ។ តើសង្គមខាងក្រៅគួរតែមានការកែតំរូវដើម្បីឲ្យកាន់ តែមានភាពដូចគ្នាទៅនឹងពិភពលើបណ្តាញឬទេ? ឬមួយក្រឹត្យក្រមរបស់សង្គមខាងក្រៅគួរតែយកទៅអនុវត្តនៅក្នុងពិភពលើបណ្តាញ? ចម្លើយគឺស្ថិតនៅទីកណ្តាល។

## ៥.១ នយោបាយប្រកួតប្រជែង

សេវាកម្មអ៊ីនធឺណែតគួរតែមានការប្រកួតប្រជែងឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ ដែលមានន័យថាការធ្វើឲ្យមានទីផ្សារសេរីនៅក្នុងវិស័យទូរគមនាគមន៍ ជាពិសេសបើសិនវិស័យនេះ មានលក្ខណៈជាជំនួញផ្តាច់មុខ។ ការប្រើយុទ្ធសាស្រ្តទីផ្សារសេរីនៅក្នុងវិស័យនេះបានធ្វើឲ្យគុណភាពប្រសើរឡើង រីឯតំលៃថយចុះ។ ការយកតំលៃទាបធ្វើឲ្យជំរាបនៃអ៊ីនធឺណែតមានការកើនឡើង ដូចជាក្នុងករណីរបស់ broadband ជាដើម។ ការយកតំលៃទាបធ្វើឲ្យមានបំរែបំរួលនៃនិន្នាការប្រើប្រាស់អ៊ីនធឺណែត។ ទ្រឹស្តី Game theory បានពោលថាគួរតែមានយ៉ាងហោចណាស់អ្នកលេងល្បែងចំនួន ៣ នាក់ដើម្បីឲ្យការប្រកួតមានប្រសិទ្ធភាព។

### របបទីផ្សាសេរីក្នុងវិស័យទូរគមនាគមន៍ និងតំលៃក្នុងការប្រើប្រាស់អ៊ីនធឺណែត

គេបាននិយាយថាមូលហេតុមួយក្នុងចំណោមមូលហេតុជាច្រើន ដែលធ្វើឲ្យមានការលូតលាស់លើវិស័យអ៊ីនធឺណែតក្នុងសហរដ្ឋអាមេរិច គឺដោយសាររបបទីផ្សាសេរីក្នុងវិស័យទូរគមនាគមន៍។ គួររំលឹកដែរថា អ៊ីនធឺណែតគឺអាស្រ័យទៅលើការតភ្ជាប់បណ្តាញទូរគមនាគមន៍ក្នុងចំងាយឆ្ងាយ។ ការប្រកួតប្រជែងក្នុងវិស័យនោះបានធ្វើឲ្យតំលៃធ្លាក់ចុះ។ ឥទ្ធិពលនៃរបបទីផ្សាសេរីត្រូវបានគេឃើញយ៉ាងច្បាស់នៅសហរដ្ឋអាមេរិច ដែលជាអ្នកផ្តើមឲ្យមានចលនាទីផ្សាសេរីក្នុងវិស័យទូរគមនាគមន៍ ដែលជាហេតុធ្វើឲ្យវាមានតំលៃទាបក្នុងការបង្ហោះគេហទំព័រនៅអាមេរិច ជាងប្រទេសភាគច្រើនដទៃទៀត។ នេះក៏ជាការនាំទៅរកវដ្តនៃភាពអនុគ្រោះ ដែលកើតឡើងមកពីពាណិជ្ជកម្មក្នុងបរិមាណច្រើនធ្វើឲ្យតំលៃមានការធ្លាក់ចុះ។

ការស្រាវជ្រាវបានបង្ហាញឲ្យឃើញថាតំរូវការក្នុងវិស័យទូរគមនាគមន៍មានភាពយឺតនិងរួញជាបង្គួរ។ នេះមានន័យថា ការធ្លាក់ចុះនៃតំលៃក្នុងកំរិត x ភាគរយ នឹងនាំឲ្យមានការកើនឡើងនៃការប្រើប្រាស់ក្នុងកំរិតច្រើនជាង x ភាគរយទៅទៀត។ ការសិក្សាបានបង្ហាញផងដែរថាការអនុញ្ញាតិឲ្យមានការប្រកួតប្រជែងនៅទីផ្សាទូរគមនាគមន៍ក្នុងស្រុកនឹងធ្វើឲ្យជំរាបនៃអ៊ីនធឺណែតកើនឡើងកាន់តែខ្លាំង។

ប្រទេសបារាំង ជប៉ុន និងសាធារណរដ្ឋកូរ៉េបានបង្កើនជំរាបនៃ broadband តាមរយៈនយោបាយគាំទ្រការប្រកួតប្រជែង។ សាធារណរដ្ឋកូរ៉េមានជំរាប broadband ខ្ពស់ជាងគេបំផុតនៅលើពិភពលោក។ ប្រទេសនេះបានដាក់ចេញនូវនយោបាយដែលអនុញ្ញាតឲ្យមានលំហូរចូលដោយសេរីទៅក្នុងវិស័យទូរគមនាគមន៍ចាប់តាំងពីទស្សវត្សឆ្នាំ ១៩៨០មកម្ល៉េះ។ រីឯករណីប្រទេសបារាំង និងជប៉ុនអាចឲ្យយើងដឹងព័ត៌មានច្រើនជាង ដោយសារមិនមានជំរាបខ្ពស់ រហូតដល់ប្រហែលឆ្នាំ ២០០៥។ ចាប់តាំងពីពេលនោះមក នយោបាយគាំទ្រការប្រកួតប្រជែងបានជំរុញឲ្យតំលៃធ្លាក់ចុះ ហើយជំរាប broadband បានស្ទុះឡើង។

ចាប់ពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៨០ រហូតដល់ពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៩០ មានសៀវភៅនិងឯកសារស្រាវជ្រាវជាច្រើនបានពិភាក្សាអំពីអត្ថប្រយោជន៍នៃរបបទីផ្សាសេរីក្នុងវិស័យទូរគមនាគមន៍។ របបទីផ្សាសេរីក្នុងវិស័យអ៊ីនធឺណែតគឺជាទស្សនៈបន្ថែមដែលត្រូវបានគេសិក្សាទៅលើវិស័យទូរគមនាគមន៍។ សូមមើលស្នាដៃរបស់ Emanuelee Giovannetti, "បដិវត្តន៍នៃបច្ចេកវិទ្យាព័ត៌មាន អ៊ីនធឺណែត និងទូរគមនាគមន៍៖ ការផ្លាស់ប្តូរទៅរកឧស្សាហកម្មប្រកួតប្រជែងមួយនៅសហគមន៍អឺរ៉ុប" និពន្ធដោយ E. Giovannetti M. Kagami និង M. Tsuji។ បដិវត្តន៍នៃអ៊ីនធឺណិត៖ ការប្រមើលមើលជាសកល (គ្រឹះស្ថាន បោះពុម្ព Cambridge University Press ឆ្នាំ ២០០៣) ទំព័រ ១២៤-១៤២។

## ៥.២ ការត្រួតពិនិត្យ និងសិទ្ធិក្នុងការបញ្ចេញមតិ

ការត្រួតពិនិត្យដោយរដ្ឋាភិបាល និងផ្នែងឯកជនបានធ្វើឡើងនៅទូទាំងពិភពលោក។ ដូចដែលបានពិភាក្សាកន្លងមក បញ្ហាគឺស្ថិតនៅលើការធ្វើឲ្យមានតុល្យភាពនៃប្រយោជន៍ក្នុងស្រុកឲ្យស្របទៅតាមក្រឹត្យក្រមអន្តរជាតិ ដែលមិនដាក់ការត្រួតពិនិត្យឬដាក់ការត្រួតពិនិត្យក្នុងកំរិតតិចតួច ទៅលើអ៊ីនធឺ ណែត។ ការរាំងខ្ទប់ការមិឲ្យមានការលក់ដុំនៃទំនិញនៅលើគេហទំព័រ ត្រូវបានបដិសេធដោយសហគមន៍អ៊ីនធឺណែត។ ដំណោះស្រាយងាយស្រួលនិងអាចទទួលយកបានគឺស្ថិតនៅលើការច្រោះយកតែខ្លឹមសារល្អៗដោយអ្នកប្រើប្រាស់ផ្ទាល់។ កម្មវិធីគំរងដែលតំលើងដោយអ្នកប្រើប្រាស់គឺអាចទទួលយកបាន។ ប៉ុន្តែគេបានរកឃើញថា មាតាបិតាជាញឹកញាប់មិនសូវមាជំនាញ និងចំណេះដឹងក្នុងការតំលើង និងប្រើប្រាស់កម្មវិធីគំរងទាំងនោះឡើយ។

## ការច្រោះយកគេហទំព័រដែលកំណត់ប្រភេទលើខ្លួនឯង

ក្នុងឆ្នាំ ១៩៩៩ គ្រឹះស្ថាន Bertelsmann បានបង្កើតក្រុមការងារមួយដើម្បីអភិវឌ្ឍប្រព័ន្ធមួយសំរាប់ធ្វើការច្រោះយកតែខ្លឹមសារអ៊ីនធឺណែតណាដែលមិនយកកំរៃ គិតគូរដល់ការប៉ះពាល់វប្បធម៌ ព្រមទាំងមិនរំលោភបំពានលើសិទ្ធិក្នុងការបញ្ចេញមតិ។ ក្រុមនោះគឺជា ការជួបជុំនៃអ្នកស្រាវជ្រាវ អ្នកដាក់បទបញ្ជា ព្រមទាំងអ្នកគាំទ្រសិទ្ធិក្នុងការបញ្ចេញមតិដោយសេរីផងដែរ។ លទ្ធផលជាចុងក្រោយគឺជាការបង្កើតឡើងនូវសមាគមន៍ដាក់ ចំណាត់ថ្នាក់ទៅលើខ្លឹមសារអ៊ីនធឺណែត(ICRA)។

ក្រុមនេះបានដឹង និងរំពឹងទុកនូវលទ្ធផលដែលគួរជាទីចង់បាន៖ មាតាបិតានិងចុចទៅលើឈ្មោះប្រទេសរបស់ពួកគេ បន្ទាប់មកចុចទៅលើប្រព័ន្ធតំរង (ឧទាហរណ៍ៈ ប្រព័ន្ធដែលបង្កើតដោយវិហារកាតូលិច) បន្ទាប់ពីនោះមកគេហទំព័រទាំងឡាយណាដែលគេគិតថា មិនសមរម្យនឹងត្រូវបានធ្វើការច្រោះចេញ។ ក្នុងគោលគំនិតនៃប្រព័ន្ធតំរង គេហទំព័រត្រូវបានគេដាក់ស្លាកសំគាល់ទៅតាមភាសា ហឹង្សានិងកំរិតអាក្រាតកាយ ព្រមទាំងខ្លឹមសារដែលអាចមានការជំទាស់ (ប៉ុន្តែមិនមែនខុសច្បាប់ទេ) ដូចជាគ្រឿងស្រវឹង។ ស្លាក សំគាល់ទាំងអស់មានចំនួនប្រហែល ៤០។

ក៏ប៉ុន្តែនៅទីបំផុត ICRA មិនបានមកកាន់គោលដៅដែលបានកំណត់ឡើយ។ ទី១ ដោយសារមានការប្រឆាំងពីក្រុមស៊ីវិលដែលគាំទ្រការសំរេចចិត្តដោយសេរី ដូចជាមជ្ឈមណ្ឌល សំរាប់ប្រជាធិបតេយ្យ និងបច្ចេកវិទ្យានៅសហរដ្ឋអាមេរិច។ គេហទំព័រព័ត៌មានជាច្រើន ដែលពីដំបូងព្រមព្រៀងឲ្យមានការដាក់ស្លាកសំគាល់លើខ្លួន បានប្តូរចិត្តនៅពេលដែលពួកគេមានអារម្មណ៍ថាខ្លួនបានចុះញ៉មនឹងរបបត្រួតពិនិត្យនោះ។ ទី២ ដើម្បីដោះស្រាយការបញ្ចេញទស្សនៈដោយសេរី គេហទំព័រទាំងអស់ត្រូវតែដាក់ស្លាកសំគាល់លើខ្លួនឯង ដែលនេះជាកត្តារំខានដល់ការបង្កើតគេហទំព័រសាមញ្ញៗ ដោយសារតំរូវការនៃការធ្វើស្លាកស្នាមនេះ។ ខណៈដែលគ្មានគេហទំព័រសាមញ្ញៗទាំងនោះ អ្នកប្រើប្រាស់ដែលប្រើតំរងច្រោះ ត្រូវតែឈប់ប្រើតំរងម្តងម្កាលដើម្បីទទួលបានគេហទំព័រទាំងនោះ។ ទី៣ កម្មវិធីតំរងទាំងនោះនឹងមានប្រសិទ្ធភាពខ្ពស់បើសិនជាបញ្ចូលដោយផ្ទាល់ទៅក្នុង browser។ ខណៈពេលដែលនីតិវិធីរបស់ ICRA បានអភិវឌ្ឍរួចរាល់សំរាប់ប្រើប្រាស់ សង្គ្រាម browser បានបញ្ចប់មុននោះទៅហើយ ដោយ Microsoft បានទទួលជោគជ័យ។ បន្ទាប់មកទាំង Microsoft និង Netscape បានបន្ថែមសមត្ថភាពទៅលើ brower របស់ពួកគេរៀងៗខ្លួន។ តាមពិតទៅ browser របស់ Microsoft ដែលផលិតក្នុងឆ្នាំ ២០០០ មានបំពាក់ប្រព័ន្ធតំរងមួយចំនួនរួចទៅហើយ។ ទីបំផុត ដូចទៅនឹងបទពិសោធន៍ដែលគេធ្លាប់មានជាមួយនឹង ប្រព័ន្ធដាក់ស្លាកសំគាល់ V-chip នៅសហរដ្ឋអាមេរិច ដែលមានគោលបំណងប្រើប្រាស់ក្នុងការច្រោះចេញនូវខ្លឹមសារតាមទូរទស្សន៍ដែលបង្កប់អំពើហឹង្សា ពុំមានការទាមទារច្បាស់លាស់ណាមួយពីសំណាក់អតិថិជនឡើយ ឬអតិថិជនមិនធ្វើកិច្ចសន្យាផ្ទាល់មាត់អំពីតំរូវការសំរាប់គំរោងច្រោះបែបនោះឡើយ។

នៅឆ្នាំ ២០០៧ ICRA ត្រូវបានបញ្ចូលទៅក្នុងវិទ្យាស្ថានសុវត្ថិភាពលើបណ្តាញរបស់គ្រួសារ ( Family Online Safety Institute )។

ដោយសារអ្នកនិពន្ធបានចូលរួមដោយផ្ទាល់ក្នុងក្រុម ICRA ក្នុងតួនាទីជាសមាជិក រឿងរ៉ាវខាងលើនេះត្រូវបានរៀបរាប់ឡើងវិញជាលើកដំបូង។ សៀវភៅដែលមានចំណងជើងថា *រៀបចំភាពច្របូកច្របល់* ក៏បានបង្ហាញព័ត៌មានលំអិតមួយចំនួនអំពី ICRA ក្នុងផ្នែកដែលមានឈ្មោះថា "ការត្រួតពិនិត្យ និងការដាក់បទបញ្ជាលើខ្លឹមសាររបស់អ៊ីនធឺណែត"។

វិធីមួយទៀតគឺត្រូវធ្វើឡើងតាមរយៈការតំលើងកម្មវិធីតំរងនៅកំរិត server ដែលតំលៃសេវាត្រូវបានបញ្ចូលបន្ថែមទៅលើការចំណាយរបស់អ្នកប្រើប្រាស់។ ការយកថ្លៃគឺធ្វើឡើងសំរាប់សេវាកម្មដូចជាការកែតំរូវព័ត៌មាន និងការថែទាំបញ្ជីនៃគេហទំព័រដែលត្រូវរាំងខ្ទប់នោះ។ នេះគឺជាតំរងប្រោះដែលអ្នកប្រើប្រាស់ទូទៅយល់ថា ជាស្ថានភាពមួយដែលមិនអាចធ្វើការរំលងបាន។ ប៉ុន្តែ អ្វីដែលជាគុណវិបត្តិនោះគឺជួនកាលមានការរាំងខ្ទប់ហួសហេតុ ព្រមទាំងពិបាកក្នុងការ "ដោះការរាំងខ្ទប់" ចំពោះគេហទំព័រដែលត្រូវបានរាំងខ្ទប់ដោយការភ័ន្តច្រលំនោះ។

### ការងារត្រូវធ្វើ

១.ចូររៀបរាប់អំពីជំហាននៃការដាក់បទបញ្ជាទៅលើខ្លឹមសារអ៊ីនធឺណែត នៅប្រទេសរបស់អ្នកប្រសិនបើមាន។

២.បើសិនជាមានរដ្ឋាភិបាលនៃប្រទេសដទៃបានស្នើឲ្យរដ្ឋាភិបាលប្រទេសរបស់អ្នក ធ្វើការរាំងខ្ទប់គេហទំព័រមួយដែលមានខ្លឹមសារខុសច្បាប់ក្នុងប្រទេសរបស់គេ តើរដ្ឋាភិបាលប្រទេសរបស់អ្នកគួរធ្វើយ៉ាងណា? ចូរផ្តល់អនុសាសន៍ និងលើកហេតុផលគាំទ្រ។

## ៥.៣ ការបង្ខូចកេរ្តិ៍ឈ្មោះ

ជាមួយនឹងសិទ្ធិក្នុងការបញ្ចេញមតិកាន់តែមានសភាពខ្លាំងក្លាលើប្រព័ន្ធអ៊ីនធឺណែត ឱកាសកាន់តែមានច្រើនសំរាប់ការបង្ខូចកេរ្តិ៍ឈ្មោះនៅលើបណ្តាញ។ ជាទូទៅដំណោះស្រាយនៃការបង្ខូចកេរ្តិ៍ឈ្មោះតំរូវឲ្យមានតុល្យភាពរវាងបុព្វហេតុប្រឆាំងគ្នាជាច្រើនៈ បុព្វហេតុរបស់បុគ្គលក្នុងការចង់កត្តិយស និង បុព្វហេតុសង្គមដែលជំរុញសិទ្ធិក្នុងការបញ្ចេញមតិឲ្យកាន់តែប្រសើរ។ នៅលើប្រព័ន្ធអ៊ីនធឺណែតក៏នៅមានភាពស្មុគ្រស្មាញបន្ថែមទៀតទាក់ទងនឹងតំលៃវប្បធម៌ដែលផ្តល់ទំងន់ទៅលើបុព្វហេតុបុគ្គល និងសង្គម។

រឿងរ៉ាវដែលអាចធ្វើឲ្យយើងយល់អំពីការបង្ខូចកេរ្តិ៍ឈ្មោះនេះ គឺពាក់ព័ន្ធនឹងលោក Joseph Gutnick ដែលជាអ្នកជំនួញនៅទីក្រុង Melbourne ប្រទេសអូស្រ្តាលី។ ទស្សនាវដ្តី Barron's របស់ក្រុមហ៊ុន Dow Jones បានបង្ខូចកេរ្តិ៍ឈ្មោះលោក Gutnick នៅក្នុងអត្ថបទរបស់ខ្លួន។ ទស្សនាវដ្តីនេះមានអ្នកជាវជាប្រចាំចំនួន ១៤ នាក់ នៅក្នុងប្រទេសអូស្រ្តាលី ក្នុងនោះមាន ៥ នាក់ នៅទីក្រុង Victoria ដែលនេះជាលក្ខខ័ណ្ឌគ្រប់គ្រាន់សំរាប់តុលាការជាន់ខ្ពស់អូស្រ្តាលីប្រើនីតិវិធីច្បាប់។[31] ទស្សនាវដ្តី Barron's មានអ្នកជាវ ប្រចាំនៅលើបណ្តាញចំនួន ១៧០០ នាក់ដែលបង់ប្រាក់តាមក្រេឌីដកាដអូស្រ្តាលី។ អ្វីដែលយើងអាចចោទសួរបាននោះគឺ បើសិនជាលោក Gutnick ឈ្នះរឿងក្តីនេះ តើអត្ថបទនីមយៗដែលបានចុះផ្សាយហើយនោះ អាចចាត់ទុកជាខ្នាតសំរាប់គិតសំណងជំងឺចិត្តដែរឬទេ នៅក្នុងប្រទេសដែលមានការរិតត្បិតក្នុងរឿងបង្ខូចកេរ្តិ៍ឈ្មោះមួយនេះ? ជាសំណាងល្អ តុលាការជាន់ខ្ពស់បានសំរេចឲ្យមានសំណងជាទឹកប្រាក់ទៅឲ្យលោក Gutnick ដោយកំណត់នូវការខូចខាតផ្នែកកិត្តយសដែលមានតែនៅក្នុងទីក្រុង Melbourne ប៉ុណ្ណោះ មិនមែនទូទាំងពិភពលោកឡើយ។[32] តុលាការហាក់ដូចជាគ្រាន់តែពិចារណាទៅលើការខូចខាតជាក់ស្តែងដែលបង្កឡើងដោយអត្ថបទបង្ខូចកេរ្តិ៍ឈ្មោះមួយនេះ ដែលនេះជាអ្វីដែលកម្រមាននៅក្នុងតុលាការប្រទេស Commonwealth។

---

[31] David Fickling និង Stuart Millar "របៀបដែលករណីបង្ខូចកេរ្តិ៍ឈ្មោះលោក Diamond Joe អាចផ្លាស់ប្តូរអនាគតរបស់អ៊ីនធឺណែត" ទស្សនាវដ្តី Guardian លេខ ១១ ខែធ្នូឆ្នាំ ២០០២ http://www.guardian.co.uk/technology/2002/dec/11/media.newmedia.

[32] តុលាការជាន់ខ្ពស់អូស្រ្តាលី □ក្រុមហ៊ុន Dow Jones តទល់នឹងលោក Gutnick□ ថ្ងៃទី១០ ខែធ្នូ ២០០២ http://www.austlii.edu.au/au/cases/cth/high_ct/2002/56.html.

### ការងារត្រូវធ្វើ

ចូរឲ្យដំបូន្មានដល់ Y ដែលជាពលរដ្ឋម្នាក់ក្នុងប្រទេសរបស់អ្នក តាមស្ថានការណ៍ដូច តទៅ៖

ស្ថានការណ៍ទី១៖

គេហទំព័រព័ត៌មានរបស់ W បានបង្ខូចកេរ្តិ៍ឈ្មោះ Y។ តើមានអ្វីខុសគ្នាខ្លះ បើសិនជាគេហទំព័រនោះមានឬមិនមានប្រជាប្រិយភាពនោះ? ចុះបើសិនជាមានអត្ថបទចំនួន ២០០ បានធ្វើការការពារ Y?

ស្ថានការណ៍ទី២៖

ចុះបើសិនជាអង្គភាពសារព័ត៌មាននៅសហរដ្ឋអាមេរិចបានបង្ខូចកេរ្តិ៍ឈ្មោះក្រុមហ៊ុន របស់ Y។ តើគួរតែមាន "កាតព្វកិច្ចផ្លូវច្បាប់អន្តរជាតិ" សំរាប់ការបង្ខូចកេរ្តិ៍ឈ្មោះឬទេ?

អ៊ីនធឺណែតបានបង្ខំឲ្យមានការផ្លាស់ប្តូរមួយទៀតនៅក្នុងច្បាប់គ្រប់គ្រងអ៊ីនធឺណែត៖ វាតំរូវឲ្យមានការលើកលែងទោសដែលបង្កឡើងដោយខ្លឹមសារបង្កើតឡើងដោយភាគីទី៣។ នេះមានន័យថាគេហទំព័រ និងវេទិកាដែលជាអ្នកទទួលផ្សព្វផ្សាយខ្លឹមសាររបស់អ្នកដទៃ មិនគួរមានកាតព្វកិច្ចចំពោះមុខច្បាប់ឡើយ ក្នុងករណីដែលពួកគេបានចាត់វិធានការសមស្រប បន្ទាប់ពីបានទទួលការជូនដំណឹងអំពីខ្លឹមសារបង្ខូចកេរ្តិ៍ឈ្មោះមក។ នៅក្នុងចំណាត់ការតាមផ្លូវច្បាប់ភាគច្រើន ចាត់វិធានការសមស្រប មានន័យថាការដកចេញនៃ ខ្លឹមសារបង្ខូចកេរ្តិ៍ឈ្មោះនោះឲ្យបានក្នុងចំនួនថ្ងៃដែលបានកំណត់។[33] ដំណើរការនេះក៏ត្រូវបានគេឲ្យ ឈ្មោះថាលក្ខន្តិកៈ "ផ្តល់ដំណឹងនិងអនុវត្តតាម" ។

[33] សូមមើល Ang (2005).

## ៥.៤ សិទ្ធិអ្នកនិពន្ធ និងកម្មសិទ្ធិបញ្ញាដទៃៗទៀត

**រូបភាពទី៣. ការថ្លឹងថ្លែងនៃកម្មសិទ្ធិបញ្ញា**

( ប្រភព៖ គ្រឹះស្ថាន Diplo http://textus.diplomacy.edu/textusbin/env/scripts/Pool/GetBin.asp?IDPool=1181 )




លក្ខន្តិកៈលើកលែងទោសស្រដៀងគ្នានេះ មានភាពចាំបាច់សំរាប់ការរក្សាសិទ្ធិ។ នេះមានន័យថា គេហទំព័រ និងវេទិកាដែលទទួលយកខ្លឹមសារដែលនិពន្ធដោយអ្នកដទៃទៀតមកផ្សព្វផ្សាយ មិនគួរមានកាតព្វកិច្ច ចំពោះមុខច្បាប់សំរាប់ខ្លឹមសារណាមួយដែលអាចរំលោភលើការរក្សាសិទ្ធិឡើយ បើសិនជាគេបានចាត់វិធាន ការសមស្រប បន្ទាប់ពីទទួលបានការជូនដំណឹងអំពីការបំពាននេះ។ មានប្រទេសកាន់តែច្រើនទៅៗបាន ប្រកាន់យកលក្ខន្តិកៈផ្តល់ដំណឹងនិងអនុវត្តតាមរបស់អាមេរិចនេះ សំរាប់ការរក្សាសិទ្ធិ។ លក្ខន្តិកៈបែបនេះ តំរូវឲ្យមានប្រសិទ្ធភាពនៃការផ្តល់ដំណឹងណាមួយដើម្បីឲ្យមានការអនុវត្តតាម។ ទាល់តែបុគ្គលដាក់បណ្តឹង ពីការរំលោភការរក្សាសិទ្ធិអាចដកពាក្យបណ្តឹងចេញ វិញនិងអនុញ្ញាតឲ្យមានការផ្សាយស្នាដៃរបស់ខ្លួន បើពុំនោះទេការចោទប្រកាន់នេះនឹងត្រូវដោះស្រាយ ដោយតុលាការ។

ផ្នែកមួយនៃកម្មសិទ្ធិបញ្ញាដែលមានភាពចំរូងចំរាស់នោះ គឺថាតើឈ្មោះដូម៉េនគួរតែចាត់ទុកជាយីហោរបស់ក្រុមហ៊ុន ដែលចុះបញ្ជីដាច់មុខស្របច្បាប់សំរាប់ក្រុមហ៊ុនជំនួញណាមួយដែរឬទេ។ សំរាប់ក្រុមហ៊ុនជំនួញអន្តរជាតិ ច្បាប់បែបនេះនឹងបន្ធូរបន្ថយបន្ទុកនៃការចុះបញ្ជីឈ្មោះក្រុមហ៊ុន នៅគ្រប់ប្រទេសទាំងអស់។ ច្បាប់នេះមានន័យថាបើសិនជានរណាម្នាក់បានប្រើឈ្មោះក្រុមហ៊ុនអន្តរជាតិរបស់គេមកធ្វើជាឈ្មោះដូម៉េន ដោយគ្មានច្បាប់អនុញ្ញាតត្រឹមត្រូវ បុគ្គលនោះបានរំលោភបំពានលើច្បាប់កម្មសិទ្ធិបញ្ញា ហើយត្រូវតែប្រគល់ឈ្មោះដូម៉េននោះមកវិញ។

ដំណោះស្រាយជំលោះទូទៅរបស់ ICANN អាចត្រូវបានប្រើដើម្បីដោះស្រាយបញ្ហានេះ ក្នុង កំរិតពិភពលោក។ ប៉ុន្តែនៅក្នុងប្រទេសនីមួយៗ ច្បាប់ជាតិមានសារៈសំខាន់ក្នុងការធ្វើមឲ្យមានភាព ច្បាស់លាស់នៃសិទ្ធិទាក់ទងនឹង ccTLD។

### សំនួរពិចារណា

១.តើឈ្មោះដូម៉េនគួរតែចាត់ទុកជាយីហោមុខជំនួញដែរឬទេ? ហេតុអ្វីគួរ ឬហេតុអ្វីមិនគួរ?
២.តើអ្នកនឹងថ្លឹងថ្លែងផលប្រយោជន៍ជាតិរបស់អ្នក និងម្ចាស់កម្មសិទ្ធិបញ្ញាដែលអាចជាបុគ្គលដែលមកពីប្រទេសដែលមានការអភិវឌ្ឍន៍ជាង ដោយរបៀបណា?

## ៥.៥ ភាពឯកជន

ដូចដែលបានសង្កេតកន្លងមក ច្បាប់អំពីភាពឯកជនត្រូវតែមាននៅទីនេះ។ អ្វីដែលត្រូវចោទសួរនោះ គឺៈ តើគំរូមួយណាគួរយកមកប្រើដើម្បីដាក់បទបញ្ញាលើភាពឯកជននេះ? មានគំរូសំខាន់ៗពីរ ដែលមានបែបបទខុសគ្នាយ៉ាងខ្លាំង។ នៅក្នុងគំរូរបស់ EU ភាពឯកជនមានតំលៃស្មើនឹងសិទ្ធិ មនុស្សដែលមិនអាចត្រូវបានគេទិញ លក់ ឬដោះដូរឡើយ ម៉្យាងទៀតវាសាកសមនឹងមានច្បាប់ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ។ ក្នុងគំរូរបស់សហរដ្ឋអាមេរិច ភាពឯកជនគឺសិទ្ធិស្របច្បាប់ដែលមានតំលៃ សំរាប់ការធ្វើកិច្ចសន្យាណាមួយ។ ឧទាហរណ៍ គេអាចព្រមព្រៀងផ្តល់អាស័យដ្ឋានអ៊ីម៉េលរបស់ខ្លួន ដើម្បីអាចអានឯកសារមួយចំនួន ឬទទួលបានសេវាកម្មណាមួយ។ ការធ្វើនីតិកម្មច្បាប់សំរាប់គំរូនេះមិនមានលក្ខណៈគ្រប់ជ្រុងជ្រោយឡើយ ប៉ុន្តែសង្កត់ធ្ងន់ទៅលើវិស័យមួយចំនួន។

នៅលើអ៊ីនធឺណែត គំរូទាំងពីរនេះមានលក្ខណៈស្រដៀងគ្នាទាំងការអនុវត្ត និងលទ្ធផល។ វាជាការពិតណាស់ដែលគំរូរបស់ EU មានការដាក់ទណ្ឌកម្មច្រើនជាង ដែលធ្វើឲ្យមានការបន្ថែមទៅលើការ ចំណាយ។

កត្តាវប្បធម៌និងប្រវត្តិសាស្ត្ររបស់ប្រទេសមួយនឹងជំរុញឲ្យប្រទេសនោះ ជ្រើសរើសគំរូណាមួយដែលសមស្រម។ ក៏ប៉ុន្តែគំរូរបស់ EU មានសក្តានុពលក្នុងការយកទៅប្រើប្រាស់ជាអន្តរជាតិ បើសិនជាច្បាប់ការពារទិន្នន័យត្រូវបានពង្រឹង។

### សំនួរពិចារណា

១.នៅក្នុងប្រទេសរបស់អ្នក តើក្នុងកំរិតណា ដែលភាពជាឯកជនត្រូវបានចាត់ទុកជាគំរូការស្របច្បាប់របស់អ្នកប្រើប្រាស់?

២.តើប្រទេសរបស់អ្នកមាននិន្នាការប្រកាន់យកគំរូ EU ឬគំរូសហរដ្ឋអាមេរិច សំរាប់ការដាក់បទបញ្ញាលើភាពជាឯកជន? ហេតុអ្វីបានជាអ្នកគិតដូច្នោះ?

## សរុបសេចក្តី

នីតិវិធីក្នុងការដាក់បទបញ្ញាគួរតែមានតម្លាភាព មានការចូលរួមពីអ្នកពាក់ព័ន្ធច្រើន និងមានប្រជាធិប តេយ្យ។ នេះមានន័យថា នីតិវិធីនេះគួរមានការផ្តល់យោបល់ ពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់។ ការដាក់បទបញ្ញាគួរធ្វើការពិចារណាទៅលើប្រភេទទាំង ៤ នៃការដាក់បទបញ្ញាៈ ទីផ្សា ក្រឹត្យក្រមសង្គម ស្ថាបត្យកម្ម និងបទបញ្ញារបស់រដ្ឋាភិបាល (ដោយរួមបញ្ចូល បទបញ្ញាផ្ទៃក្នុង ព្រោះថាដើម្បីទទួលបានប្រសិទ្ធភាព បទបញ្ញាផ្ទៃក្នុងត្រូវការឲ្យមានការចែករំលែកអំណាចពីរដ្ឋាភិបាល)។

### សាកល្បងខ្លួនឯង

១.តើអ្វីខ្លះជាភាពពាក់ព័ន្ធរបស់នយោបាយប្រកួតប្រជែងនៅក្នុងការទទួលបានសេវាអ៊ីនធឺណែត?

២.តើការត្រួតពិនិត្យលើប្រព័ន្ធអ៊ីនធឺណែតធ្វើឲ្យមានការទទួលយក ដោយការអត់ទ្រាំ ឬស្ម័គ្រចិត្ត ក្នុងកំរិតណា?

៣.តើអ្នកប្រើប្រាស់អ៊ីនធឺណែតអាចបង្ខូចកេរ្តិ៍ឈ្មោះនរណាម្នាក់នៅលើបណ្តាញ ហើយរួចខ្លួនដោយងាយឬទេ?

៤.តើច្បាប់បង្ខូចកេរ្តិ៍គួរតែត្រូវធ្វើការកែសំរួលដើម្បីសំរបទៅតាមអ៊ីនធឺណែតដែរឬទេ?

៥.តើបញ្ហាចំរូងចំរាស់សំខាន់ៗអ្វីខ្លះ ទាក់ទងនឹងការរក្សាសិទ្ធិ និងច្បាប់កម្មសិទ្ធិបញ្ញាដទៃៗទៀតនៅលើប្រព័ន្ធអ៊ីនធឺណែត?

៦.តើវិធីទាំងពីរ ក្នុងការការពារទិន្នន័យនិងភាពជាឯកជន មានអ្វីខ្លះ ហើយពួកវាមានលក្ខណៈខុសគ្នាដូចម្តេចខ្លះ?

# ៦. ទំហំនៃការអភិវឌ្ឍន៍៖ ភាពខុសគ្នានៃគំរិតឌីជីថល

ផ្នែកនេះរៀបរាប់អំពីរបៀបដែលអ៊ីនធឺណែតត្រូវបានប្រើសំរាប់ការអភិវឌ្ឍន៍នៃសង្គម និង សេដ្ឋកិច្ច ព្រមទាំងបណ្តាចំនុចខ្វះខាតរបស់ ICTD។

ការអភិវឌ្ឍជាតិគឺជាកត្តាជំរុញមួយសំរាប់ WSIS ដែលបណ្តាលឲ្យមានការពិភាក្សាអំពីការអភិបាលអ៊ីនធឺណែត។ ទោះជាយ៉ាងណាក៏ដោយ ការអភិវឌ្ឍន៍គឺជាជ្រុងមួយដ៏ធំ ដែលត្រូវចំណាយពេលជាច្រើនទស្សវត្សដើម្បីដោះស្រាយ។ គេមានសេចក្តីសង្ឃឹមទៅលើ ICT ដោយរួមទាំងអ៊ីនធឺណែតដោយសារពួកវាអាចជួយបង្កើនល្បឿននៃដំណើរការអភិវឌ្ឍន៍។

## ៦.១ ICT សំរាប់ការអភិវឌ្ឍន៍

ដើម្បីទទួលបានប្រសិទ្ធភាពរបស់ខ្លួន ICTD បានរួមបញ្ចូលប្រធានបទដូចជា (ក) ការអភិបាល និងការផ្តល់អំណាច (ខ) ហេដ្ឋារចនាសម្ព័ន្ធ (គ) ការអភិវឌ្ឍសេដ្ឋកិច្ច និង(ឃ) ការអភិវឌ្ឍសង្គម។ បើគ្មានការអភិបាលសមស្របទេ ធនធានថវិកានិងបាត់បង់ទៅដោយអត់ប្រយោជន៍។ បើគ្មានការផ្តល់អំណាចអ្នកប្រើប្រាស់មិនមានអារម្មណ៍ថាខ្លួនអាចផ្លាស់ប្តូរស្ថានការណ៍របស់ខ្លួនបាន។ បើគ្មានហេដ្ឋារចនាសម្ព័ន្ធដូចជាភ្លើងអគ្គីសនី ឬខ្សែទំនាក់ទំនងទូរគមនាគមន៍ វានឹងមិនអាចធ្វើឲ្យអ៊ីនធឺណែតមានចីរភាពបានឡើយ។

WSIS បានជួយបង្កើតថវិកាសាមគ្គីឌីជីថល (Digital Solidarity Fund)។ គោលដៅអភិវឌ្ឍន៍សហសវត្ស (MDG) គឺជាអ្នកនាំផ្លូវដ៏ល្អ សំរាប់ឲ្យដឹងថាថវិកាគួរចំណាយយ៉ាងណា។ MDG មានដូចជា៖

១. លុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លាន
២. ទទួលបានការអប់រំមូលដ្ឋានជាសកល
៣. លើកតំកើងសមភាពនៃជេនឌ័ និងការឲ្យអំណាចដល់ស្ត្រី
៤. កាត់បន្ថយការស្លាប់របស់កុមារ
៥. ធ្វើឲ្យប្រសើរនៃសុខភាពមាតា
៦. ប្រយុទ្ធនឹងជំងឺ HIV/AIDS គ្រុនចាញ់ និងជំងឺដទៃទៀត

៧. ធានានិរន្តភាពនៃបរិស្ថាន

៨. បង្កើតភាពជាដៃគូអភិវឌ្ឍន៍ជាសកល

*មេរៀនទី១ ក្នុងក្រុមមេរៀន Acedemy of ICT Essentials for Government Leaders បានពិភាក្សាអំពីទំនាក់ទំនងរវាង ICT និង MDG*

### អ៊ីនធឺណែតតាមភូមិ

ក្នុងនាមជាបច្ចេកវិទ្យាដ៏ទំនើបនិងមានឥទ្ធិពល អ៊ីនធឺណែតមានសក្តានុពលក្នុងការធ្វើឲ្យ មានគំលាតប្រាក់ចំណូលរវាងអ្នកដែលប្រើវា និងអ្នកដែលមិនប្រើវា។ ក្នុងចំណោមករណី ជាច្រើនដែលធ្វើឲ្យឃើញ ច្បាស់នោះគឺអាចជាភាពខុសគ្នាដែលមាននៅក្នុងប្រទេសឥណ្ឌា។ នៅទីនោះ បច្ចេកវិទ្យាដែលទំនើបចុងក្រោយបំផុតត្រូវបានគេ ឃើញនៅទីក្រុងធំៗ។ ប៉ុន្តែនៅជនបទប្រទេសឥណ្ឌាវិញ គឺជាកន្លែងដែលជនជាតិឥណ្ឌាហៅ □ភាពអន្ធការនៃសារព័ត៌មាន□ ដោយសារនៅទីនោះមិនមានទូរទស្សន៍សំរាប់ប្រើប្រាស់ឡើយ។

ដើម្បីផ្សព្វផ្សាយការប្រើប្រាស់អ៊ីនធឺណែត និងដោះស្រាយបញ្ហាសង្គម ក្នុងឆ្នាំ ២០០៧ រដ្ឋាភិបាលឥណ្ឌាបានអនុវត្តគំរោងជាតិសំរាប់អភិបាលកិច្ចតាមបែបអេឡិចត្រូនិច ដែលត្រូវបានគេហៅថា គំរោងមជ្ឈមណ្ឌលផ្តល់ សេវាកម្មទូទៅ (Common Service Center (CSC) Scheme) ដែលក្នុងនោះ មានភូមិចំនួន ៦០០០០០ ក្នុងប្រទេស ឥណ្ឌា ដែលធ្វើការចែករំលែក មជ្ឈមណ្ឌលចំនួន ១០០០០០ ដែលជាតូបផ្តល់សេវាអ៊ីនធឺណែត។

តូបអ៊ីនធឺណែតកាលជំនាន់នោះមិនមានកំរិតជោគជ័យខ្ពស់ឡើយ។ តាមពិតទៅ ជំនាន់ទី ១ នៃតូបទាំងនោះមានកំរិតជោគជ័យតែ ៣ ភាគរយប៉ុណ្ណោះ ដែលភាពជោគជ័យក្នុងករណីនេះត្រូវវាស់ដោយនិរន្តភាពបន្ទាប់ពីរយៈពេល ១ឆ្នាំ។ ជាមួយនឹងមេរៀននេះ ជំនាន់ទី ២ បានទទួលភាពជោគជ័យចំនួន ៣០ភាគរយ ដែលជាការរីកចំរើន ១០ដង លើសមុន ប៉ុន្តែវាក៏មានន័យថានៅតែបរាជ័យចំនួន ៧០ភាគរយផងដែរ។ គំរោង CSC នេះគឺជាការសាកល្បង ជំនាន់ទី ៣ វាគឺជាលទ្ធផលនៃការសិក្សាស្រាវជ្រាវចុងក្រោយបំផុតទាក់ទងនឹងកម្មវិធីប្រើប្រាស់ណាខ្លះដែលមាន ប្រយោជន៍សំរាប់អ្នកភូមិ ក៏ដូចជាជួយផ្លាស់ប្តូរជីវិតរស់នៅរបស់ពួកគេ។

ឧទាហរណ៍ រដ្ឋាភិបាលឥណ្ឌាបានអនុញ្ញាតឲ្យប្រជាជនទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីតាមរយៈ អ៊ីនធឺណែត ពីព្រោះនៅក្នុងភូមិ ពួកមន្ត្រីពុករលួយជួនកាលបោកប្រាស់ប្រជាជនទាក់ទងនឹងបញ្ហដីធ្លី នេះ។ ការថតចំលង CD និងការបោះពុម្ពរូបថតឌីជីថលត្រូវបានគេរកឃើញថាជាសកម្មភាពសំរាប់ បង្កើតប្រាក់ចំណូលផងដែរ។ នៅក្នុងរដ្ឋ Chennai គំនិតផ្តួចផ្តើមជំនួញឯកជនមួយបានបង្ហាញឲ្យ ឃើញថាការដាក់វិញ្ញាសារប្រឡងនៅលើបណ្តាញគឺធ្វើឲ្យមានការប្រែប្រួលជាខ្លាំង។ ពីដំបូងចំនួនអ្នក ភូមិដែលបានជាប់ការប្រឡងធំៗមានចំនួនតិចតួច ប៉ុន្តែបន្ទាប់ពីពួកគេបានហ្វឹកហាត់ជាមួយនឹង វិញ្ញាសារប្រឡងនៅលើបណ្តាញអ្នកប្រឡងជាប់មានចំនួនស្ទុះឡើង។ ជំនឿចិត្តដែលកើតចេញពីករណី ប្រឡងជាប់របស់ប្រជាជនគឺជាសញ្ញាវិជ្ជមានមួយ។

គំរោង CSC គឺជាគំនិតដែលកើតចេញពីការស្រមើស្រម៉ៃមួយ។ ក្រៅពីការប្រើអ៊ីនធឺណែតដើម្បីដោះស្រាយបញ្ហាសង្គម (ដូចជា ការរំលោភយកដីខុសច្បាប់) និងកាត់បន្ថយគំលាតឌីជីថល គេក៏ប្រើអ៊ីនធឺណែតក្នុងគោលបំណងផ្តល់ការងារមួយចំនួន។ អ្នកប្រតិបត្តិការនៅតូបអ៊ីនធឺណែតដែលតាំងនៅក្នុងភូមិនឹងក្លាយជាសហគ្រិនឯកជន។ បើតាមទ្រឹស្តី វាមានន័យថារដ្ឋាភិបាលថ្នាក់ជាតិនឹងចំណាយថវិកាតិចតួចប៉ុណ្ណោះ ក្នុងខណៈដែលរដ្ឋាភិបាល របស់រដ្ឋនីមួយៗត្រូវបានរំពឹងថានឹងចូលវិភាគទានជា សាច់ប្រាក់ចំណែកឯការចូលរួមរបស់ផ្នែកឯកជននឹងធ្វើឲ្យការចំណាយកើនឡើង។ គំរោងនេះកំពុង ត្រូវបានគេអនុវត្ត។ លទ្ធផលយ៉ាងណានោះ វាមានតំលៃសំរាប់ការតាមដានមើល។

## ៦.២ ដែនកំណត់ និងឧបសគ្គ

មកដល់ចំនុចនេះ យើងគួរតែមានគំនិតដែលយល់ថាមានដែនកំណត់ចំពោះការប្រើប្រាស់ ICTD។ ឧទាហរណ៍ ការប្រើប្រាស់ ICTD ត្រូវតែសន្មត់ថា ព័ត៌មានមានគុណភាពមានតំលៃស្មើនឹងការសំរេចចិត្តដែលមានគុណភាព ដែលនេះមិនប្រាកដថាត្រឹមត្រូវគ្រប់ស្ថានការណ៍ឡើយ។ ម្យ៉ាងវិញ កម្មវិធីប្រើប្រាស់ ICT ជាច្រើន គឺសំរាប់តែជាមធ្យោបាយផ្តល់ព័ត៌មាន ឬធ្វើប្រតិបត្តិការលើព័ត៌មាន ហើយមិនមែនជាមធ្យោបាយសំរាប់ទំនាក់ទំនងឡើយ ក្នុងខណៈដែលការអាស្រ័យទាក់ទងគ្នាទៅវិញទៅមកធ្វើឲ្យមានលទ្ធផលប្រាកដប្រជាមួយសំរាប់ការអភិវឌ្ឍន៍នោះ។ ម្យ៉ាងទៀត មានឧបសគ្គជា ច្រើនដែលហួសពីសមត្ថភាពគ្រប់គ្រងរបស់បុគ្គលម្នាក់។ ភាសាអាចជាឧបសគ្គមួយ។ អំពើពុករលួយក៏ជាឧបសគ្គមួយទៀតផងដែរ។

តំលៃនៃការចំណាយនៅតែជាការគិតចំបងមួយ ដែលវាអាចនឹងត្រូវកាត់បន្ថយបាន។ ទី១ តំលៃនៃផ្នែករឹង (hardware) អាចត្រូវបានកាត់បន្ថយ។ ទី២ ក៏មានការផ្តល់ជូននូវផ្នែកទន់ (software) ដែលស្ថិតនៅក្រោមលក្ខខណ្ឌមិនគិតថ្លៃ និងបើចំហរកូដ (FOSS)។ គេគួរកត់សំគាល់ថា FOSS អាចមិនមែនជាមធ្យោបាយកាត់បន្ថយចំណាយ ដោយសារវាត្រូវការថែទាំ និងតំលើងជាមួយផ្នែកផ្សេងៗបញ្ចូលគ្នា ឧទាហរណ៍ កម្មវិធីម៉ាស៊ីនព្រីនអាចនឹងមិនមាន ដែលតំរូវឲ្យមានការបង្កើតកម្មវិធីនេះជាពិសេស។

## ៦.៣ ការប្រើប្រាស់ ICTD

មានការប្រើប្រាស់ ICTD ជាច្រើនត្រូវបានគេស្គាល់និងធ្វើការសាកល្បងជាច្រើនដង។ ដូចដែលបានពោលកន្លងមក ភាគច្រើននៃការប្រើប្រាស់ទាំងនេះស្ថិតក្នុងប្រភេទផ្តល់ព័ត៌មាន។ កម្មវិធីប្រើ ប្រាស់របស់ ICTD អាចត្រូវបាន ឃើញក្នុងវិស័យកសិកម្ម អប់រំ សេវាសុខភាព និងទេសចរណ៍។ ជាញឹកញាប់ គេទទួលស្គាល់ថា ការទទួលព័ត៌មានកាន់តែល្អក្នុងវិស័យទាំងនេះនឹងនាំទៅរក លទ្ធផលកាន់តែល្អ។ ឧទាហរណ៍ ការទទួលចំណេះដឹងអំពីរុក្ខជាតិដែលមានប្រយោជន៍សំរាប់ កសិករ។

ទំនាក់ទំនង គឺជាប្រយោជន៍របស់ ICTD ដែលមានលើសពីប្រយោជន៍របស់ព័ត៌មានទៅទៀត។ ឧទាហរណ៍ បន្ទាប់ពីបានដាំដុះរុក្ខជាតិរួចរាល់ហើយនោះ វានឹងមានអត្ថប្រយោជន៍ជាខ្លាំងក្នុងការដឹងពីវិធីប្រឆាំងនឹងសត្វចង្រៃដែលបំផ្លាញរុក្ខជាតិ។ កត្តានេះជាអ្វីដែល ICTD បានសន្យាយ៉ាងមុតមាំក្នុង ការបង្កលក្ខណៈឲ្យមានទំនាក់ទំនងដែលល្អតាមដែលអាចធ្វើទៅបាន។

ជាក់ស្តែង ការសន្យាទាំងនេះរបស់ ICTD ត្រូវបានធ្វើឡើងតាមរយៈការផ្តល់សេវារដ្ឋាភិបាលតាមបែបអេឡិចត្រូនិច (e-government)។ ឧទាហរណ៍មួយចំនួននៃសេវា e-government មានដូចជា៖ ការដាក់ពាក្យសុំទិដ្ឋការ ពន្ធដារ ប័ណ្ណកម្មសិទ្ធដីធ្លី ប័ណ្ណបើកបរ និងសូម្បីតែពាក្យស្នើសុំដែលអាចទាញយក ពីបណ្តាញ។ ដើម្បីចាប់ផ្តើមការផ្តល់សេវាបែបនេះ រាល់ការិយាល័យរបស់រដ្ឋាភិបាលទាំងអស់ត្រូវតែបំពាក់ដោយប្រព័ន្ធកុំព្យូទ័រ។ គោលបំណងនៃការបំពាក់ប្រព័ន្ធកុំព្យូទ័រគឺដើម្បីបង្កើនប្រសិទ្ធភាពរបស់រដ្ឋាភិបាល។ ឧទាហរណ៍ ការបង្កលក្ខណៈឲ្យអ្នកផ្តល់សេវារបស់រដ្ឋាភិបាលធ្វើការផ្ទាល់នៅលើ បណ្តាញ បានបង្ហាញឲ្យឃើញថាជាការសន្សំសំចៃក្នុងការចំណាយ។ ជាមួយនឹងប្រព័ន្ធកុំព្យូទ័រ ដំណើរការប្រតិបត្តិការងារមានតម្លាភាព កាត់បន្ថយអំពើពុករលួយ។ ការបង្កើតប្រព័ន្ធកុំព្យូទ័រធ្វើឲ្យមានដំណើរការនៃសេដ្ឋកិច្ចបច្ចេកវិទ្យាព័ត៌មាន ដែលមានន័យថាការបង្កើតអាជីពការងារខាងព័ត៌មានវិទ្យាសំរាប់អ្នកបច្ចេកទេស និងអ្នកសរសេរកម្មវិធីកុំព្យូទ័រ។ ការផ្ជួបផ្គុំរវាងការប្រើប្រព័ន្ធកុំព្យូទ័រនិងប្រព័ន្ធអ៊ីនធឺណែតធ្វើឲ្យមានការបើកចំហរកាន់តែទូលំទូលាយនៃវេទិកាពិភាក្សាដែលចូលរួមដោយពលរដ្ឋ លើបញ្ហាសាធារណៈសំខាន់ៗ។ ការសំរេចបានដូចនេះ នឹងនាំទៅរកការផ្តល់អំណាចដល់ប្រជាពលរដ្ឋកាន់តែច្រើន ដែលជាការចាប់ផ្តើមនៃខ្សែរង្វង់អភិវឌ្ឍន៍ប្រកបដោយសមធម៌។ *(មេរៀនទី៣ ក្នុងក្រុមមេរៀន Acedemy of ICT Essentials for Government Leaders គឺនិយាយអំពី បំរើបំរាស់នៃ ICT ក្នុង e-Government។)*

កំរិតតម្លាភាពកាន់តែខ្ពស់ដែលផ្តល់ដោយ e-government ត្រូវបានគេនិយាយជាញឹកញាប់ថាជាការនាំផ្លូវទៅរករបបប្រជាធិបតេយ្យកាន់តែប្រសើរ។ នេះមិនមែនជាគោលដៅតែមួយដែលចង់សំរេចបាននោះឡើយ។ តាមពិតទៅ សេវាដែលផ្តល់ដោយ e-government ធ្វើឲ្យរដ្ឋាភិបាលថ្នាក់កណ្តាលអាចក្តាប់ការគ្រប់គ្រងបានច្រើនជាងមុន។ រដ្ឋាភិបាលថ្នាក់កណ្តាលងាយស្រួលក្នុងការដឹងអំពើអ្វីដែលកំពុងកើតឡើងនៅថ្នាក់មូលដ្ឋានដែលជាកន្លែងផ្តល់សេវាផ្ទាល់នោះ។ ក្នុងស្ថានភាពបែបនេះ ការផ្តល់សេវរបស់រដ្ឋាភិបាលបានឆ្លើយតបទៅនឹងតំរូវការនៅថ្នាក់មូលដ្ឋាន ដែលជាមូលហេតុអាចកាត់បន្ថយអំពើពុករលួយ។[34]

## សរុបសេចក្តី

[34] លោក R.Kluver, សមាសភាពផ្សំនៃការគ្រប់គ្រង៖ យុទ្ធសាស្ត្រប្រទេសចិនសំរាប់អភិបាលកិច្ចបែបអេឡិចត្រូនិច នៅក្នុងអត្ថបទឈ្មោះ □ប្រព័ន្ធអ៊ីនធឺណែត និងការអភិបាល៖ បរិបទពិភពលោក□ នៃកំរងអត្ថបទស្រាវជ្រាវអំពីគោលនយោបាយសាធារណៈលេខ ២៥, ១ ( ឆ្នាំ២០០៥) ទំព័រ ៧៥-៩៧

ការអភិវឌ្ឍន៍គឺជាគោលបំណងចំបងមួយរបស់ WSIS ដែលនាំទៅរកការបង្កើត WGIG។ ប៉ុន្តែប្រធានបទនៃការអភិវឌ្ឍន៍នេះមិនបានទទួលនូវចំណាប់អារម្មណ៍គ្រប់គ្រាន់ក្នុង របាយចុងក្រោយ របស់ WGIG ឡើយ ហើយប្រធានបទនេះជាញឹកញាប់ត្រូវគេមើលរំលងនៅក្នុងកិច្ចពិភាក្សាអំពីការអភិបាលអ៊ីនធឺណែត។ ប្រាកដណាស់ សហគមន៍អន្តរជាតិអាចធ្វើការងារទាក់ទងនឹងប្រធានបទនេះបានយ៉ាងច្រើន តាមរយៈការផ្តល់ថវិការផ្គត់ផ្គង់គំរោង ICTD។ ភាពជាដៃគូរវាងផ្នែកឯកជន និង សាធារណៈ (PPP) គឺជាយុទ្ធសាស្រ្តសំរាប់ធ្វើឲ្យមាននិរន្តភាពនៃការអភិវឌ្ឍន៍ ដោយសារវាអនុញ្ញាតិឲ្យមានការចែករំលែកបន្ទុកចំណាយ និងរៀបចំគ្រោងឆ្អឹងនៃគំរោងដែលងាយនឹងទទួលបានជោគជ័យ។ *(ការប្រើប្រាស់ PPP សំរាប់ផ្គត់ផ្គង់ថវិកានៃគំរោង ICTD ត្រូវបានពិភាក្សានៅក្នុងមេរៀនទី៨ ក្នុងក្រុម មេរៀន Acedemy of ICT Essentials for Government Leaders។)* ប៉ុន្តែមានសកម្មភាពជាច្រើនដែលរដ្ឋាភិបាលជាតិអាចធ្វើ និងគួរធ្វើដើម្បីប្រើប្រាស់ ICTD។ តំលៃនៃសេវាត្រូវឲ្យទាបជាងមុនជាចាំបាច់។ ឧទាហរណ៍ តំលៃក្នុងការចុះឈ្មោះដូម៉េនត្រូវតែមានការបន្ទាបចុះ។ បន្ទាប់ពីនេះ ត្រូវមានការតាំងចិត្តផ្នែកនយោបាយដើម្បីបង្កើតបរិយាកាសដែលមានច្បាប់គាំទ្រដល់ ICTD។ ការប្រើប្រាស់របស់ ICTD គឺជាពិសេស សំរាប់ជាឧបករណ៍សំរាប់ទំនាក់ទំនង ដែលជាអត្ថប្រយោជន៍ខ្ពស់បំផុត។

**T សាកល្បងខ្លួនឯង**

១.តើអ៊ីនធឺណែតអាចត្រូវគេប្រើរបៀបណា ដើម្បីសំរេចបានគោលដៅអភិវឌ្ឍន៍?

២.តើមានដែនកំណត់ និងឧបសគ្គអ្វីខ្លះ ក្នុងការប្រើប្រាស់អ៊ីនធឺណែតដើម្បីសំរេចបានគោលដៅអភិវឌ្ឍន៍?

# ៧. ការអភិបាលប្រព័ន្ធអ៊ីនធឺណែត៖ ការប្រមើលមើលទៅមុខ

នៅក្នុងផ្នែកនេះ មានរាយបញ្ជីបញ្ហាសំខាន់ៗជាងគេមួយចំនួនដែលវេទិការអភិបាលអ៊ីនធឺណែតមិនអាចដោះស្រាយបានទាំងពេលបច្ចុប្បន្ន និងក្នុងពេលអនាគត ដែលបញ្ហាទាំងនោះទាមទារឲ្យមានការ យកចិត្តទុកដាក់ប្រុងប្រយ័ត្នពីបណ្តារដ្ឋាភិបាលទាំងអស់។

អណត្តិរយៈពេល ៥ឆ្នាំរបស់វេទិកាអភិបាលអ៊ីនធឺណែតត្រូវបញ្ចប់ក្នុងឆ្នាំ ២០១០។ ការធ្វើផែនការសកម្មភាពភាគច្រើនត្រូវបានលើកយកមកពិភាក្សានៅក្នុងរាល់កិច្ចប្រជុំពេញអង្គរបស់វេទិកា។ អត្ថប្រយោជន៍នៃការបង្កើតវេទិកានេះគឺសំរាប់ជាការផ្តល់នូវភស្តុតាងជាក់ស្តែង។ បើតាមគោលគំនិតវេទិកានេះមានតួនាទីសំរាប់ផ្តល់ជាឱកាសពិភាក្សាបញ្ហាសំខាន់ៗ ព្រមទាំងអាចអនុញ្ញាតឲ្យប្រទេសតូចៗលើកបញ្ហាដែលគេជួបប្រទះមកពិភាក្សា។ តាមការអនុវត្តជាក់ស្តែង វាបានបង្កើនការយល់ដឹងអំពីបញ្ហាទាក់ទងនឹងការអភិបាលអ៊ីនធឺណែត និងបានជួយបង្កើនការស្វែងយល់អំពីសារសំខាន់នៃដំណើរការអភិបាលអ៊ីនធឺណែត។

ប៉ុន្តែអ្វីដែលគួរឲ្យចង់សើចនោះ គឺភាគច្រើននៃសកម្មភាពជាក់ស្តែងក្នុងការងារអភិបាលអ៊ីនធឺណែតគឺកំពុងនឹងកើតឡើងស្របទៅនឹងរបៀបវារៈ និងឆន្ទៈផ្ទាល់របស់ភាគីដែលបានស្នើរបៀបវារៈទាំងនោះ ឡើង។ សកម្មភាពចូលរួមយ៉ាងសកម្មមួយចំនួន គឺគ្រាន់តែសំរាប់ឆ្លើយតបទៅនឹងគោលបំណងនៃ ក្រុមគេរៀងៗខ្លួនប៉ុណ្ណោះ ឧទាហរណ៍ របៀបវារៈស្តីពី spam គឺជាភាពសកម្មក្នុងការរៀបចំកិច្ចពិភាក្សា ដើម្បីដោះស្រាយបញ្ហា spam តែមួយមុខប៉ុណ្ណោះ។

បណ្តាបញ្ហាដែលលើកឡើងក្នុងរបាយការណ៍ចុងក្រោយរបស់ WGIG គឺជាការលំបាកដែលមិនងាយក្នុងការរកដំណោះស្រាយ ឧទាហរណ៍ បញ្ហានយោបាយទាក់ទិននឹងការគ្រប់គ្រងជាអន្តរជាតិនៃ ICANN និង DNS ត្រូវបានគេជៀសវាងមិនដោះស្រាយជាដរាបមក។ សហរដ្ឋអាមេរិចអាចប្រកាស □ជ័យជំនះ□ របស់ខ្លួនខណៈដែល ICANN នៅតែស្ថិតនៅក្នុងកណ្តាប់ដៃរបស់ខ្លួន។ នៅផ្នែកខាងក្នុងមានភាពចំរូងចំរាស់ស្ងប់ស្ងាត់ ទាក់ទងនឹងស្ថានភាពដែលថា ទោះជា ccTLD ស្ថិតក្នុងកណ្តាប់ដៃ

រដ្ឋាភិបាលនៃប្រទេសនីមួយៗ គ្មានអ្វីដែលជាឧបសគ្គសំរាប់សហរដ្ឋអាមេរិចលុបរដ្ឋាភិបាលណាមួយជាឯកតោភាគី ចេញពីការគ្រប់គ្រង ccTLD របស់ខ្លួនបានឡើយ។ ការរិតត្បិតបែបនេះមានជាលក្ខណៈអនុវត្តជាក់ស្តែង តែមិនមែនជាលក្ខណៈរូបវន្តឡើយ ដែលមានន័យថាលទ្ធភាពនៅតែមាន ទោះជាមិនទំនងនឹងកើតឡើក៏ដោយ សំរាប់ការកាត់ផ្តាច់ប្រទេសណាមួយចេញពីប្រព័ន្ធអ៊ីនធឺណែត។

បញ្ហាក្នុងក្រុមដទៃទៀតដែលគួរឲ្យចាប់អារម្មណ៍នោះ គឺអំពីការប្រើប្រាស់អ៊ីនធឺណែត បញ្ហាទាក់ទងនឹងអ៊ីនធឺណែតដែលប៉ះពាល់ដល់កត្តាដទៃទៀត និងផ្នែកអភិវឌ្ឍន៍ជំរុញដោយអ៊ីនធឺណែត ដែលបញ្ហាទាំងនេះមិនងាយនឹងមានដំណោះស្រាយឡើយ។ អ្វីដែលវេទិកាអភិបាលអ៊ីនធឺណែតអាចធ្វើ បាននោះគឺការជួយរំលេចនូវមេរៀនល្អៗជាងគេដើម្បីដោះស្រាយបញ្ហាទាំងនោះ។ ដូច្នេះការអភិវឌ្ឍន៍សមត្ថភាពក្នុងការអភិបាលអ៊ីនធឺណែតក៏ជាបញ្ហាដែលកំពុងជួបប្រទះដែលរដ្ឋាភិបាលទាំងអស់ត្រូវ ដោះស្រាយផងដែរ។

កិច្ចពិភាក្សាដែលជាបច្ច័យនៃរបាយការណ៍ចុងក្រោយរបស់ WGIG បានលើកយកបញ្ហាអំពីការលើកកំពស់ការយល់ដឹងអំពីសារសំខាន់នៃការអភិបាលអ៊ីនធឺណែត។ ដោយហេតុថា ការដោះស្រាយបញ្ហាទាំងនោះទាមទារពេលវេលា បណ្តារដ្ឋាភិបាលទាំងអស់ត្រូវកសាងសមត្ថភាពរបស់ពួកគេសំរាប់ដោះស្រាយបញ្ហា និងចូលរួមរាល់កិច្ចពិភាក្សាជាអន្តរជាតិលើបញ្ហាទាំងនោះ។ ការកសាងសមត្ថភាពនេះមានភាពចាំបាច់ ដោយសារការអភិបាលអ៊ីនធឺណែតមិនមែនគ្រាន់តែជាកិច្ចការក្នុងឆាកអន្តរជាតិ ប៉ុណ្ណោះទេ តែបញ្ហាភាគច្រើននៃការអភិបាលអ៊ីនធឺណែតគឺពាក់ព័ន្ធតំបន់នីមួយៗផ្ទាល់ ដែលក្នុងនោះ ICTD មានសារសំខាន់បំផុតសំរាប់រដ្ឋាភិបាលតាមតំបន់នីមួយៗ។ ដោយសារមូលហេតុនេះហើយរដ្ឋាភិបាលតាមតំបន់ក៏ដូចជារដ្ឋាភិបាលប្រទេសនីមួយៗ មានតួនាទីគន្លឹះក្នុងការអភិបាលអ៊ីនធឺណែត។

## សេចក្តីសង្ខេប

មេរៀនអំពីការអភិបាលអ៊ីនធឺណែតនេះបានពិភាក្សាលើចំនុចដូចតទៅ៖

១. ការអភិបាលអ៊ីនធឺណែតគឺផ្តោតលើការអភិបាលជាជាងអ៊ីនធឺណែតខ្លួនឯង។ វាបានគ្របដណ្តប់បញ្ហានយោបាយមួយចំនួនទាក់ទងនឹងគោលនយោបាយអន្តរជាតិអំពីអ៊ីនធឺណែត ការប្រើប្រាស់ និងការប្រើមិនត្រឹមត្រូវនៃអ៊ីនធឺណែត ព្រមទាំងការពង្រាយសេវាអ៊ីនធឺណែតដើម្បីសំរេចបាននូវការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច។

២. ផ្ទុយទៅនឹងទស្សនៈយល់ច្រលំ អ៊ីនធឺណែតពិតជាមានចំនុចគ្រប់គ្រងកណ្តាលនៅក្នុងតំបន់ដែលគេហៅថាប្រព័ន្ធ root zone។ ប្រព័ន្ធ root zone នេះស្ថិតក្នុងការកាន់កាប់របស់ទីភ្នាក់ងារមួ ដែលមានការគាំទ្រដោយសហរដ្ឋអាមេរិច ដែលគេហៅថា ICANN។

៣. WGIG ត្រូវបានបង្កើតឡើងដោយអង្គការសហប្រជាជាតិ ដើម្បីដោះស្រាយភាពតានតឹងជុំវិញស្ថានភាពនយោបាយនៃការអភិបាលអ៊ីនធឺណែត។ នៅក្នុងកិច្ចពិភាក្សាតឹងសសៃកបន្ទាប់ពីការចេញផ្សាយនៃរបាយការណ៍របស់ WGIG គេបានទទួលស្គាល់ថាវេទិកាអភិបាលអ៊ីនធឺណែតសាមញ្ញមួយនឹងត្រូវបង្កើតឡើង ប៉ុន្តែប្រព័ន្ធ root zone នៅតែស្ថិតក្នុងកណ្តាប់ដៃរបស់ ICANN ដដែល ដោយមានលក្ខន្តិកៈដែលថាមានតែរដ្ឋាភិបាលជាតិនីមួយៗប៉ុណ្ណោះ ដែលអាចគ្រប់គ្រងនិងដំណើរការ ccTLD របស់គេរៀងៗខ្លួន។

៤. ការអភិបាលអ៊ីនធឺណែតគួរតែមានលក្ខណៈជាពហុភាគី និងពហុវិស័យ។ នេះមានន័យថា គ្មានប្រទេសណាមួយ ឬអង្គភាពណាមួយគួរតែមានសិទ្ធិសំរេចតែឯកឯងបានឡើយ។ ផ្ទុយទៅវិញ ដំណើរការប្រព្រឹត្តិទៅ ទោះបីនៅថ្នាក់ជាតិឬអន្តរជាតិក៏ដោយ គួរតែមានលក្ខណៈប្រជាធិបតេយ្យ។ នៅកំរិតអន្តរជាតិ ការចូលរួមនៃការអភិបាលអ៊ីនធឺណែតត្រូវធ្វើឡើងដោយប្រទេសទាំងអស់ ម៉្យាងទៀតនៅកំរិតណាក៏ដោយ ការអភិបាលត្រូវមានការចូលរួមពីផ្នែកឯកជន និងសង្គមស៊ីវិល។

៥. ដូចនឹងជីវិតនៃពិភពខាងក្រៅ ប្រព័ន្ធអ៊ីនធឺណែតអាចនឹងត្រូវបានដាក់បទបញ្ញត្តតាមវិធីសាស្រ្ត ៤យ៉ាង៖ ច្បាប់ ក្រឹត្យក្រមសង្គម យន្តការទីផ្សារ និងស្ថាបត្យកម្ម។ ដោយសារការពង្រឹងច្បាប់មិនជា និច្ចកាលទទួលជោគជ័យលើប្រព័ន្ធអ៊ីនធឺណែតនោះ រដ្ឋាភិបាលទាំងអស់ត្រូវមានកាច្នៃប្រឌិតខ្ពស់ ក្នុងការដាក់បទបញ្ញត្តទៅលើអ៊ីនធឺណែត។

៦. បទបញ្ញត្តផ្ទៃក្នុងគឺជាទំរង់មួយបញ្ជាក់ពីការប្រគល់សិទ្ធិដោយរដ្ឋាភិបាល។ ជាញឹកញាប់ គេបានផ្តល់ជាអនុសាសន៍ថាទំរង់បែបនេះគឺជាការដាក់បទបញ្ញត្តដែលគួរជ្រើសយក ប៉ុន្តែវាមានចំនុចត្រូវបំពេញ ជាច្រើននិងការចំណាយផ្សេងៗក្នុងការយកទំរង់នេះមកប្រើប្រាស់។

៧. មានផ្លូវតំរង់ទិសក្នុងការដាក់បទបញ្ញត្តលើអ៊ីនធឺណែត ដើម្បីជំរុញភាពសុះសាយនៃអ៊ីនធឺណែតខណៈដែលនៅតែមានផលប៉ះពាល់ ត្រូវបានស្នើឡើង។

៨. អ៊ីនធឺណែតផ្តល់ជីវិតថ្មីសំរាប់អំពើឧក្រិដ្ឋចាស់ៗមួយចំនួន ព្រមទាំងបង្កើតអពើរំលោភបំពានថ្មីៗមួយចំនួន។ ភាពលំបាកមួយក្នុងចំណោមភាពលំបាកជាច្រើននោះ គឺការផ្តល់និយម័យន័យនៃបទឧក្រិដ្ឋសំរាប់អំពើ ណាមួយនោះ។

ក. ចំនុចពីរដែលមានការព្រមព្រៀងក្នុងការអនុវត្តជាក់ស្តែង គឺរូបអាសគ្រាមកុមារ និងការឆបោកអ្នកប្រើប្រាស់។ ទីភ្នាក់ងារពង្រឹងច្បាប់ពិតជាបានសហការក្នុងការរើកមុខជនល្មើសមកកាត់ ទោស។

ខ. Spam គំរោងការឆបោក កូដព្យាបាទ និងការក្លែងបន្លំលួចយកព័ត៌មានផ្ទាល់ខ្លួនជាទូទៅត្រូវបានគេទទួលស្គាល់ថាជាអំពើរំលោភបំពាន ប៉ុន្តែច្បាប់ប្រឆាំងអំពើបែបនេះមិនមាននៅគ្រប់ប្រទេសទាំងអស់ នោះទេ។

គ. ការចាត់វិធានការច្បាប់ និងសកម្មភាពកាន់តែមិនសូវមានសំរាប់ការប្រឆាំងនឹងការគំរាម កំហែងការលួចតាមដាន តាមប្រព័ន្ធអ៊ីនធឺណែត ក៏ដូចជាការលួចអត្តសញ្ញាណ និងការឈ្លក់វង្វេងនឹង អ៊ីនធឺណែត។

ឃ. វេទិកាអភិបាលអ៊ីនធឺណែតបានជំរុញឲ្យមានការបង្កើត សម្ព័ន្ធសកម្ម សំរាប់ក្រុមដែលមានចំណាប់អារម្មណ៍ក្នុងការដោះស្រាយបញ្ហាដោយឡែកណាមួយ អាចជួបជុំគ្នាពិភាក្សាស្វែងរកមេរៀនល្អៗ ក៏ដូចជាសកម្មរួមគ្នាណាមួយ។

៩. ខណៈដែលការដាក់បទបញ្ញាត្រូវមានកាច្នៃប្រឌិតខ្ពស់ ការដាក់ទណ្ឌកម្មនៅលើអ៊ីនធឺណែតក៏ត្រូវមានការច្នៃប្រឌិតដូចគ្នាផងដែរ។

១០. នៅទីបំផុត កិច្ចសហប្រតិបត្តិការអន្តរជាតិមានសារសំខាន់ក្នុងការប្រឆាំងនឹងអំពើឧក្រិដ្ឋលើអ៊ីនធឺណែត។

១១. បញ្ហាអភិបាលអ៊ីនធឺណែតបានហូរហៀរមកលើសង្គមខាងក្រៅផងដែរ។ ឧទាហរណ៍មានដូចជានយោបាយប្រកួតប្រជែង ការត្រួតពិនិត្យ និងសិទ្ធិក្នុងការបញ្ចេញមតិ ការបង្កុចកេរ្តិ៍ឈ្មោះ ការរក្សា សិទ្ធិ និងកម្មសិទ្ធិបញ្ញា ព្រមទាំង ភាពជាឯកជន។

១២. កត្តាជំរុញមួយក្នុងការសិក្សាទៅលើការអភិបាលអ៊ីនធឺណែត គឺទាក់ទងនឹងកង្វល់ដែលថាប្រទេសកំពុងអភិវឌ្ឍន៍អាចនឹងត្រូវបានគេទុកចោលឲ្យនៅខាងក្រោយ ក្នុងវិស័យសេដ្ឋកិច្ចព័ត៌មានវិទ្យានោះ។ ដូច្នេះការប្រើប្រាស់ ICTD គឺជាផ្នែកសំខាន់នៃការអភិបាលអ៊ីនធឺណែត។

ក. មានដែនកំណត់ និងឧបសគ្គចំពោះការប្រើប្រាស់ ICTD

ខ. មានរឿងរ៉ាវជោគជ័យមួយចំនួនដែលត្រូវសិក្សានិងយកគំរាប់តាម

គ. ICTD អាចជួយធ្វើឲ្យប្រសើរឡើងនៃស្ថានការណ៍ពិតពខាងក្រៅ ជាឧទាហរណ៍ ដោយសារវាបានធ្វើឲ្យតម្លាភាពមានភាពល្អជាងមុន

១៣. ភាពតានតឹងផ្នែកនយោបាយក្នុងការអភិបាលអ៊ីនធឺណែតមិនត្រូវបានដោះស្រាយនៅឡើយទេ ហើយការកសាងសមត្ថភាពសំរាប់ការងារអភិបាលអ៊ីនធឺណែតនៅតែជាបញ្ហា ដែលរដ្ឋាភិបាលទាំងអស់ចាំបាច់ត្រូវដោះស្រាយ។




ប្រភព៖ គ្រឹស្ថាន Diplo http://textus.diplomacy.edu/textusbin/env/scripts/Pool/GetBin.asp?IDPool=1190

# កថាបន្ថែម

## សំរាប់ការអានបន្ថែម

Ang, Peng Hwa. 2005. *ការរៀបចំភាពច្របូកច្របល់ Ordering Chaos: ការដាក់បទបញ្ញាលើអ៊ីនធឺណែត Regulating the Internet*. Singapore: Thomson.

Butt, Danny, ed. 2005. *ការអភិបាលអ៊ីនធឺណែត Internet Governance: ទស្សនៈវិស័យក្នុងតំបន់អាស៊ីប៉ាហ្វិច Asia-Pacific Perspectives*. Bangkok: UNDPAPDIP. http://www.apdip.net/publications/ict4d/igovperspectives.pdf.

Cukier, Kenneth Neil. 2005. អ្នកណានឹងគ្រប់គ្រងអ៊ីនធឺណែត ? Who Will Control the Internet? *កិច្ចការបរទេស Foreign Affairs* November/December. http://www.foreignaffairs.org /20051101facomment84602 /kenneth-neil-cukier/whowill-control-the-internet.html.

Drissel, David. 2006. ការអភិបាលអ៊ីនធឺណែតក្នុងពិភពលោកដែលមានសសរទ្រច្រើន Internet Governance in a Multipolar World: ការតទល់នឹងការគ្របដណ្តប់ដ៏ធំធេងរបស់អាមេរិច Challenging American Hegemony. *ការពិនិត្យឡើងវិញនៃកិច្ចការអន្តរជាតិរបស់សាកលវិទ្យាល័យខេមប្រ៊ីដ Cambridge Review of International Affairs* 19( 1 ), March, 105-120.

Kapur, Akash. 2005. *ការអភិបាលអ៊ីនធឺណែត Internet Governance: A Primer*. Bangkok: UNDP-APDIP. http://www.apdip.net/publications/iespprimers/eprimer-igov.pdf.

ក្រុមការងារអភិបាលអ៊ីនធឺណែត Working Group on Internet Governance.2005. *របាយការណ៍របស់ក្រុមការងារអភិបាលអ៊ីនធឺណែត Report of the Working Group on Internet Governance*. http://www.wgig.org.

Wu, Tim, Esther Dyson, A. Michael Froomkin and David A. Gross. អំពីអនាគតនៃការអភិបាលអ៊ីនធឺណែត On the Future of Internet Governance. *សង្គមអាមេរិចសំរាប់សន្និសីទប្រចាំឆ្នាំស្តីពីច្បាប់អន្តរជាតិ American*

*Society of International Law Proceedings of the Annual Meeting*, លេខ Vol.101.
http://ssrn.com/abstract=992805.

## សន្ទានុក្រម

| | |
|---|---|
| IP Address | អាស័យដ្ឋានប្រូតូកូលអ៊ីនធឺណែត៖ អត្តសញ្ញាណដែលមានតែមួយសំរាប់សំគាល់កុំព្យូទ័រនីមួយៗ ឬឧបករណ៍ណាមួយនៅលើបណ្តាញដែលប្រើអ៊ីនធឺណែតប្រូតូកូល (IP)។ នាពេលបច្ចុប្បន្នមាន IP address ពីរប្រភេទដែលកំពុងត្រូវបានប្រើប្រាស់គឺ IP វគ្គទី ៤ (IPv4) និង IP វគ្គទី ៦ (IPv6)។ IPv4 (ដែលប្រើលេខចំនួន ៣២ bit) ត្រូវបានប្រើតាំងពីឆ្នាំ ១៩៨៣ មកម្ល៉េះ និងនៅតែជាប្រភេទដែលប្រើច្រើនជាងគេនៅឡើយ។ ការដាក់ឲ្យប្រើប្រាស់ IPv6 ប្រូតូកូលបានចាប់ផ្តើមក្នុងឆ្នាំ ១៩៩៩។ អាស័យដ្ឋាន IPv6 គឺជាលេខដែលមាន ១២៨ bit។ |
| Registrar | ស្ថាប័នមួយដែលអនុម័តដោយ (ទទួលអាជ្ញាប័ណ្ណ) ក្រុមហ៊ុនចុះបញ្ជីណាមួយដើម្បីមានសិទ្ធិជាតំណាងលក់ឈ្មោះដូម៉េន។ |
| Registry | ក្រុមហ៊ុន ឬអង្គភាពមួយដែលថែរក្សាជាតាបេសកណ្តាលសំរាប់កត់ត្រា TLD ឬសំរាប់ធ្វើការាំងខ្ទប់ IP address (ឧទាហរណ៍ RIR: សូមមើលផ្នែកខាង ក្រោម)។ ក្រុមហ៊ុនចុះបញ្ជីមួយចំនួនបានដំណើរការដោយគ្មាន Registrar ឡើយទាល់តែសោះ ដោយឡែកមានមួយចំនួនក៏មាន Registrar ផងដែរ ប៉ុន្តែរាល់ការចុះបញ្ជីត្រូវ ធ្វើឡើងដោយផ្ទាល់ជាមួយនឹង Registry ខ្លួនឯង។ |
| RIRs | ក្រុមហ៊ុនចុះបញ្ជីនៅតាមតំបន់។ ពួកគេគឺជាអង្គភាពមិនរកប្រាក់ចំណេញដែលទទួលខុសត្រូវចែកចាយ IP address នៅក្នុងកំរិតតំបន់ ទៅឲ្យអ្នកផ្តល់សេវាអ៊ីនធឺណែត និងក្រុមហ៊ុនចុះបញ្ជីក្នុងស្រុក។ |
| Root servers | Server ដែលផ្ទុកព័ត៌មានសំរាប់ចង្អុលទៅរក server ផ្តល់ឈ្មោះនៅក្រោមបង្គាប់ដទៃទៀត ដែលផ្ទុកព័ត៌មានអំពី TLD។ ជាការបន្ថែមទៅលើ root server □ដើម□ ដែលមាន ១៣គ្រឿងសំរាប់ផ្ទុកឯកសារ root zone ដែលគ្រប់គ្រងដោយអាជ្ញាធរផ្តល់ លេខនៅលើប្រព័ន្ធអ៊ីនធឺណែត នាពេលបច្ចុប្បន្នមាន server |

| | |
|---|---|
| | Anycast ជាច្រើន ដែលផ្ទុកព័ត៌មានដូចគ្នាទៅនឹង root server ហើយដែលត្រូវបានគេពង្រាយនៅពាសពេញពិភពលោក ដោយក្រុមហ៊ុនប្រតិបត្តិការមួយចំនួននៅតាមតំបន់ចំនួន ១២។ |
| Root zone file | ឯកសារមេ (ដើម) ដែលផ្ទុកព័ត៌មានសំរាប់ចង្អុលទៅរក server ផ្តល់ឈ្មោះ សំរាប់ TLD ទាំងអស់។ |
| WHOIS | ប្រូតូកូលសំរាប់ផ្តល់ចំលើយ ឬស្វែងរកព័ត៌មានអំពីការប្រតិបត្តិការ ដែលត្រូវបានប្រើយ៉ាងទូលំទូលាយសំរាប់ផ្តល់ព័ត៌មានសេវាកម្មទៅឲ្យអ្នកប្រើប្រាស់។ ទោះបីជាពីដើមត្រូវបានប្រើដោយក្រុមហ៊ុនចុះបញ្ជី TLD ភាគច្រើន (តែមិនមែនទាំងអស់ទេ) ដើម្បីផ្តល់សេវា □ទំព័រពណ៌ស□ និងព័ត៌មានអំពីបណ្តាឈ្មោះដូម៉េនដែលបានចុះបញ្ជីហើយ ការប្រើប្រាស់បច្ចុប្បន្នបានគ្របដណ្តប់លើសេវាផ្តល់ព័ត៌មានដ៏ច្រើនជាងមុន ដោយរួមទាំងសកម្មភាពរបស់ RIR WHOIS ក្នុងការស្វែងរកព័ត៌មានអំពីការចាត់ចែង IP address។ |

## កំណត់សំគាល់សំរាប់អ្នកបណ្តុះបណ្តាល

ដូចដែលបានធ្វើកំណត់សំគាល់ក្នុងផ្នែកដែលមានចំណងជើង □អំពីក្រុមមេរៀន□ មេរៀននេះ និងមេរៀនដទៃទៀតនៅក្រុមនៃមេរៀននេះ ត្រូវបានរចនាឡើងសំរាប់ជាប្រយោជន៍ដល់អ្នកអានច្រើន ប្រភេទ និងទៅតាមការប្រែប្រួល និងលក្ខណៈខុសៗគ្នានៃជាតិនីមួយៗ។ មេរៀននេះក៏ត្រូវបានរចនាឡើងក្នុងទំរង់សំរាប់ធ្វើការបង្ហាញ ទាំងមូល ឬជាផ្នែកៗ តាមប្រភេទផ្សេងៗគ្នា ទាំងនៅលើ និងក្រៅបណ្តាញ។ មេរៀននេះអាចយកទៅសិក្សាជាផ្ទាល់ខ្លួន ឬជាក្រុមនៅក្នុងស្ថាប័នបណ្តុះបណ្តាល ព្រមទាំងការិយាល័យរដ្ឋាភិបាល។ ចំណេះដឹងពីមុនរបស់អ្នកអាន ក៏ដូចជារយៈពេលសិក្សា នៃវគ្គបណ្តុះបណ្តាលនឹងអាចកំនត់នូវទំហំក្បោះក្បាយសំរាប់ការបង្ហាញអំពីមេរៀន។

□កំណត់សំគាល់□ ទាំងនេះអាចផ្តល់ឲ្យអ្នកបណ្តុះបណ្តាលនូវគំនិតនិងការណែនាំ សំរាប់ធ្វើការបង្ហាញខ្លឹមសារមេរៀនឲ្យកាន់តែមានប្រសិទ្ធភាព។ ការណែនាំបន្ថែមអំពីវិធីសាស្រ្តក្នុងការបណ្តុះបណ្តាលត្រូវបានផ្តល់នៅក្នុងសៀវភៅក្បួនអំពីការរចនាការបង្ហាត់បង្ហាញ ដែលជាឯកសារភ្ជាប់មកជាមួយក្រុម មេរៀន *Acedemy of ICT Essentials for Government Leaders* នេះ។ សៀវភៅក្បួននេះអាចទាញ យកពី http://www.unapcict.org/academy។

## ការប្រើប្រាស់មេរៀន

រាល់ផ្នែកនីមួយៗនៃមេរៀនដែលបានលើកបង្ហាញ នឹងចាប់ផ្តើមពីពាក្យពេជន៍ស្តីអំពីគោលបំណងនិងបញ្ចប់ដោយកំរងសំនួរ □សាកល្បងខ្លួនឯង□។ អ្នកអានអាចប្រើគោលបំណងនិងសំនួរទាំងនេះសំរាប់ជាមូលដ្ឋានវាយតំលៃការរីកចំរើនអំពីការយល់ដឹងមេរៀន។ ផ្នែកនីមួយៗក៏មានបញ្ចូលសំណួរពិភាក្សា និងលំហាត់អនុវត្តជាក់ស្តែង ដែលត្រូវបំពេញដោយអ្នកអាន ឬប្រើប្រាស់ដោយអ្នកបណ្តុះបណ្តាល។ សំនួរនិងលំហាត់ទាំងនេះត្រូវបានរចនាឡើងដើម្បីបង្កលក្ខណៈឲ្យអ្នកអានវាស់វែងបទពិសោធន៍ផ្ទាល់ខ្លួនដើម្បីវាយតំលៃខ្លឹមសារមេរៀន និងគិតឆ្លុះបញ្ចាំងលើបញ្ហាដែលបានយកមកបង្ហាញ។

បណ្តាករណីជាក់ស្តែងទាំងអស់គឺជាផ្នែកសំខាន់នៃខ្លឹមសារមេរៀន។ ពួកវាត្រូវបានប្រើក្នុងគោលបំណងសំរាប់ការពិភាក្សា និងការវិភាគ ជាពិសេសអំពីភាពពាក់ព័ន្ធនៃគំនិតគន្លឹះៗ និងគោលការណ៍ដែលមានក្នុងមេរៀននេះ ទៅនឹងករណីក្នុងសង្គមជាក់ស្តែង។ ចំពោះករណី ការអភិបាលអ៊ីនធឺណែតបញ្ហាដែលបានលើកមក ក្នុងពេលតែមួយមានលក្ខណៈជាអន្តរជាតិ ជាតិ ឬតាមមូលដ្ឋាន។ បញ្ហាជាច្រើនស្ថិតក្នុងកំរិតជាតិ និងកំរិតមូលដ្ឋាន ជាពិសេសអំពីការប្រើប្រាស់ ICT ដោយរួមទាំងអ៊ីនធឺណែតសំរាប់ការអភិវឌ្ឍន៍។ អ្នកបណ្តុះបណ្តាលអាចលើកទឹកចិត្តអ្នកចូលរួមឲ្យលើកយកករណី និងឧទាហរណ៍ដទៃៗទៀត ដែលចេញបទពិសោធន៍របស់ពួកគេផ្ទាល់ ដើម្បីផ្តល់ជាភស្តុតាងគាំទ្រកិច្ចពិភាក្សាក្នុងមេរៀន។

## ការរៀបចំពេលវេលាបណ្តុះបណ្តាល

ដោយអាស្រ័យទៅលើអ្នកអាន ពេលវេលាដែលមាន ព្រមទាំងលក្ខខណ្ឌនិងស្ថានភាពជាក់ស្តែង ខ្លឹមសារនៃមេរៀននេះអាចលើកមកបង្ហាញទៅតាមទំរង់ពេលវេលាផ្សេងៗ។ អាចមានមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ដែលចាំបាច់ត្រូវទទួលព័ត៌មានស្តីពីបច្ចុប្បន្នភាពនៃការអភិបាលអ៊ីនធឺណែត។ ដូច្នេះ កម្មវិធីបណ្តុះបណ្តាលគួរតែមានវេលាសិក្សាម្តងៗរយៈពេល ១ម៉ោង ឬ ២ម៉ោង។ កម្មវិធីបណ្តុះបណ្តាលទាំង មូលនឹងមានរយៈពេលយ៉ាងខ្លីបំផុត ១.៥ ថ្ងៃ។ មេរៀននេះត្រូវបានរចនាឡើង ជាមួយនឹងផ្នែកទាំង ៣ដំបូងផ្តោតសំខាន់ទៅលើប្រវត្តិ និងទ្រឹស្តី ចំណែកឯផ្នែកដែលនៅសល់ផ្តោតលើការប្រើប្រាស់។

### សំរាប់ថ្នាក់រយៈពេល ១ ទៅ ២ម៉ោង

ចូរច្របាច់ចូលគ្នារវាងផ្នែកទី១ និងទី២ ដោយផ្តោតលើបញ្ហា និងលទ្ធផលដែលបានសំរេចដោយ WSIS និង WGIG។ សូមបញ្ចូល ICTD ដែលដកស្រង់ចេញពីផ្នែកទី ៦។

### សំរាប់ថ្នាក់រយៈពេល ៣ម៉ោង

ចូរច្របាច់បញ្ចូលគ្នារវាងផ្នែកទី១ និងទី២ ដូចខាងលើ។ អាស្រ័យលើចំនួនអ្នកចូលរួម ចូរផ្តុំផ្នែកទី៣ ទី៤ ទី៥ និងទី៦ ដោយអាចជ្រើសរើសចំនុចណាមួយដូចខាងក្រោម៖

- ការបង្កើតគំរោងច្បាប់មួយ ដោយផ្តោតទៅលើផ្នែកទី៤ និងទី៥ ឬ
- ការប្រើប្រាស់ ICTD ដោយផ្តោតលើផ្នែកទី៥ និងទី៦។

### សំរាប់ថ្នាក់រយៈពេល ១ថ្ងៃពេញ (៦ម៉ោង)

ចូរបង្រៀនផ្នែកទី១ ទី២ និងទី៣ នៅពេលព្រឹក។ នៅពេលថ្ងៃ ចូរពិភាក្សាផ្នែកទី៤ ទី៥ និងទី៦ ដោយប្រើលំហាត់ និងសំនួរសំរាប់ពិភាក្សា។ ធ្វើដូចនេះគឺដើម្បីរក្សាកំរិតកំលាំងថាមពលឲ្យនៅខ្ពស់បន្ទាប់ពីបាយថ្ងៃត្រង់។ ចូរធ្វើការសរុបផ្នែកទី៧។

**សំរាប់ថ្នាក់រយៈពេល ១.៥ ថ្ងៃ**

ទោះជាមាន ៧ផ្នែកក៏ដោយ ផ្នែកនីមួយៗមានប្រវែងមិនដូចគ្នាទេ។ អ្នកគួរតែធ្វើការចាប់អារម្មណ៍ទៅលើគោលបំណងនៃក្រុម ដែលមានន័យថា អ្វីដែលគេរំពឹងថានឹងទទួលបានបន្ទាប់ពីវគ្គបណ្តុះ បណ្តាល។ ផ្នែកទី១ និងទី២បានឲ្យទំងន់ទៅលើព័ត៌មានអំពីប្រវត្តិទូទៅ។ បើសិនជាក្រុមមិនមានចំណាប់អារម្មណ៍ទៅលើផ្នែកនេះទេ ប៉ុន្តែផ្តោតទៅលើលទ្ធផល ដូច្នេះគួរផ្តោតទៅលើលទ្ធផលវិញ។ ជាទូទៅអ្នកចូលរួមមានទំនោរចង់បានជំនាញដែលអាចយកទៅប្រើប្រាស់ជាក់ស្តែងជាងនេះ។

ការពិភាក្សានិងការផ្លាស់ប្តូរព័ត៌មានអាចជាកត្តាមានប្រយោជន៍ដើម្បីពង្រឹងបន្ថែមទៅលើការបណ្តុះបណ្តាល។

**សំរាប់ថ្នាក់រយៈពេល ៣ថ្ងៃ**

ចូរពិភាក្សាផ្នែកទី១ និងទី២ នៅថ្ងៃទី១។ ដោយផ្អែកទៅលើប្រតិកម្មតបរបស់ក្រុម អ្នកប្រហែលជាអាចបន្តទៅផ្នែកទី៣។ នៅថ្ងៃទី២ ចូរបង្រៀនអំពីផ្នែកទី៣ ទី៤ និងទី៥។ នៅថ្ងៃទី៣ ចូរពិភាក្សាផ្នែកទី៦ និង ទី៧។ ការកត់សំគាល់អំពីភាពរីកចំរើនរបស់អ្នកចូលរួមមានសារសំខាន់ណាស់។ ពួកគេគួរត្រូវបានជំរុញទឹកចិត្តឲ្យលើកយកបទពិសោធន៍ផ្ទាល់ខ្លួនមកចែករំលែកនៅក្នុងថ្នាក់រៀន។ ជាពិសេស ពួកគេគួរត្រូវបានលើកទឹកចិត្តឲ្យប្រើផ្នែកទី៦ ដើម្បីដោះស្រាយបញ្ហាគំលាតឌីជីថលនៅក្នុងប្រទេសរបស់គេរៀងៗខ្លួន។ ផ្នែកទី៧ បានផ្តល់នូវឱកាសមួយក្នុងការសរុបនៅពេលបញ្ចប់ថ្នាក់។

## អំពីអ្នកនិពន្ធ

លោក Ang Peng Hwa គឺជាសាស្ត្រាចារ្យ និងនាយកនៃមជ្ឈមណ្ឌលស្រាវជ្រាវអ៊ីនធឺណែតសឹង្ហបូរី នៅសាលាបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ Wee Kim Wee នៃសាកលវិទ្យាល័យបច្ចេកវិទ្យា Nangyang ប្រទេសសឹង្ហបូរី។ ម៉្យាងទៀត ក្នុងឋានៈជាមេធាវីតាមរយៈវគ្គបណ្តុះបណ្តាល គាត់បានបង្រៀនច្បាប់សារព័ត៌មាន និងនយោបាយ។ ការសិក្សាស្រាវជ្រាវរបស់គាត់គឺស្ថិតនៅក្នុងផ្នែកអភិបាលអ៊ីនធឺណែត។ សៀវភៅរបស់គាត់ដែលបានបោះពុម្ពក្នុងឆ្នាំ ២០០៥ ក្រោមចំណងជើងថា *ការរៀបចំភាពច្របូកច្របល់៖ការដាក់បទបញ្ជាលើអ៊ីនធឺណែត* បានលើកហេតុផលគាំទ្រថា អ៊ីនធឺណែតអាចត្រូវបាន និងកំពុងតែ ព្រមទាំងគួរតែ មានការដាក់បទបញ្ជា។

នៅឆ្នាំ ២០០៤ គាត់ត្រូវបានតែងតាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ឲ្យធ្វើការនៅក្រុមការងារអភិបាលអ៊ីនធឺណែត ដើម្បីរៀបចំរបាយការណ៍សំរាប់កិច្ចប្រជុំកំពូលពិភពលោកឆ្នាំ ២០០៥ ស្តីពីសង្គមព័ត៌មានវិទ្យា។ ក្រោយមក គាត់បានជួយបង្កើតបណ្តាញនៃបណ្ឌិតសភាសំរាប់ការអភិបាលអ៊ីនធឺណែតពិភពលោក (Global Governance Academic Network) ក្នុងឋានៈជាប្រធានកិត្តិយស។

នាពេលបច្ចុប្បន្ន គាត់មានតួនាទីជាប្រធាននៃមជ្ឈមណ្ឌលសារព័ត៌មាននិងគមនាគមន៍អាស៊ី (Asian Media Information and Communication Centre)។ ម៉្យាងទៀត គាត់ក៏ជាប្រធាននៃក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានគមនាគមន៍ Mudra (Governance Council of the Mudra Institute of Communications) នៅទីក្រុង Ahmedabad ប្រទេសឥណ្ឌាផងដែរ។ គាត់បានឈប់សំរាកពីតួនាទីជាប្រធានចាប់ពី ខែកក្កដា ឆ្នាំ

២០០៨ រយៈពេល ១ឆ្នាំសិក្សា ដើម្បីដឹកនាំនិងជួយគាំទ្រការបង្កើតនៃវិទ្យាស្ថានស្រាវជាវ គមនាគមន៍ Mudra។

## UN-APCICT

មជ្ឈមណ្ឌលអាស៊ីនិងប៉ាស៊ីហ្វិចសំរាប់បណ្តុះបណ្តាលបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍អភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ (The United Nations Asian and Pacific Training Centre for Information and Communication Technology for Development, UN-APCICT) គឺជាស្ថាប័នចំណុះនៃគណកម្មការសេដ្ឋកិច្ចនិងសង្គមកិច្ចប្រចាំអាស៊ីនិងតំបន់ប៉ាស៊ីហ្វិចរបស់អង្គការសហប្រជាជាតិ (The United Nations Economic and Social Commission for Asia and the Pacific, ESPCAP)។ UN-APCICT មានគោលបំណងជួយពង្រឹងកិច្ចប្រឹងប្រែងរបស់ប្រទេសជាសមាជិកនៃ ESCAP ក្នុងការប្រើប្រាស់ ICT ដើម្បីអភិវឌ្ឍសង្គមសេដ្ឋកិច្ចតាមរយៈការកសាងសមត្ថភាពស្ថាប័ននិងធនធានមនុស្ស។ ការងារ របស់ UN-APCICT ផ្តោតទៅលើ៖

១. ការបណ្តុះបណ្តាល៖ ដើម្បីបង្កើនចំណេះដឹង ក៏ដូចជាជំនាញផ្នែក ICT ដល់អ្នកធ្វើគោលនយោបាយ និងអ្នកប្រកបវិជ្ជាជីវៈ ICT ព្រមទាំងពង្រឹងសមត្ថភាពរបស់អ្នកបណ្តុះបណ្តាល ក៏ដូចជាវិទ្យាស្ថានបណ្តុះបណ្តាល ICT ទាំងអស់

២. ការស្រាវជ្រាវ៖ ដើម្បីទទួលការងារសិក្សាស្រាវជ្រាវនិងវិភាគទាក់ទងនឹងការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យ ICT និង

៣. ការប្រឹក្សា៖ ដើម្បីផ្តល់សេវាប្រឹក្សាអំពីកម្មវិធីអភិវឌ្ឍនធនធានមនុស្សទៅដល់សមាជិក ESCAP និងសមាជិកបន្ទាប់បន្សំដទៃទៀត។

UN-APCICT មានទីតាំងនៅទីក្រុង Incheon សាធារណរដ្ឋកូរ៉េ។ http://www.unapcict.org

## ESCAP

ESCAP គឺជាផ្នែកមួយនៃអង្គការសហប្រជាជាតិសំរាប់ការអភិវឌ្ឍតាមតំបន់ ព្រមទាំងមានមុខងារជាមជ្ឈមណ្ឌលមេ សំរាប់ការអភិវឌ្ឍសង្គម និង សេដ្ឋកិច្ចនៃអង្គការសហប្រជាជាតិប្រចាំអាស៊ី និងតំបន់ប៉ាស៊ីហ្វិច។ អណត្តិនីមួយៗរបស់ ESCAP មានគោលដៅពង្រីកកិច្ចសហប្រតិបត្តិការរវាងសមាជិក ទាំង ៥៣ របស់ខ្លួន ក៏ដូចជាសមាជិកបន្ទាប់បន្សំចំនួន ៩ ផ្សេងទៀត។ ESCAP បានផ្តល់នូវទស្សនៈវិស័យក្នុងការតភ្ជាប់គ្នាជាយុទ្ធសាស្ត្ររវាងកម្មវិធីថ្នាក់ជាតិនិងថ្នាក់ពិភពលោក ក៏ដូចជាបញ្ហាដែលជួបប្រទះនៅកំរិតជាតិនិងពិភពលោកផងដែរ។ វាផ្តល់ការគាំទ្រដល់រដ្ឋាភិបាលនៅក្នុងតំបន់ ដើម្បីធ្វើសាមគ្គីភាពនៅក្នុងតំបន់ក្នុងន័យគាំទ្រដល់វិធានការតំបន់សំរាប់ដោះស្រាយបញ្ហាប្រឈម ទាក់ទងនឹងសង្គមសេដ្ឋកិច្ចប្រចាំតំបន់តាមបែបសកលភាវូបនីយកម្ម។ ការិយាល័យរបស់ ESCAP មានទីតាំងនៅទីក្រុងបាងកក ប្រទេសថៃ។ http://www.unescap.org

## The Academy of ICT Essentials for Government Leaders

http://www.unapcict.org/academy

*Academy* គឺជាកំរងមុខវិជ្ជាប្រើសំរាប់បណ្តុះបណ្តាលអំពី ICTD ដែលមានគ្រប់ជ្រុងជ្រោយ ជាមួយនឹងមេរៀនចំនួន ៨ដំបូងមានគោលបំណងបំពាក់ចំណេះដឹងនិងជំនាញសំខាន់ៗដល់អ្នកធ្វើគោលនយោបាយ ដើម្បីប្រើឱកាសដែលផ្តល់ដោយ ICT សំរាប់ការទទួលបាននូវគោលដៅអភិវឌ្ឍន៍ជាតិ និងតភ្ជាប់គំលាតឌីជីថល។

### មេរៀនទី១៖ ការតភ្ជាប់រវាងកម្មវិធីប្រើប្រាស់ ICT ជាមួយនឹងការអភិវឌ្ឍដែលមានន័យ

ធ្វើឲ្យលេចឡើងនូវបញ្ហាគន្លឹះៗ និងដំណាក់កាលសំរេចចិត្តផ្សេងៗ ចាប់ពីគោលនយោបាយរហូតដល់ដំណាក់កាលអនុវត្ត ដើម្បីសំរេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្ស។

### មេរៀនទី២៖ ICT សំរាប់គោលនយោបាយអភិវឌ្ឍន៍ ដំណើរការ និងអភិបាល

ផ្តោតទៅលើការធ្វើគោលនយោបាយ និងការអភិបាល ICTD និងផ្តល់ជាព័ត៌មានសំខាន់ៗទាក់ទងនឹងទស្សនៈវិស័យផ្សេងៗអំពីគោលនយោបាយជាតិ យុទ្ធសាស្ត្រ និងគំរោងការណ៍លើក តំកើង ICTD។

### មេរៀនទី៣៖ កម្មវិធីប្រើប្រាស់របស់ ICT នៅក្នុងរដ្ឋាភិបាលតាមបែបអេឡិចត្រូនិច

គ្រួតពិនិត្យទៅលើគោលគំនិត គោលនយោបាយ និងប្រភេទនៃកម្មវិធីប្រើប្រាស់ របស់ e-government ព្រមទាំងពិភាក្សាផងដែរអំពីវិធីដែលប្រព័ន្ធ e-government ត្រូវបានបង្កើតឡើង និងស្វែងរកការរចនាផ្សេងៗសំរាប់ជាជំរើសពិចារណា។

### មេរៀនទី៤៖ ទំនោររបស់ ICT សំរាប់ថ្នាកដឹកនាំរដ្ឋាភិបាល

ផ្តល់នូវគំនិតស៊ីជម្រៅទាក់ទងនឹងទំនោរ ICT បច្ចុប្បន្ន ក៏ដូចជាទិសដៅនាថ្ងៃអនាគតរបស់វា។ វាក៏មើលផងដែរទៅលើគោលពិចារណាគន្លឹះៗស្តីពីគោលនយោបាយ និងបច្ចេកទេស នៅពេលត្រូវធ្វើការសំរេចចិត្តទាក់ទងនឹង ICTD។

### មេរៀនទី៥៖ ការអភិបាលអ៊ីនធឺណែត

ពិភាក្សាការអភិវឌ្ឍគោលដែលកំពុងប្រព្រឹត្តិទៅទាក់ទងនឹង នយោបាយអន្តរជាតិ និងនីតិវិធីសំរាប់គ្រប់គ្រងការប្រើប្រាស់ និងប្រតិបត្តិការរបស់អ៊ីនធឺណែត។

### មេរៀនទី៦៖ ភាពជាឯកជន និងសន្តិសុខនៃព័ត៌មាននិងបណ្តាញ

លើបង្ហាញអំពីបញ្ហាសន្តិសុខព័ត៌មាន និងទំនោររបស់វា ព្រមទាំងដំណើរការនៃការបង្កើតយុទ្ធសាស្រ្តសំរាប់សន្តិសុខព័ត៌មាន។

### មេរៀនទី៧៖ ការគ្រប់គ្រងគំរោង ICT តាមបែបទ្រឹស្តីនិងការអនុវត្ត

ណែនាំឲ្យស្គាល់នូវគោលគំនិតផ្សេងៗសំរាប់គ្រប់គ្រងគំរោងដែលទាក់ទងនឹងគំរោង ICTD ដូចជាវិធីសាស្រ្ត ដំណើរការ និងវិន័យផ្សេងៗសំរាប់គ្រប់គ្រងគំរោង ដែលគេប្រើប្រាស់ច្រើន។

### មេរៀនទី៨៖ ជំរើសនៃការផ្តត់ផ្គង់ថវិការសំរាប់ ICTD

ធ្វើការពិនិត្យទៅលើជំរើសនៃការផ្គត់ផ្គង់ថវិកាសំរាប់ ICTD និងគំរោងផ្សេងៗរបស់ e-government។ ភាពជាដៃគូឯកជននិងសាធារណៈត្រូវបានធ្វើឲ្យឃើញច្បាស់ថាជាជំរើសដ៏ល្អមួយ
សំរាប់ជាជំរើសផ្គត់ផ្គង់នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ។

មេរៀនទាំងនេះកំពុងត្រូវបានកែតំរូវបន្ថែមដោយបញ្ចូលនូវករណីជាក់ស្តែងក្នុងមូលដ្ឋាន ដែលធ្វើឡើងដោយដៃគូ *Academy* ជាតិផ្សេងៗ ដើម្បីធានាថាមេរៀនទាំងនេះមានភាពទាក់ទង និងអាចដោះស្រាយតំរូវការរបស់អ្នកធ្វើគោលនយោបាយក្នុងប្រទេសផ្សេងៗ។ មេរៀនទាំងនេះក៏ត្រូវបានបកប្រែជាភាសាផ្សេងៗផងដែរ។ លើសពីនេះទៅទៀត មេរៀនទាំងនេះនឹងត្រូវបានធ្វើឲ្យមានបច្ចុប្បន្នភាពជាប្រចាំដើម្បីឲ្យពួកវាមានភាពទាក់ទងជាមួយនឹងអ្នកធ្វើគោលនយោបាយ និងដើម្បីបង្កើតមេរៀនថ្មីៗបន្ថែមដែលផ្តោតទៅលើ ICTD សំរាប់សតវត្សទី ២១។

**បណ្ឌិតសភា** APCICT **ដែលមាននៅលើបណ្ដាញ** ( AVA http://ava.unapcict.org )

- ជាទំរង់នៃការសិក្សាពីចំងាយសំរាប់ *Academy*
- ត្រូវបានរចនាឡើងដើម្បីធានាថារាល់មេរៀន *Academy* ទាំងអស់ត្រូវមានមេរៀន ការបង្ហាញ និងករណីជាក់ស្ដែងផ្សេងៗ ដែលអាចចូលទៅប្រើបានតាមរយៈ បណ្ដាញ។
- បង្កលក្ខណៈឲ្យអ្នកសិក្សាអាចសិក្សាឯកសារផ្សេងៗតាមសមត្ថភាពរៀនរបស់ពួកគេ

**បណ្ដាញកណ្ដាលសំរាប់កិច្ចសហការតាមអេឡិចត្រូនិច** ( e-Co Hub http://www.unapcict.org/ecohub )

- គេហទំព័រផ្ដល់ធនធាន និងបណ្ដាញផ្លាស់ប្ដូរចំណេះដឹងអំពី ICTD
- ផ្ដល់នូវភាពងាយស្រួលក្នុងការចូលទៅយកធនធានតាមមេរៀន
- អ្នកប្រើប្រាស់អាចចូលរួមការពិភាក្សាលើបណ្ដាញ និងក្លាយជាផ្នែកមួយនៃសហគមន៍លើ បណ្ដាញ e-Co Hub ដែលមានតួនាទីផ្លាស់ប្ដូរនិងពង្រីកឃ្លាំងចំណេះដឹងអំពី ICTD

សូមចុះឈ្មោះលើបណ្ដាញដើម្បីទទួលបានផលប្រយោជន៍ពេញលេញពីសេវាផ្ដល់ដោយ AVA និង e-Co Hub នៅ http://www.unapcict.org/join_form